ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- អៀង ធីរិទ្ធ និយាយ រឿង ប្រល័យពូជសាសន៍នៅកម្ពុជា
- លក្ខខណ្ឌនៃភស្តុតាង

[illegible]

លេខ៨ ខែសីហា ឆ្នាំ២០០០

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
លេខ៥ ខែឧសភា ឆ្នាំ២០០០

## មាតិកា

- សំបុត្រ................................................ ១

**ផ្នែកឯកសារ**

- វាយរំដោះទីក្រុងភ្នំពេញ.......................................... ២
- អៀង ធីរិទ្ធ ហៅ «មិត្តភា ឬមិត្តហុង» ........................ ៤
- ប្រវត្តិរូប ដួន ប្រាសិទ្ធ........................................ ៧
- ភោគ ឆាយ មុនពេលក្លាយជាអ្នកទោស...................... ១០
- ចម្លើយសារភាពៈ ប្រវត្តិអ្នកទោសរបស់អង្គការ.............. ១៤

**ផ្នែកប្រវត្តិសាស្ត្រ**

- សម្លេងពីមន្ទីរស-២១ ........................................... ១៧
- គ្រោះថ្នាក់នៃអព្យាក្រឹតភាព..................................... ២១

**ផ្នែកច្បាប់**

- គំរូមួយនៃភ័ស្តុតាងឯកសារ........................................ ២៤
- ទារុណកម្ម...................................................... ២៦
- លក្ខខណ្ឌនៃភ័ស្តុតាង............................................ ៣០
- ច្បាប់ស្តីពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍.......... ៣៤
- កិច្ចខិតខំប្រឹងប្រែងរបស់សហរដ្ឋអាមេរិក........................ ៣៦

**វេទិកាពិភាក្សាជាសាធារណៈ**

- ២០ ឧសភា........................................................ ៤០
- ប្រសាសន៍របស់សម្តេច ហ៊ុន សែន ........................ ៤២
- បញ្ហាដែនសមត្ថកិច្ច................................................ ៤៥
- ម្ភៃប្រាំឆ្នាំក្រោយស្រមោលនៃការពិត............................ ៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- មាស សារិន បានដឹងអំពីជោគវាសនា........................ ៥១
- កោះខ្សាច់ទន្លេ កោះស្ត្រីមេម៉ាយ................................ ៥៥
- លិខិតពីអភិបាលខេត្តពោធិសាត់..............................ក្របក្នុង

**កំណាព្យ**

- ថ្ងៃ២០ ឧសភា............................................ក្របក្រោយ



លោកពូ ឡាយនី

# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***វាគ្មិនលេខនេះ:*** *អេលីហ្សាបែត វ៉ាន់ស្កាក់, គ្រេក អេចឆេសាន់, សាស្ត្រាចារ្យ ដេវីត ឆេនដល័រ, យែនគុន ក្លេមម័រ, ម៉ៃឃឺល ស៊ីព័រ, សាស្ត្រាចារ្យ ស៊ីវ ហេឌ័រ, ម៉ម កល្យានី* ***អ្នកនិពន្ធនិងស្រាវជ្រាវ:*** *សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ* ***ជំនួយការនិពន្ធនាយក:*** *អែម សុឃីម* ***និពន្ធនាយករងទី១:*** *ដាត គុសល* ***និពន្ធនាយករងទី២:*** *ស៊ីម សុរិយ៉ា* ***អ្នកបកប្រែ:*** *សួ ប៊ុនស៊ូ* ***និពន្ធនាយកទូទៅ:*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រ:*** *ស៊ឹម សុភ័ក្ត្រ,* ***គ្រប់គ្រងការចែកផ្សាយ:*** *ទ្រី សុភក្តិ*

**សំបុត្រៈ**

# ស្រមោល

លោកពូ ឡាយនី នៅខេត្តព្រៃវែងបានប្រាប់ខ្ញុំថាដរាបណាគាត់នៅឃើញស្រមោលរបស់គាត់នៅពេលដែលគាត់ដើរទៅកាន់វាលស្រែ គឺគាត់មិនអាចបំភ្លេចបានសោះឡើយនូវការកាប់សម្លាប់របស់ពួកខ្មែរក្រហមមកលើប្រពន្ធកូនរបស់គាត់និងប្រជាជនខ្មែរទាំងមូលក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ប្រសាសន៍របស់លោកពូបានកំណត់ និងបញ្ជាក់ឲ្យឃើញនូវការទាមទារពីរដ៏សំខាន់គឺ១) ទាមទារឲ្យមានការស្រាយបំភ្លឺឲ្យបានច្បាស់លាស់ពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និង២) ទាមទារឲ្យទទួលស្គាល់អ្វីដែលមានភាពជាមនុស្ស ។ ការទាមទារនេះគឺពុំមែនជាការសងសឹក ។ វាគឺជាការសំខាន់ណាស់ក្នុងការទទួលស្គាល់ថាអ្វីដែលបានកើតឡើងមកលើមនុស្សគឺជារឿងមួយដែលមនុស្សមិនអាចបំភ្លេចបាន ។ ពួកមេដឹកនាំខ្មែរក្រហមផ្តាច់ខ្លួនស្ទើរតែទាំងអស់បច្ចុប្បន្ននេះបានបង្ខំជនរងគ្រោះរបស់ខ្លួនទាំងផងដឹតផងល់ឲ្យបំភ្លេចអតីតកាលបំភ្លេចអំពីការជិះជាន់និងការកាប់សម្លាប់ដែលខ្លួនបានប្រព្រឹត្ត ។ ពួកមេដឹកនាំខ្មែរក្រហមផ្តាច់ខ្លួន មកទល់នឹងពេលនេះ នៅតែមិនយល់អំពីលក្ខខណ្ឌរបស់មនុស្ស និងភាពជាមនុស្ស ហើយស្គាល់តែអ្វីដែលជាភាពព្រៃផ្សៃ តិរច្ឆាន និងជ្រុលនិយម ។ អ្វីដែលកើតឡើងចំពោះមនុស្ស គឺមនុស្សមិនអាចបំភ្លេចបានឡើយដរាបណាខ្លួននៅមានវិញ្ញាណ និងជីវិត ។ ការបង្ខំឲ្យមនុស្សបំភ្លេចបានគឺមានតែការផ្តាច់ជីវិតរបស់មនុស្សដូចដែលពួកខ្មែរក្រហមបានធ្វើមកលើប្រជាជនកម្ពុជាអស់រាប់លាននាក់រួមទាំងក្រុមគ្រួសាររបស់លោកពូ ឡាយនី ទាំងមូល ។ អំពើបែបនេះគឺជាការប្រឆាំងដោយចំហ និងដោយផ្ទាល់ទៅលើលក្ខខណ្ឌនិងសិទ្ធិរស់រានមានជីវិតរបស់មនុស្សគ្រប់រូប ហើយត្រូវតែរងទទួលនូវការដាក់ទណ្ឌកម្មដោយខានពុំបាននៅចំពោះមុខច្បាប់ និងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ។ ជនរងគ្រោះរាប់ពាន់នាក់ដែលខ្ញុំបានជួបប្រាស្រ័យសម្ភាសន៍ពុំមាននរណាម្នាក់បានទាមទារសំណងអ្វីឲ្យសមទៅនឹងអំពើដែលពួកខ្មែរក្រហមបានធ្វើមកលើក្រុមគ្រួសារខ្លួននោះទាល់តែសោះឡើយក្រៅពីចង់បាននូវចម្លើយតែមួយគឺ «ហេតុអ្វីបានពួកខ្មែរក្រហមសម្លាប់ក្រុមគ្រួសាររបស់គាត់?» ។ ប្រសិនបើជាមាននូវការទាមទារសំណង ឬជម្ងឺចិត្តតាមផ្លូវច្បាប់ ខ្ញុំជឿថាទោះបីដាក់គុកពួកមេដឹកនាំខ្មែរក្រហមផ្តាច់ខ្លួនទាំងអស់ចំនួន១លានឆ្នាំក៏មិនគ្រប់គ្រាន់ដែរ ហើយទោះបីជាបង្ខំ អៀង សារី អៀង ធីរិទ្ធ ខៀវ សំផន នួន ជា តាម៉ុក ឬឌុច ឲ្យធ្វើការដោយអត់អាហារ១លានឆ្នាំ ក៏ពុំស្មើនឹងការអត់ឃ្លានក្នុងរបបខ្មែរក្រហម ហើយនឹងទោះបីយកមេដឹកនាំខ្មែរក្រហមទាំងនោះ មកជ្រៀកជា១លានចម្រៀកក៏មិនអាចធ្វើឲ្យជីវិតខ្មែររាប់លាននាក់ ទាំងក្រុមគ្រួសាររបស់លោកពូ ឡាយនី ត្រឡប់មកវិញបានដែរ ។ អ្វីដែលជនរងគ្រោះបានទទួចសុំគឺមានភាពតិចតួចស្តួចស្តើងបំផុត ។ ប៉ុន្តែមកទល់នឹងថ្ងៃនេះអ្វីដែលជាការទទូចសុំរបស់ជនរងគ្រោះមិនទាន់ត្រូវបានឆ្លើយតប ។ ការអត់ធ្មត់ ការសន្សំសុខ និងការថែរក្សាសន្តិភាពត្រូវបានជ្រោមជ្រែងដោយជនរងគ្រោះអស់រយៈពេលជាង២០ឆ្នាំមកហើយ ។ ឥឡូវនេះគឺសមល្មមដល់វេនពួកមេដឹកនាំខ្មែរក្រហមឲ្យគ្រាន់តែឆ្លើយបំភ្លឺនៅចំពោះមុខតុលាការមួយថាតើហេតុដូចម្តេចបានជាពួកខ្លួនសម្លាប់ប្រជាជនខ្មែរយ៉ាងព្រៃផ្សៃយ៉ាងនេះ?

ស្រមោលអាចគេចវេសចេញពីលោកពូ ឡាយនី បាននៅពេលដែលគាត់ត្រឡប់មកពីស្រែវិញនាពេលព្រះអាទិត្យហៀបលិច ប៉ុន្តែវានៅក្លាយទៅជាសុបិនដ៏អាក្រក់សម្រាប់គាត់ដដែលជាដដែល និងជាច្រើនឆ្នាំ និងជាការរំខានដល់អនាគតនៃជីវិតរបស់គាត់ ក៏ដូចជាជនរងគ្រោះរាប់លាននាក់ដរាបណាការពិតនៅក្នុងរបបខ្មែរក្រហមមិនត្រូវបានបង្ហាញឲ្យឃើញជាសាធារណៈដោយអង្គតុលាការឯករាជ្យមួយ ។

**ឆាំង យុ**

# ខាយរំដោះទីក្រុងភ្នំពេញ

**(ដកស្រង់តាមសំណៅដើមទាំងស្រុងពីឯកសារ D ០០៧១០)**

**(តពីលេខមុន)**

- ពេលនោះអង្គការខ្មែរក្រហមគេចាត់ទុកភ្នំពេញខាងលើគឺជាប្រជាជន និងជយភណ្ឌ ផ្តាច់មុខរបស់ភូមិភាគបូព៌ា ដូច្នេះអ្នកណាគេចទៅណាក៏ទៅចុះ ឲ្យតែនៅក្នុងបរិវេណទឹកដីខេត្តព្រៃវែង ខេត្តស្វាយរៀង ហើយនិងខេត្តកំពង់ចាម គឺគេចាត់ទុកជាប្រជាជនរបស់គេទាំងអស់ អ្នកធ្វើដំណើរទាំងអស់កាលណាគ្រប់កំណត់ថ្ងៃធ្វើដំណើរត្រឹមណា គឺគេបង្ខំឲ្យនៅត្រង់នោះតាមទិសអង្គការកំណត់ទុកជាដាច់ខាត ។

- ពេលដែលគេទៅឃាត់អ្នកដែលគេជម្លៀសចេញពីទីក្រុងឲ្យចូលមករស់នៅក្នុងភូមិរបស់គេ គណៈភូមិគេធ្វើការឃោសនាថា បងប្អូនពុកម៉ែមិនបាច់ធ្វើដំណើរខ្លួនឯងទៀតទេ ព្រោះស្រុកភូមិពុកម៉ែនៅឆ្ងាយ នាំគ្នាស្នាក់នៅទីនេះសិនចុះ ចាំអង្គការយើងរករថយន្តជូនពុកម៉ែឲ្យទៅដល់ស្រុកភូមិកំណើតវិញស្រួលជាង នេះជាពាក្យបោកបញ្ឆោតរបស់អង្គការខ្មែរក្រហមទៅលើប្រជាជនលើកទី២ ។

**២) ប្រជាជននៅទីក្រុងភ្នំពេញភាគខាងជើង អង្គការខ្មែរក្រហមចែកចេញជា២ផ្នែក**

ក) ភាគខាងជើង ផ្នែក (ប៉ែក) ខាងកើត ចាប់ពីស្ថានីយ៍រថភ្លើងទៅទល់នឹងទន្លេមេគង្គ អង្គការចាត់ទុកប្រជាជននិងជយភណ្ឌផ្នែកនេះជាកម្មសិទ្ធរបស់ភូមិភាគឧត្តរទិស ប្រជាជននេះត្រូវតាមផ្លូវជាតិលេខ៥ ហើយឆ្លងទន្លេមេគង្គទៅផ្លូវជាតិលេខ៦ មុខឆ្ពោះទៅខេត្តកំពង់ធំ និងខេត្តសៀមរាប ។

ខ) ភាគខាងជើង ផ្នែក (ប៉ែក) ខាងលិចចាប់ពីស្ថានីយ៍រថភ្លើងរហូតដល់តំបន់ទួលគោកផ្នែកខាងកើត អង្គការខ្មែរក្រហមចាត់ទុកប្រជាជនជយភណ្ឌផ្នែកនេះជាកម្មសិទ្ធិរបស់ភូមិភាគពាយ័ព្យទិស ប្រជាជននេះត្រូវចាកចេញពីភ្នំពេញតាមថ្នល់ជាតិលេខ៥ ជាមួយពួកឧត្តរទិសដែរ មុខឆ្ពោះទៅកាន់ខេត្តពោធិសាត់ និងខេត្តបាត់ដំបង ។

- ប្រជាជនភូមិភាគនេះ ក៏មិនបានទៅដល់ទិសរបស់ខ្លួនដែរ ព្រោះពាក្យពេចន៍របស់អង្គការខ្មែរក្រហមគ្មានអ្វីពិតប្រាកដនោះទេ គឺសុទ្ធតែពាក្យបោកបញ្ឆោតទាំងអស់ ។

**៣) ប្រជាជននៅទីក្រុងភ្នំពេញភាគខាងលិច អង្គការខ្មែរក្រហមចែកចេញជា២ផ្នែក**

ក) ភាគខាងលិចផ្នែក (ប៉ែក) ខាងជើង ចាប់ពីថ្នល់សាលដីហ្គោលមកដល់ទួលគោក ផ្នែកខាងលិចសល់ពីភូមិភាគពាយ័ព្យ អង្គការខ្មែរក្រហមចាត់ទុកប្រជាជន ជយភណ្ឌផ្នែកនេះជាកម្មសិទ្ធិរបស់ភូមិភាគបស្ចិមទិស គណៈភូមិភាគត្រូវជម្លៀសប្រជាជនផ្នែកនេះទៅកាន់ខេត្តកំពង់ឆ្នាំង ទៅតាមថ្នល់កាត់ទទឹងចេញពីថ្នល់ទទឹង ខេត្តកណ្តាល ទៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

ខ) ភាគខាងលិចផ្នែក (ប៉ែក) ខាងត្បូង ពីថ្នល់សាលដីហ្គោល រហូតដល់សាលារៀន១៨មីនា អង្គការខ្មែរក្រហមចាត់ទុកប្រជាជន ជយភណ្ឌផ្នែកនេះជាកម្មសិទ្ធិរបស់ភូមិភាគបស្ចិម គណៈភូមិភាគសម្រេចឲ្យយកប្រជាជនផ្នែកនេះទៅខេត្តកំពង់ស្ពឺ ចេញពីភ្នំពេញតាមផ្លូវស៊ឹងមានជ័យ អូរបែកក្អម តាមថ្នល់ជាតិលេខ៤ ប្រជាជនភូមិភាគនេះក៏គ្មានអ្វីខុសពីប្រជាជនភូមិភាគខាងលើដែរ ។

**៤) ប្រជាជននៅក្នុងទីក្រុងភ្នំពេញ ភាគខាងត្បូង ប្រជាជនភូមិភាគនេះអង្គការខ្មែរក្រហមចែកចេញជា២ផ្នែក**

ក) ភាគខាងត្បូងផ្នែក (ប៉ែក) ខាងលិច ចាប់ពីសាលារៀន១៨មីនា រហូតបឹងត្របែក អង្គការខ្មែរក្រហមចាត់ទុកប្រជាជនជយភណ្ឌភាគនេះជាកម្មសិទ្ធិរបស់ភូមិភាគនិរតីទិស គណៈភូមិភាគសម្រេចឲ្យប្រជាជនផ្នែកនេះចេញពីក្រុងភ្នំពេញទៅនៅខេត្តកំពត ប្រជាជនផ្នែកនេះត្រូវចេញតាមថ្នល់ស៊ឹងមានជ័យទៅស៊ឹងបាគូ ។

ខ) ភាគខាងត្បូងផ្នែក (ប៉ែក) ខាងកើតចាប់ពីថ្នល់មុនីវង្ស រហូតដល់ទន្លេ ប្រជាជនផ្នែកនេះអង្គការខ្មែរក្រហមចាត់ទុកជាកម្មសិទ្ធិរបស់ភូមិភាគបស្ចិមទិស គណៈភូមិភាគសម្រេចឲ្យប្រជាជនផ្នែកនេះចេញពីក្រុងភ្នំពេញទៅនៅខេត្តតាកែវត្រូវចេញតាមថ្នល់ កាត់តាមក្បាលថ្នល់ទៅតាខ្មៅ ចូលតាមថ្នល់ជាតិលេខ២

- ប្រជាជនភាគនេះក៏គ្មានអ្វីឲ្យខុសពីប្រជាជនខាងលើដែលបានរៀបរាប់រួចមកហើយនោះទេ ។

## ចម្លើយទី១ វគ្គទី២

## មូលហេតុអ្វី?

## មូលហេតុដែលគេជម្លៀស គោលដៅ របស់បក្សខ្មែរក្រហម

១) ពួកគេគោរពតាមទិសរបស់អង្គការដាក់ចុះតាមទ្រឹស្តីរបស់ប្រធានបក្សកុម្មុយនិស្តចិនម៉ៅកាំង ត្រូវបោសសម្អាតខ្មាំងផ្ទៃក្នុងឲ្យអស់ជាមុនសិន ទើបសម្រេចកិច្ចការអ្វីៗឯទៀតតាមក្រោយ ។

២) បក្សកុម្មុយនិស្តមានបំណងធ្វើយ៉ាងណាឲ្យប្រជាជនស្គាល់ការពិបាកឲ្យខ្លាំងជាទីបំផុត ដើម្បីបំបាក់ស្មារតី ពត់មនុស្សឲ្យដើរតាមមាគ៌ារបស់បក្សកុម្មុយនិស្តឲ្យបាន១០០% នៅពេលបំពេញការកសាងបក្សនៅក្នុងប្រទេសកម្ពុជា ។

៣) ក្នុងគោលបំណងរបស់បក្សកុម្មុយនិស្តធ្វើការជ្រើសរើសមនុស្ស

-ថាតើមនុស្សប្រភេទណា ដែលត្រូវរាប់បញ្ចូលជាប្រជាជនរបស់បក្ស

-តើមនុស្សប្រភេទណាដែលត្រូវកម្ទេចចោលតាមពាក្យស្លោករបស់គេថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត»

៤) បក្សកុម្មុយនិស្តមានបំណងសម្លាប់មនុស្សដំពូកដែលគេមិនគួរទុកដូចជាអ្នករដ្ឋការ មានទាហានជាដើម តែការសម្លាប់នេះ កុម្មុយនិស្តមានគោលបំណងធ្វើយ៉ាងណាកុំឲ្យមតិមហាជនក្នុងប្រទេស ហើយនិងមតិសកលលោកគេមើលឃើញច្បាស់ពេក ឲ្យស្របតាមពាក្យស្លោកថា «អូសទូកកុំឲ្យល្អានចាប់ត្រីបានកុំឲ្យល្អក់ទឹក»

៥) កុម្មុយនិស្តមានបំណងធ្វើយ៉ាងណាឲ្យប្រជាជនទាំងអស់នោះកុំឲ្យនៅមានការសោកស្តាយនឹងទ្រព្យសម្បត្តិ នាំឲ្យគេមានការពិបាកត្រួតត្រាទៅថ្ងៃមុខ ។

៦) បក្សកុម្មុយនិស្តមានផែនការទុកជាមុនរួចស្រេចទៅហើយថា កុម្មុយនិស្តដាច់ខាតមិនឲ្យប្រជាជនមានទ្រព្យសម្បត្តិជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ អ្វីៗគឺជារបស់រដ្ឋទាំងអស់ ។

៧) បក្សកុម្មុយនិស្តត្រូវតែធ្វើបែបនេះដើម្បីឲ្យស្របតាមពាក្យឃោសនារបស់គេ កាលគេរៀបចំកម្លាំងកម្ទេចរបបសេរី គេប្រាប់កម្មាភិបាលនិងប្រជាជនថា ផ្ទះថ្ម វីឡា ឡានពេជ្រ ដែលពួកសក្តិភូមិ និងពួកមូលធន គហបតីប្រើប្រាស់សព្វថ្ងៃនេះ គឺជាវត្ថុដែលចេញអំពីកម្លាំងញើសឈាមរបស់វណ្ណៈកសិករ និងកម្មករ ដូច្នេះពួកយើងត្រូវតែខំរំដោះឲ្យឈ្នះ កាលណាយើងឈ្នះរបស់ទាំងនោះគឺអង្គការបក្សត្រូវតែជូនដល់ពុកម៉ែនិងមិត្តជាដាច់ខាត ពេលនោះយើងត្រូវតែដេញពួកវាចេញ ពួកយើងត្រូវតែទៅដេកស៊ីទីនោះយកពួកវាមកប្រើប្រាស់ម្តងវិញ ។

៨) បក្សកុម្មុយនិស្តគេចងក្រងទ្រឹស្តីទុកថា កាលណាយើងរំដោះប្រទេសបានពីរបបសេរី គឺយើងត្រូវតែរៀបចំកសាងប្រទេសពីជនបទមុន ។

៩) ដើម្បីកសាងប្រទេសពីក្រឈានទៅរកមានគឺយើងត្រូវតែយកពួកសក្តិភូមិ នាយទុន និយាយខ្លីគឺអ្នកនៅទីក្រុងហើយនិងទ្រព្យសម្បត្តិរបស់ពួកទាំងនោះមកកសាងប្រទេស វាគាប់ប្រសើរជាងទុកចោលឲ្យខូចខាត ។

## ចម្លើយទី១ វគ្គទី៣

## មុនជម្លៀសចេញពីទីក្រុង

មុននឹងគេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញតាមការសង្កេតផ្ទាល់ឃើញថាការជម្លៀសចេញនេះគឺគេរៀបចំទុកជាមុនស្រេចទៅហើយ ព្រោះសង្កេតឃើញមានរថយន្ត ត្រីចក្រយានយន្ត ត្រីចក្រយាន មានប្រដាប់បំពងសម្លេងមេក្រូជាប់ជាមួយរបៀបដូចៗគ្នា ។ ពាក្យនិយាយក៏ដូចគ្នាទៀត ។

១) ប្រជាជននៅក្នុងទីក្រុងភ្នំពេញទាំងមូលមិនថាអ្នកណាជាអ្នកណាគឺត្រូវតែចេញទៅខាងក្រៅក្រុងចម្ងាយពាគីឡូម៉ែត្រ ។

២) ចំនួនតែ៣ថ្ងៃទេ

៣) មិនបាច់យករបស់របរនាំឲ្យពិបាកទេ

៤) បងប្អូនទៅដល់ទីណា ទីនោះមានអង្គការយើងឧបត្ថម្ភគ្រប់សព្វមូលហេតុដែលអង្គការត្រូវជម្លៀសបងប្អូនចេញតែមួយរយៈសិននោះគឺ ១. អង្គការចង់សង្គ្រោះបងប្អូនទាំងអស់ដែលបាក់បែកបងប្អូនញាតិមិត្តមកពីជនបទ ដោយសារពួកសាធារណរដ្ឋបនក្បត់ លន់ ណុល ដែលកៀរបង្ខំយកមករស់នៅទីក្រុងលំបាកខ្លោចផ្សាបែបនេះ ។ វិលត្រឡប់ទៅជួបជុំគ្រួសារយើងវិញទីនេះគ្មានអីហៅថា...***(ឯកសារផ្នែកចម្លើយទី១ វគ្គទី៣មានតែត្រឹមនេះ ដោយឯកសារពុំទាន់ត្រូវបានរកឃើញនៅឡើយទេ)*** ។

# អៀង ធីរិទ្ធ

# (ហៅមិត្តភា ឬមិត្តហុង) និយាយរឿងប្រល័យពូជសាសន៍នៅកម្ពុជា



*កំណត់ហេតុឯកសារនៅទំព័របន្ទាប់ដែលផ្តល់ដោយលោក ភីតធ័រ ម៉ាហ្គាយ ត្រូវបានដកស្រង់មកពីភាពយន្តឯកសាររបស់ក្រុមហ៊ុន Studio H & S ។*

*កំណត់ហេតុឯកសារបង្ហាញអំពី ១) សមមិត្ត អៀង ធីរិទ្ធ ឬ ខៀវ ធីរិទ្ធ «ហៅមិត្តភា ឬមិត្តហុង» ដែលជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងអប់រំសិក្សាធិការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ «១៩៧៥-១៩៧៩» ២) សមមិត្ត អៀង សារី ឬ គឹម ត្រាង ឬ ស៊ូ ហាវ ដែលជាឧបនាយករដ្ឋមន្ត្រីទទួល បន្ទុកកិច្ចការបរទេសហើយជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជាក្នុងរវាងឆ្នាំ១៩៧៥-១៩៧៩ ។*

**ឆាំង យុ**

១) កំណត់ហេតុឯកសារស្តីអំពីការសម្ភាសន៍ជាមួយសមមិត្ត អៀង ធីរិទ្ធ ដកស្រង់ចេញពីភាពយន្តឯកសារដែលមានចំណងជើងថា «ប្រទេសកម្ពុជាៈ ការស្លាប់ និងការរស់ឡើងវិញ» ផលិតដោយក្រុមហ៊ុន Studio H & S, ឆ្នាំ១៩៨០ ។ កិច្ចសម្ភាសន៍នេះធ្វើឡើងនៅទីក្រុងស្តុកខូម ប្រទេសស៊ុយអែត ។

២) កំណត់ហេតុឯកសារស្តីអំពីការសម្ភាសន៍ជាមួយសមមិត្ត អៀង សារី ដកស្រង់ចេញពីភាពយន្តឯកសារដែលមានចំណងជើងថាៈ «អង្គការ Die Angkar» ផលិតដោយ Studio H & S និពន្ធនិងចាត់ចែងដោយលោក ហេណូគី និងស្មៀម៉ាន់ (ជនជាតិអាល្លឺម៉ង់) ក្នុងឆ្នាំ១៩៨១ ។

បទសម្ភាសន៍ជាមួយនឹងសមមិត្ត អៀង ធីរិទ្ធ ដែលមានចំណងជើងថា «ប្រទេសកម្ពុជាៈ ការស្លាប់ និងការរស់ឡើងវិញ» មានដូចតទៅៈ

◆អស់លោកដឹងទេ កាលមុនសហរដ្ឋអាមេរិកឈ្លានពានប្រទេសយើង ប៉ុន្តែគេគាំទ្រនូវឯករាជ្យភាពរបស់យើង យើងចាត់ទុកសហរដ្ឋអាមេរិកជាមិត្តរបស់យើង ។

◆ខ្ញុំគិតថាគ្រប់ៗគ្នាដឹងរឿងនេះ មនុស្សពេញពិភពលោកឥឡូវនេះដឹងថាភាពទុរ្ភិក្សត្រូវបានបង្កើតដោយចេតនាដោយពួកយួនឈ្លានពានទឹកដីក្នុងគោលបំណងដើម្បីវាយបំបាក់នូវការតស៊ូរបស់យើង ។

◆ពួកយួនវាបានឆក់ប្លន់ ផ្ទះសម្បែង ភោគផល កសិកម្ម រួចហើយក៏ចូលមកដុតភោគផលកសិកម្មនៅក្នុងស្រែ ពីព្រោះកាលណោះវាជារដូវប្រមូលកាត់ប្រមូលផល ។ ដូច្នេះពួកយួនបានកាត់ផ្តាច់ការផ្គត់ផ្គង់ស្បៀងតាមវិធីនេះ ហើយមកដល់ឥឡូវនេះពួកវាប្រើប្រាស់គ្រោះទុរ្ភិក្សនេះជាអាវុធដើម្បីសម្លាប់ប្រជាជនយើង ។

◆យើងបានទទួលជោគជ័យក្នុងការផ្តល់ស្បៀងអាហារនិងសម្លៀកបំពាក់គ្រប់គ្រាន់ដល់ប្រជាជន ព្រមទាំងផ្តល់នូវថ្នាំសង្កូវ និងព្យាបាលជំងឺដោយឥតគិតថ្លៃ ។

◆យើងបានចាប់ពួកភ្នាក់ងារយួនក្នុងជួរទ័ព្រាំ (ជាឈ្មោះតំណាងឲ្យពួកធ្វើវិទ្ធង្សនា ឬពួកបះបោរ) ដោយជោគជ័យចាប់តាំងពីឆ្នាំ១៩៧៥ មកទល់នឹងខែឧសភា ឆ្នាំ១៩៧៨ ហើយគឺក្នុងខែឧសភានេះតែម្តងដែលយើងបានកម្ទេចពួកវិទ្ធង្សនាយួន




ដោយបានចាប់មេៗវានៅក្នុងក្រុមទាំងនេះ ។

◆ចំពោះផ្នែករូបភាព ។ អស់លោកដឹងទេពួកយួនវាឆ្លាតណាស់ចំពោះអារឿងនេះ ។ ពួកវាអាចធ្វើរូបភាពគ្រប់បែបយ៉ាង ។ ពួកយួននឹងធ្វើអ្វីៗទាំងអស់ដើម្បីធ្វើឲ្យការឈ្លានពានរបស់វាមានលក្ខណៈស្របច្បាប់ ។ ហើយខ្ញុំសារភាពដូចខ្ញុំបានប្រាប់អស់លោកអ៊ីចឹងថា មានការធ្វើជ្រុលជ្រួស ប៉ុន្តែការជ្រុលជ្រួសទាំងអស់នោះគឺធ្វើឡើងដោយមានបញ្ជាមកពីទីក្រុងហាណូយ ។ ដូច្នេះរដ្ឋអំណាចក្រុងហាណូយមានមុខពីរ ។ នៅដៃម្ខាងពួកវាបានបញ្ជាភ្នាក់ងាររបស់វាឲ្យចូលមកប្រព្រឹត្តនូវអំពើទាំងនេះនៅក្នុងប្រទេសរបស់យើងហើយដៃម្ខាងទៀតពួកវាបានយកការជ្រុលជ្រួសមួយចំនួនធ្វើជាខែលដើម្បីពង្រីកនូវការឃោសនាជាប្រពន្ធ័ប្រឆាំងនឹងរដ្ឋាភិបាលរបស់យើងក្នុងគោលបំណងមួយថា នៅពេលដែលវាឈ្លានពានប្រទេសយើងជាសាធារណៈហើយនោះមតិសាធារណៈបានប្រមូលផ្តុំប្រឆាំងយើងរួចជាស្រេចហើយនឹងគាំទ្រនិងផ្តល់ភាពស្របច្បាប់ដល់ការឈ្លានពាននោះដោយនិយាយថា «អូ! ពួកយួនទាំងនោះល្អណាស់ ពួកវាមិនមែនជាអ្នកឈ្លានពានទេ ពួកយួនគឺជាពួករំដោះ ប្រជាជនកម្ពុជាដែលជាជនរងគ្រោះរបស់រដ្ឋាភិបាលខ្លួនឯង ។

◆ពួកយួនឈ្លានពានមកដល់ឥឡូវបានសម្លាប់រង្គាលប្រជាជនយើងអស់ជាងមួយលានកន្លះ ។ ភាគច្រើននៃប្រជាជនទាំងនោះជាស្ត្រី កូនក្មេង មនុស្សចាស់ជរាដែលខ្សោយគ្មានកម្លាំងគ្រប់គ្រាន់ក្នុងការរត់ចេញទាន់ពេលពីការសម្លាប់រង្គាលដ៏ខ្លាំងក្លានោះ ។

◆ នេះការឃោសនារបស់យួន ។ ខ្ញុំប្រាប់អស់លោកទៅចុះ ខ្ញុំមិនប្រកែកទេថា ខ្ញុំបានជម្លៀសប្រជាជនទាំងអស់រួមទាំងគ្រួសាររបស់ខ្ញុំផង មានម្តាយ ប្អូនស្រី ចេញពីទីក្រុងភ្នំពេញឲ្យទៅជនបទ ។ ប្អូនស្រីរបស់ខ្ញុំគឺជាវេជ្ជបណ្ឌិត ។ នាងក៏ជាបញ្ញវន្តដែរ ហើយអស់លោកដឹងទេថា ពួកយួនបានសម្លាប់ប្អូនស្រីខ្ញុំ ។ ដូច្នេះអស់លោកមិនអាចនិយាយថា ខ្ញុំបានសម្លាប់ប្អូនស្រីខ្លួនឯងឡើយ ។ វាមិនអាចទៅរួចទេ ។ ដូច្នេះពួកវាបានចេញបញ្ជាឲ្យធ្វើយ៉ាងដូច្នោះដើម្បីសម្លាប់បញ្ញវន្ត ពីព្រោះបញ្ញវន្តមានឧត្តមគតិស្នេហាជាតិ និងមានឯករាជ្យម្ចាស់ការណាស់ បញ្ញវន្តទាមទារឯករាជ្យប្រទេសយ៉ាងទទូចប្រឆាំងនឹងការឈ្លានពានរបស់យួន ។ ហើយគឺពួកនោះឯងដែលបានប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ហើយធ្វើការឃោសនានៅលើឆាកអន្តរជាតិថារដ្ឋាភិបាលរបស់យើងគឺជាអ្នកប្រព្រឹត្តអំពើឧក្រិដ្ឋកម្មទាំងអស់នោះ ។

◆ឧទាហរណ៍ខ្លួនខ្ញុំផ្ទាល់ ខ្ញុំគឺជាបញ្ញវន្ត ។ ខ្ញុំសិក្សានៅទីក្រុងប៉ារីស ។ ខ្ញុំបានសិក្សាជាពិសេសនៅស័រប៊ន ទីក្រុងប៉ារីស» ។



អ្នកទោសទួលស្លែង

◆ដូច្នេះវាមិនមែនជាការពិតឡើយដែលថាយើងបានចាត់តាំងគោលការណ៍ដើម្បីសម្លាប់បញ្ញវន្ត ពីព្រោះយើងចង់បានបញ្ញវន្ត យើងត្រូវការបញ្ញវន្ត ព្រោះបញ្ញវន្តអាចជួយយើងកសាងប្រទេសឲ្យបានឆាប់រហ័ស ។

◆ហើយសូម្បីតែយួនក៏បាននិយាយថាយើងសម្លាប់អ្នកទាំងឡាយណាដែលពាក់វ៉ែនតាម្ល៉ឹបពាក់វ៉ែនតា ព្រោះអ្នកពាក់វ៉ែនតាគឺត្រូវបានចាត់ទុកថាជាបញ្ញវន្ត ។ ប៉ុន្តែអស់លោកឃើញទេថាខ្លួនខ្ញុំផ្ទាល់ ក៏ពាក់វ៉ែនតាដែរ» ។

◆◆◆

បទសម្ភាសន៍ជាមួយសមមិត្ត អៀង សារី ដកស្រង់ពីភាពយន្តឯកសារដែលមានចំណងជើងថា «អង្គការ» មានដូចតទៅៈ

◆នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានតែងតាំងជាឧប-នាយករដ្ឋមន្ត្រី ។ ខ្ញុំទទួលខុសត្រូវចំពោះនយោបាយការបរទេស ។ ហើយសព្វថ្ងៃនៅក្រោម ខៀវ សំផន ខ្ញុំជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស ។

◆ខ្ញុំបានអានប្រ-យោគនេះនៅឯអង្គការសហប្រជាជាតិដូចជាអ្នកការទូតផ្សេងៗទៀតដែរ ។ អ្នកការទូតទាំងនោះនិយាយថា វាជារឿងកំប្លែងមួយមិនគួរឲ្យចង់មើលសោះ ។

◆យើងត្រូវបានធ្វើឲ្យជឿជាក់ថារដ្ឋាភិបាលចិនតែងតែជួយជ្រោមជ្រែងយើងក្នុងការតស៊ូដើម្បីទាមទារឯករាជ្យ និងការការពារជាតិលុះត្រាដល់ថ្ងៃជ័យជម្នះ ។

◆យើងមិនបានដឹងអំពីជីវិតរបស់ប្រជាជនតូចតាចឡើយ ពោលគឺមនុស្សឃាតអាចកើតឡើងតាមផ្លូវនេះ ។ ប៉ុន្តែឃាតករគឺពួកយួន ។ វាច្បាស់ដូចថ្ងៃអីចឹង ។

◆យើងផ្អែកសេចក្តីសង្ឃឹមទៅលើរដ្ឋាភិបាលរបស់លោក រីហ្គែន ថារដ្ឋាភិបាលនេះនឹងអនុវត្តនូវសេចក្តីប្រកាសរបស់ខ្លួនដើម្បីអនុវត្តដាច់ខាតចំពោះរឿងទាក់ទងនឹងសហភាពសូវៀត ហើយនឹងចរចាតែពីបញ្ហាកម្លាំងប៉ុណ្ណោះ ។ ការនេះនឹងជួយយើងយ៉ាងច្រើន ។

◆មុនដំបូងមានពួកឈ្លានពាន និងពួកវាតទីនិយមដឹកនាំដោយសហភាពសូវៀត ហើយបន្ទាប់មកទៀតគឺមានចលនាតស៊ូដើម្បីឯករាជ្យ និងសេរីភាពប្រឆាំងនឹងពួកវាតទីនិយមទាំងនេះ ។ វាជាការល្អដែលសហរដ្ឋអាមេរិកនិងប្រទេសចិនបានយល់ស្របគ្នា ។ ហើយយើងក៏ស្ថិតនៅក្នុងក្រុមនេះដែរ ។



គណប្រតិភូមកពីប្រទេសស៊ុយអែដធ្វើទស្សនកិច្ចរបបកម្ពុជាប្រជាធិបតេយ្យ

◆◆◆

# ប្រវត្តិរូប ថុន ប្រាសិទ្ធ

## (កត់ត្រាតាមសំណេរដើមទាំងស្រុង)

**(តពីលេខមុន)** នៅពេលនោះព្រឹត្តិការណ៍សេរីរីលេចមក (ឆ្នាំ១៩៥៨-១៩៦០) ក៏ខ្ញុំមិនឃើញច្បាស់ ហើយគ្មានជំហរច្បាស់លាស់អំពីព្រឹត្តិការណ៍នេះទេ ។ ពេលនោះខ្ញុំគោរពតាមការណែនាំរបស់បក្សឲ្យគិតបញ្ហាជាតិមុនគេ យកបញ្ហាកម្ពុជាជាធំ ធ្វើបដិវត្តន៍កម្ពុជាឈរលើផលប្រយោជន៍ជាតិធំជាងគេ ។

**V. ពីឆ្នាំ១៩៦៣ (ខែ៦) ដល់ឆ្នាំ១៩៧០ (ខែ៣)**

១) ខ្ញុំបានមកដល់ប្រទេសបារាំងដោយពាំនាំពត៌មានពីបក្សអំពីសភាពការណ៍ក្នុងប្រទេសមកឲ្យមិត្តនិស្សិតនៅប្រទេសបារាំង ហើយប្រកាន់គោលជំហរដែលបក្សបានណែនាំអំពីបញ្ហាទំនាស់រវាងសេរីរីនិងចិន គឺរវាងសេរីរីនិងបដិវត្តន៍ ។ ទស្សនៈគោលជំហរបក្សនេះបាននាំឲ្យដោះស្រាយបញ្ហាមួយចំនួនក្នុងចំណោមនិស្សិតដែលកំពុងតែច្របូកច្របល់ ។

២) ក្នុងរយៈពេលជិត៧ឆ្នាំនេះ សកម្មភាពនយោបាយខ្ញុំនៅតែក្នុងក្របខ័ណ្ឌនិស្សិត «សហភាពនិស្សិតខ្មែរ» និងជនកម្ពុជាខ្លះ ។ ខ្ញុំបានទាក់ទងឡើងវិញមិត្តបារាំងដែលរៀនសូត្រជាមួយគ្នា ។ ឯអា ម៉ារេ ដែលបានស្គាល់នៅភ្នំពេញនោះក៏វាមកទាក់ទងដែរ តែមិនបានជាប់លាប់ទេ ព្រោះវានៅឆ្ងាយពីយើងខ្ញុំ ។ ក្រោយពីរដ្ឋប្រហារខែ៣ ឆ្នាំ១៩៧០មក វាការពារច្បាស់លាស់អាក្បត់ លន់ ណុល ។ ខ្ញុំបានផ្ដាច់ការទាក់ទងជាមួយវាតាំងពីដើមឆ្នាំ១៩៧១មក ។ ឯបរទេសឯទៀតខ្ញុំមិនបានទាក់ទង ឬចូលរួមសកម្មភាពអីទេ ។ ទោះតែវៀតណាមដែលមិត្តនិស្សិតយើងទាក់ទងនៅប៉ារីស ក៏ខ្ញុំមិនស្គាល់គេដែរ ។ បក្សកុម្មុយនិស្តបារាំងក៏ខ្ញុំមិនបានទាក់ទងឡើងវិញដែរ ។ ៩០ ភាគរយ នៃពេលវេលាខ្ញុំគឺចំណាយទៅរកចិញ្ចឹមខ្លួនឯង ចិញ្ចឹមគ្រួសារ ហើយព្រួយបារម្ភអត់ការធ្វើ ។

៣) ជាទស្សនៈខ្ញុំមកនៅឯប្រទេសបារាំងមួយរយៈពេលត្រៀមខ្លួនថ្ងៃណាមួយបក្សហៅត្រឡប់ទៅវិញ ។ ក្នុងការត្រៀមនេះក៏ខ្ញុំចូលរួមសកម្មភាពខ្លះជាមួយមិត្តនិស្សិតក្នុងសហភាពនិស្សិតខ្មែរ ហើយខំអប់រំនិស្សិតខ្លះថែមទៀតតាមសមត្ថភាពរបស់ខ្លួន ។ ក្នុងរយៈ៧ឆ្នាំកន្លះនេះ ដាច់ខ្សែទាក់ទងជាមួយបក្សទាំងស្រុង ។

៤) ក្នុងរយៈពេលរស់នៅឯប្រទេសបារាំងនេះ ខ្ញុំបានទទួលលុយពីម្ដាយខ្ញុំខ្លះ ពិសេសនៅឆ្នាំ១៩៦៨ ខ្ញុំបានទទួល ៥០ពាន់ត្រណោត ។

៥) ពីឆ្នាំ១៩៦៥ ដល់ ១៩៦៨ ខ្ញុំធ្វើការក្នុងក្រុមហ៊ុនលក់ឥន្ធនៈ (ធ្យូងនិងប្រេង) ។ នៅឆ្នាំ១៩៦៨ ខ្ញុំបានចូលធ្វើការក្នុង «អាកាសយានដ្ឋានប៉ារីស» ។

៦) ក្នុងរយៈពេលរស់នៅក្នុងប្រទេសបារាំង ខ្ញុំបានទទួលឥទ្ធិពលនាយទុនបារាំងជាច្រើន ទាំងរបៀបរស់នៅទាំងទស្សនៈគោលជំហរ ។ ពិតមែនតែត្រៀមខ្លួនថ្ងៃណាមួយបក្សហៅប្រគល់ភារកិច្ចអ្វីមួយ ហើយតាមដានសភាពការណ៍ក្នុងប្រទេសជាប់តែទស្សនៈគោលជំហរបដិវត្តន៍ត្រូវបន្ទរាបជាច្រើន ។ ទស្សនៈគោលជំហរបដិវត្តន៍ស្រពេចស្រពិលឈានទៅសម្ងំសុខយករួចខ្លួន ។ គិតគូរធំឲ្យគ្រួសារកូនស្រួល មិនបានអប់រំគេឲ្យគេភ្ញាក់រឭកមកជិតជាតិកម្ពុជា ។ សម្ភារគ្របដណ្ដប់ខ្លាំង ។ ពេលនោះមិនចាប់អារម្មណ៍ថានេះជាទស្សនៈសេរីរីទេ ។ ក្រោយពីបានរៀនសូត្រក្រោយរដ្ឋប្រហារបានយល់ថា នេះជាទស្សនៈគោលជំហរសេរីរី ។ ជាក់ស្ដែងបើគ្មានរដ្ឋប្រហារ ហើយបើបក្សមិនបានហៅខ្ញុំឲ្យទៅប្រតិបត្តិការនៅប៉េកាំងក្រោយរដ្ឋប្រហារនេះមើលទៅខ្ញុំស្ដារខ្លួនមិនរួចទេ ។ គឺមើលទៅនៅឯប្រទេសបារាំងរហូតបន្តបម្រើនាយទុនបារាំងតទៅទៀតដោយបាត់ព្រលឹងជាតិទាំងស្រុង ។ បក្សបានស្ដារខ្ញុំពីផ្លូវខុស ពុករលួយ ហើយអប់រំឲ្យមកដើរផ្លូវថ្លៃថ្នូរវិញ ។ ផ្លូវនេះស្មុគស្មាញ ដោយត្រូវលះបង់ច្រើន តែផ្លូវនេះក៏មានន័យនិងកិត្តិយសស្អាតស្អំ ។

៧) ដោយខ្ញុំត្រៀមជាប់ថ្ងៃណាមួយបក្សហៅទៅវិញ ហើយឃើញថាបដិវត្តន៍ទាមទារឲ្យបែកពីគ្រួសារមួយរយៈពេល ខ្ញុំក៏បានចាត់គ្រប់វិធានការឲ្យគ្រួសារខ្ញុំឯករាជ្យម្ចាស់ការទាំងក្នុងការរកចិញ្ចឹមខ្លួន ទាំងការរស់នៅ ។ ហេតុនេះហើយបានលុយនៅធនាគារប៉ុន្មានបានដាក់ក្នុងឈ្មោះគាត់ ឬឈ្មោះពីរនាក់ ។ ដោយទស្សនៈនាយទុនចូលខ្លាំង ខ្ញុំក៏បានយល់ថា សន្សំទិញផ្ទះមួយដោយសងជាប្រាក់ខែ (គឺទិញជឿ) ចំណេញជាង និងថោក

ដាច់ជួល ។ នៅឆ្នាំ១៩៦៥ក៏បានធ្វើដូច្នេះ ។ ដល់ឆ្នាំ១៩៦៩ ដោយផ្ទះនេះនៅឆ្ងាយ ម្យ៉ាងទៀតដោយបានទទួលលុយមួយចំនួនពីម្ដាយខ្ញុំ ហើយបានចូលធ្វើការក្នុង «អាកាសយានដ្ឋានប៉ារីស» ជានីងនរ ខ្ញុំបានសម្រេចដូរផ្ទះដោយខ្ចីលុយ «អាកាសយានដ្ឋានប៉ារីស» បណ្ដោះអាសន្ន ចាំពេលលក់ផ្ទះចាស់បាន ។ សកម្មភាពទាំងអស់នេះបង្ហាញថា ខ្ញុំបានលង់ក្នុងសង្គមនាយទុន ។ ការស្មុគស្មាញនេះព្រមទាំងបទបញ្ញារបស់ «អាកាសយានដ្ឋានប៉ារីស» ទាមទារឲ្យប្រាប់៣ខែមុននឹងសុំឈប់ធ្វើការ នាំឲ្យខ្ញុំអនុវត្តន៍ការណែនាំរបស់បក្សឲ្យមកប៉េកាំងយឺត៣ខែ ។ ខ្ញុំបានទុកការនេះជាការខុះខាតមួយធំ ហើយនៅសោកស្ដាយរហូតសព្វថ្ងៃ ។

៨) សភាពការណ៍កម្មសិទ្ធិសម្ភារសព្វថ្ងៃមានដូចតទៅ៖

**អំពីផ្ទះ** តាំងពីឆ្នាំ១៩៧០ ខ្ញុំបានអនុញ្ញាតមុខសារការី (notaire) ឲ្យគ្រួសារខ្ញុំនៅរហូតដល់គាត់ស្លាប់ ។ សុំបញ្ជាក់ថាផ្ទះនេះទិញដោយបានចូលរួមទុនគ្នារវាងគ្រួសារខ្ញុំនិងខ្ញុំ ។ គាត់មានរវាង១ភាគ៣ ។

**អំពីលុយនៅធនាគារៈ** ដោយគណនីនៅធនាគារដាក់ឈ្មោះប្រពន្ធខ្ញុំ ហើយដោយខ្ញុំដាច់ជាង៦ឆ្នាំមកហើយ ខ្ញុំមិនដឹងសភាពការណ៍យ៉ាងណាទេ ។ មានគណនីមួយឈ្មោះខ្ញុំដែលបើកអនុញ្ញាតឲ្យប្រពន្ធខ្ញុំដកនិងដាក់លុយបាន ។ ខ្ញុំតាមពត៌មានពីខែ៥មុននេះនៅសល់ប្រហែល២៧០០ត្រណោត ។ តែឥឡូវខ្ញុំមិនដឹងសភាពការណ៍នេះដល់ណាទេ ។ តើគាត់ដកអស់ហើយ ឬគាត់ដាក់បន្ថែមខ្ញុំមិនដឹងទេ ។

បញ្ហាទាំងអស់នាំឲ្យខ្ញុំមានសតិអារម្មណ៍ស្មុគស្មាញម្ដងៗដែរ ។ ខ្ញុំរកវិធីដោះស្រាយឲ្យបានជ្រះស្រឡះមិនទាន់ឃើញ ។ ព្រោះលក់ផ្ទះបានលុះត្រាតែយើងលែងលះគ្នា ។ ការលែងលះគ្នានេះតាមច្បាប់បារាំងជាការយូរបើទាំងសងខាងយល់ព្រម ។ តែបើម្ខាងមិនយល់ព្រមទេគឺលែងលះមិនបាន ។ ការដាក់ស្ដែងគឺមានតែ២លទ្ធភាពគឺឬគ្រួសារមករស់នៅឯកម្ពុជា ឬលែងលះគ្នាឲ្យជ្រះស្រឡះ ។

នៅពេលសមាជិករណសិរ្សខ្លះគេប្រគល់ផ្ទះគេនៅប៉ារីសឲ្យមកបក្ស ខ្ញុំមានសេចក្ដីអៀនខ្មាស់ខ្លាំងតែមិនដឹងដោះស្រាយយ៉ាងណា ។ ក្នុងបញ្ហានេះ ខ្ញុំស្ថិតក្នុងសភាពទ័លច្រកមួយសព្វថ្ងៃនេះ ។

**អំពីគ្រួសារខ្ញុំៈ** គាត់ធ្វើការនៅឃុំអ័រស៊ី ។ មេឃុំជាជនកុម្មុយនិស្ដ ។ តែតាមខ្ញុំដឹងគាត់រកការធ្វើ ២ឬ៣កន្លែង ព្រោះការងារគាត់ជាអ្នកទីប្រឹក្សាខាងផែនការគ្រួសារ (Conseillere planning familiale) ។ ខ្ញុំមិនដឹងគាត់បានប្រាក់ខែប៉ុន្មានទេ ។ តាមខ្ញុំស្មានគាត់ទប់ទល់បានខ្លះ ។ គាត់បានចូលបក្សបារាំងពីឆ្នាំ ១៩៧០ តែគាត់មិនយល់ស្របតាមបក្សបារាំងច្រើន ។ ជារួមគាត់ជាអ្នកចង់ចំរើន តែចង់ស្រួល សម្ញុំសុខ មិនជាអ្នកនយោបាយទេ ។

## VI. *ពីឆ្នាំ១៩៧០ ខែមីនា រហូតឆ្នាំ១៩៧៥ ខែធ្នូ*

គឺរយៈកាលខ្ញុំបានចូលបម្រើបដិវត្តន៍វិញយ៉ាងសកម្មក្នុងរណសិរ្សក្រោមការដឹកនាំរបស់បក្ស រហូតខ្ញុំបានចូលក្នុងប្រទេសវិញ ។ (ខ្ញុំបានត្រឡប់មកប្រទេសនៅខែសីហាម្ដង តែបានតែ២ថ្ងៃ) ។

ខ្ញុំបានមកដល់ប៉េកាំងថ្ងៃ ៨ កក្កដា ១៩៧០ ឆ្លងតាមទីក្រុងម៉ូស្គូ ។ ពេលនោះគេមិនសូវជិះយន្ដហោះបារាំងទេពីព្រោះវាហោះកាត់ប្រទេសថៃ ។ ក្នុងរយៈពេលជាង៥ឆ្នាំនេះសូមបញ្ជាក់សកម្មភាពទស្សនៈ និងគោលជំហររបស់ខ្ញុំអំពីបញ្ហាមួយចំនួន ។

**១) *ការងារបក្សៈ***

ខ្ញុំមកប៉េកាំងដើម្បីអនុវត្តការណែនាំរបស់បក្ស ។ ដោយមិនបានមកភ្លាមតាមហេតុផលដែលខ្ញុំបានជម្រាបខាងលើនេះ ហើយខ្ញុំក៏សម្រេចជាមួយមិត្តយើងនៅប្រទេសបារាំងពេលនោះឲ្យបងខ្ញុំ សមមិត្ត ជួន មុម មកមុន ។ ទិសដៅជាបឋមរបស់ខ្ញុំមកដល់ប៉េកាំងគឺទាក់ទងជាមួយបក្ស រាយការណ៍ជូនបក្ស ហើយអនុវត្តតាមការណែនាំរបស់បក្ស ។ នេះរហូតដល់ខែកុម្ភៈឆ្នាំ១៩៧១ គឺពេលដែលខ្ញុំបានជួបបក្សឡើងវិញនៅហាណូយ ។ ក្នុងរយៈកាលមុនដំបូងដោយដាច់ពីការអប់រំរបស់បក្ស ដោយឥទ្ធិពលនាយទុនបារាំង ទស្សនៈគោលជំហរបដិវត្តន៍ទន់ខ្សោយ... ខ្ញុំមានការលំបាកច្រើនក្នុងការអនុវត្តមាគ៌ារបស់បក្ស ។ តែដោយមានការអប់រំណែនាំជាប់ពីបក្ស ការលះបង់ជាបណ្ដើរៗនូវកម្មសិទ្ធិបុគ្គលនិងកម្មសិទ្ធិឯកជនដទៃទៀត ខ្ញុំបានភ្ជាប់ខ្លួននឹងបក្សនិងបដិវត្តន៍បានឡើងវិញ ។ ជាបន្ដបន្ទាប់ បក្សក៏មានការទុកចិត្តមកលើខ្លួនខ្ញុំ ។ ជារួមកត្តាទាំងអស់នាំឲ្យខ្ញុំយកជារួម

ជ័យជម្នះបានក្នុងការបំពេញភារកិច្ចបក្សប្រគល់ឲ្យ ។ ជាមួយនេះក៏បានចាប់យល់ និងក្ដាប់ធាតុជនកុម្មុយនិស្ដដោយកសាងខ្លួនបានមួយកម្រិត ខ្ញុំបានមកចូលក្នុងចលនាបដិវត្តន៍ឡើងវិញ នាំឲ្យជីវិតខ្លួនខ្ញុំមានន័យឡើងវិញ មានខ្លឹមសារឡើងវិញ ។

## ២) *ការងាររណសិរ្ស*

ខ្ញុំមកដល់ប៉េកាំងភ្លាម ប៉ែន នុត និង សីហនុ បានចាត់តាំងភ្លាមជារដ្ឋមន្ត្រីទទួលបន្ទុកក្នុងការទាក់ទងជាមួយក្នុងប្រទេស ។ ពេលនោះសមមិត្ត គាត ឈន់ ក៏ត្រូវចាត់តាំងជារដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី ។ ការចាត់តាំងនេះមិនមែនមកពីខ្ញុំសុំឬស្នើទេ ។ គឺ ប៉ែន នុត និង សីហនុ ចង់ប្រមូលកម្លាំងមកគេ ហើយពេលនោះគេមិនទាន់ដឹងការទាក់ទងផ្ទៃក្នុងបក្សយើងទេ គេក៏មិនដឹងខ្ញុំច្បាស់ជាស្អីដែរ ។ គេឃើញខ្ញុំមានវណ្ណៈដូចគេ ។ នៅពេលនោះទិសដៅខ្ញុំធំជាងគេគឺឲ្យតែបានប្រាក់ខែដើម្បីចិញ្ចឹមគ្រួសារនៅប្រទេសបារាំង ។ ឯនាទី មុខមាត់ បុណ្យសក្ដិមិនជាសំខាន់ទេ ។

ពួករណសិរ្សថ្នាក់លើទាំងអស់មិនសប្បាយចិត្តអំពីការតែងតាំងនេះ ។ ពួកនេះចោទប្រកាន់ខ្លួនខ្ញុំខ្លាំង ព្រោះគេឃើញថាខ្ញុំប្រឆាំងផលប្រយោជន៍វណ្ណៈគេ ក្បត់វណ្ណៈគេ ទប់ទល់មិនឲ្យគេដំណើរខបាយកលដណ្ដើមអំណាច ឬមិនឲ្យគេដំណើរខបាយកលចរចាជាមួយចក្រពត្តិ ។ ទប់ទល់មិនឲ្យពួកគេលួចលុយ ។ ពួកគេចោទប្រកាន់ថា ខ្ញុំជាខ្ញុំ (បម្រើ) បារាំង (ដោយគ្រួសារ ខ្ញុំបារាំង) ខ្ញុំសេរីរ ខ្ញុំយួន...។ល ។

តែក្នុងនេះការខ្វះខាតជាអត្តនោម័តិរបស់ខ្ញុំក៏មានច្រើន÷

-ក្ដាប់មាគ៌ានយោបាយរណសិរ្សនិងមាគ៌ាសកម្មភាពរបស់បក្សមិនណែន គឺនាំឲ្យមានការបង្វៀតបង្ខូលមិនសាមគ្គីទូលំទូលាយ ។

-ចរិតជាបរទេស(បារាំង) នៅច្រើន មិនសូវទន់ភ្លន់ ផ្ញើលុយឲ្យគ្រួសារ...

ការខ្វះខាតទាំងនេះមកពីសំណល់វណ្ណៈដើមជាវណ្ណៈជិះជាន់គេ ។ តែការពិតគឺការតស៊ូវណ្ណៈក្នុងជួររណសិរ្សថ្នាក់លើនេះស្រួចស្រាល់ណាស់ ។ ពួកវណ្ណៈជិះជាន់វាយប្រហារបក្សហើយវាវាយនេះតាមរយៈខ្លួនខ្ញុំ ។ ដោយខ្ញុំទាក់ទងក្នុងប្រទេសគេខ្លាច តែគេមិនសឡាញ់ទេ ។ គេវាយចំណុចខ្សោយខ្ញុំ ។

ចំណុចខ្សោយនេះធ្វើឲ្យខ្ញុំតំណាងបក្សមិនបានគ្រប់លក្ខណៈ ។ នេះជាការឈឺចាប់របស់ខ្ញុំមួយក្នុងរយៈធ្វើការក្នុងរណសិរ្ស ។

**(នៅមានត)**



ជូន ប្រាសិទ្ធ

# ភោគ ឆាយ មុនពេលក្លាយជាអ្នកទោសរបស់ខ្មែរក្រហម

ភោគ ឆាយ ឈ្មោះបដិវត្តន៍ ទូច ភេទប្រុស កើតនៅឆ្នាំ១៩៣៦ នៅភូមិស្វាយព្រៃ ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ជាអ្នកទោសរបស់ខ្មែរក្រហមដែលត្រូវឃុំឃាំងនៅគុកទួលស្លែង ។ មានឪពុកឈ្មោះ ហ៊ូ ជូ ម្តាយឈ្មោះ នាង ហួន ឪពុកចុងឈ្មោះ ភោគ សុង ។ ភោគ ឆាយ គឺជាបុគ្គលមួយរូបដែលធ្លាប់មានទំនាក់ទំនងជាមួយមនុស្សសំខាន់ៗមួយចំនួនក្នុងជួរខ្មែរក្រហមដូចជា ហ៊ូ យន់, ហ៊ូ នឹម ជាដើម ។ល ។ យោងឯកសារលេខ J០០៨៨៦ ភោគ ឆាយ ធ្លាប់ត្រូវបាន «រដ្ឋាភិបាល» ស្តេចសីហនុ ចាប់ដាក់គុកនៅឆ្នាំ១៩៦៧ ជាមួយខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ដោយមូលហេតុទំនាស់អំពីការតាំងពិពណ៌វត្ថុសិល្បៈចិន ។

ឯកសារចម្លើយសារភាពរបស់ ភោគ ឆាយ នៅក្នុងគុកទួលស្លែងត្រូវបានសរសេរចំនួន៣ដង បញ្ជាក់ថា ភោគ ឆាយ ត្រូវបានសួរចម្លើយចំនួន៣លើក ។ ចម្លើយសារភាពលើកទី១ ចុះថ្ងៃទី២០ ខែ៣ ឆ្នាំ១៩៧៧, លើកទី២ចុះថ្ងៃទី២៤ និង ២៦ ខែ៣ ឆ្នាំ១៩៧៧ និងលើកទី៣ចុះថ្ងៃទី៣១ ខែ៣ ឆ្នាំ១៩៧៧ សរុបទាំង៣ច្បាប់មានចំនួន៨១សន្លឹក ។ ចម្លើយសារភាពទាំងបីច្បាប់នេះមានចំណុចខ្លះដូចគ្នា ហើយក៏មានចំណុចខ្លះខុសគ្នា ប៉ុន្តែទាំងបីច្បាប់សុទ្ធតែមានលក្ខណៈមិនចប់ចុងចប់ដើម ពោលគឺមជ្ឈមណ្ឌលឯកសារកម្ពុជាមានតែផ្នែកខាងមុខនៃឯកសារចម្លើយសារភាពទាំង៣ច្បាប់នេះ ឯផ្នែកខាងចុងដែលបាត់យើងពុំទាន់រកឃើញនៅឡើយ ។

ខាងក្រោមនេះជាសេចក្តីសង្ខេបសកម្មភាពរបស់ ភោគ ឆាយ ហៅ ទូច តាមចម្លើយសារភាពទាំង៣លើករបស់គាត់÷

កាលពីឆ្នាំ១៩៥០ ភោគ ឆាយ ទើបតែមានអាយុបាន១៣ឆ្នាំ ត្រូវបានបណ្តេញចេញពីសាលាតាកែវជាមួយនឹងសិស្ស២០នាក់ទៀត ដោយមូលហេតុបានចូលរួមធ្វើបាតុកម្មមួយប្រឆាំងនឹងចៅហ្វាយខេត្តតាកែវឈ្មោះ ជា ជិនគុក និងចាងហ្វាងសាលាឈ្មោះ ចាន់ ក្រោមការដឹកនាំរបស់ ព្រំ ចៅស៊ូ និង ឈូក ម៉ឹងម៉ៅ (ឈូក ម៉េងម៉ៅ) ដែលគាំទ្រ សឺង ង៉ុកថាន់ (ស៊ឺង ង៉ុកថាញ់?) ។ ឈប់ពីសាលាតាកែវ ភោគ ឆាយ បានប្រឡងជាប់អាហារូបករណ៍រៀននៅអនុវិទ្យាល័យព្រះរាជសម្ភារ ខេត្តកំពតនៅឆ្នាំ១៩៥២ ។ ឆ្នាំ១៩៥៦ ភោគ ឆាយ (អាយុ១៩ឆ្នាំ) រៀនចប់អនុវិទ្យាល័យហើយមកប្រឡងជាប់រៀនបន្តនៅសាលាដេកាតជាសាលារបស់បារាំងនៅភ្នំពេញដោយស្នាក់នៅវត្តប្រយូរវង្ស ។

ឆ្នាំ១៩៥៩ ភោគ ឆាយ (អាយុ២២ឆ្នាំ) ប្រលងជាប់រៀននៅមហាវិទ្យាល័យច្បាប់ ។ ចាប់ពីឆ្នាំ១៩៦០ គាត់ឆ្លៀតបង្រៀនតាមសាលាឈ្នួលមួយចំនួនដូចជា សាលាចតុម្មុខ, ខេមរា, ចំរើនវិជ្ជា និងសាលាប្រសើរសិក្សា ដើម្បីយកកម្រៃសម្រាប់ផ្គត់ផ្គង់ការចាយវាយផ្ទាល់ខ្លួន និងផ្ញើខ្លះទៅឲ្យម្តាយនៅឯខេត្តតាកែវ ។

នៅសាលាច្បាប់ ភោគ ឆាយ ក៏បានស្គាល់ឈ្មោះ សារិន ឆាក (សារិន ឆាក់) ធ្វើការនៅក្រសួងការបរទេសរៀននៅសាលាច្បាប់ដែរ ។ សារិន ឆាក ធ្លាប់បើកសមាគមនិស្សិតសាលាច្បាប់នៅឆ្នាំ១៩៦១-៦២ ហើយ ភោគ ឆាយ ក៏បានចូលរួមដោយទទួលខុសត្រូវខាងផ្នែកបោះពុម្ពផ្សាយទស្សនាវដ្តី ។

នៅក្នុងក្របខ័ណ្ឌសាលាច្បាប់នេះដែរ ភោគ ឆាយ បានទាក់ទងនិងយកចិត្តយកថ្លើមមនុស្សពីរនាក់ទៀត ទីមួយគឺ ហ៊ូ យន់ ជាគ្រូបង្រៀនរបស់គាត់ផ្នែកសេដ្ឋកិច្ច ។ ហ៊ូ យន់ តែងតែហៅ ភោគ ឆាយ ទៅចូលរួមក្នុងអង្គប្រជុំដែលនិយាយអំពីបញ្ហានយោបាយ ធ្វើឲ្យ ភោគ ឆាយ ចូលចិត្តនយោបាយបន្តិចម្តងៗ ហើយគោរពនិងស្តាប់បង្គាប់ ហ៊ូ យន់ ជារៀងរហូត ។ បុគ្គលទីពីរដែល ភោគ ឆាយ គោរពនិងជឿជាក់គឺ អ៊ុច វ៉ែន ជាប្រធានសមាគមចំរើនវិជ្ជាផង ជាលេខាធិការបណ្ណាល័យសាលាច្បាប់ផង និងជាចាងហ្វាងរងខាងកាសែតបារាំងឈ្មោះ «ឡាដេប៉ែស»ផង ។ តាមរយៈ អ៊ុច វ៉ែន, ភោគ ឆាយ បានស្គាល់ជិតស្និទ្ធជាមួយ ចៅ សេង ចាងហ្វាងកាសែត «ឡាដេប៉ែស»

និងបានចូលសរសេរអត្ថបទឲ្យកាសែត «ឡាដេប៉ែស» នៅឆ្នាំ ១៩៦១-៦២ ។

នៅក្នុងក្រុមកាសែត «ឡាដេប៉ែស» ភោគ ឆាយ ស្គាល់មនុស្សមួយចំនួនទៀតគឺ ប៉ុក ដឺកុមារ (ប៉ុក ដឺសកុមារ), រស់ ជេដ្ឋរ និង សូ ណៃម ។ អ្នកទាំងពីរធ្វើការនៅក្រសួងការបរទេស ។ ក្រៅពីនេះនៅបានស្គាល់ ហ៊ូ នឹម និង គ្រូយួន តាមរយៈការជួបគ្នាក្នុងអង្គប្រជុំមួយ ។

ខែ៤ ឆ្នាំ១៩៦៣ ភោគ ឆាយ (អាយុ២៥ឆ្នាំ) ប្រលងចេញពីសាលាច្បាប់ ហើយចូលធ្វើការនៅក្រសួងការបរទេសដោយមានឈ្មោះ សារិន ឆាក អគ្គលេខាក្រសួងជាអ្នកជួយទំនុកបម្រុង ។ ថ្ងៃ២៨ ខែ៧ ឆ្នាំ១៩៦៣ ភោគ ឆាយ រៀបការប្រពន្ធនៅឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ភរិយារបស់គាត់ឈ្មោះ សៀ គឹម ។

ខែ១១ ឆ្នាំ១៩៦៣ សម្តេច សីហនុ បានប្រកាសធ្វើជាតូបនីយកម្មទាំងមុខរបរធនាគារ ទាំងមុខរបរពាណិជ្ជកម្មក្រៅប្រទេស ។ នាយទុនជាច្រើនដូចជា សុង សាក់, ង៉ុយ កាន់ ជាដើម បាននាំគ្នារត់ទៅបរទេស ។

ដោយធុញទ្រាន់នឹងការងារនៅក្រសួងការបរទេស នៅចុងខែ១២ ឆ្នាំ១៩៦៣ ភោគ ឆាយ លាឈប់ពីក្រសួងការបរទេស ។ នៅខែ២ ឆ្នាំ១៩៦៤ គាត់មកធ្វើការនៅធនាគារឥណទានជាតិជាមួយ អ៊ុច វ៉ែន និង ប៉ុក ដឺកុមារ ទទួលនាទីជានាយកផ្នែកឥណទាន ។ នៅធនាគារនេះ ភោគ ឆាយ បានស្គាល់ជិតដិតជាមួយឈ្មួញម្នាក់ដែលខស្សាហ៍ចេញចូលធនាគារផ្ញើនិងដកប្រាក់ឈ្មោះ វ៉ាន់ ទិព្វសុវណ្ណ ហើយតាមរយៈ វ៉ាន់ ទិព្វសុវណ្ណ នេះ ភោគ ឆាយ បានស្គាល់ឈ្មួញម្នាក់ទៀតឈ្មោះ គី សៀនហូ (នៅក្នុងឯកសារចម្លើយសារភាពលើកទីបី ភោគ ឆាយ និយាយថាគាត់បានស្គាល់ គី សៀនហូ និង វ៉ាន់ទិព្វសុវណ្ណ តាមរយៈនាយទុនម្នាក់ឈ្មោះ ង៉ុយ ថាន់ ជាកូនរបស់ ង៉ុយ កាន់ ត្រូវជាបងប្អូនជីដូនមួយខាងម្តាយគាត់) ។ ជារឿយៗ វ៉ាន់ ទិព្វសុវណ្ណ អញ្ជើញ ភោគ ឆាយ ទៅហូបបាយផ្សារ និងចូលចិត្តនិយាយពីប្រវត្តិតស៊ូនៅខេត្តបាត់ដំបង កាលពីសម័យបារាំងឲ្យ ភោគ ឆាយ ស្តាប់ថែមទៀត ។

ចុងឆ្នាំ១៩៦៤ នៅក្រុងភ្នំពេញមានលេចព្រុសឺបរសៀវនៅគ្រប់មជ្ឈដ្ឋានបញ្ញាជនថា មានចលនាបង្កើតបដិវត្តន៍ថ្មីដែលមានអង្គការ «សេ-អ៊ី-អា» ជាអ្នកផ្តួចផ្តើម ។ ភោគ ឆាយ បានចូលប្រឡូកក្នុងអង្គប្រជុំពិភាក្សាអំពីការបង្កើតបក្សថ្មីនេះយ៉ាងពេញទំហឹង ។ ដំបូងបង្អស់គឺក្នុងរវាងដើមខែ៣ ឆ្នាំ១៩៦៤ ហ៊ូ នឹម បាននិយាយជាមួយ ប៉ុក ដឺកុមារ និង ភោគ ឆាយ អំពីគំនិតចង់បង្កើតបក្សថ្មីមួយទៀតដោយមានគាត់ធ្វើជាប្រមុខ ហើយមាន ប៉ុក ដឺកុមារ និង ភោគ ឆាយ ជាសហការី(ចម្លើយសារភាពលើកទីពីរនិយាយថាខែ១០ ។ ចម្លើយសារភាពលើកទីបីអត់មាននិយាយពីបញ្ហានេះទេ) ។ នេះជាលើកទីមួយដែល ភោគ ឆាយ បានឮអំពីបក្សកម្ពុជា ។ តាមរយៈសម្តី ហ៊ូ នឹម, ភោគ ឆាយ បានដឹងថាមានបក្សកម្ពុជាហើយ តែ ហ៊ូ នឹម ក៏ចង់បង្កើតបក្សមួយទៀតដែរ ។

យប់ថ្ងៃទី២៥ ខែ៦ ឆ្នាំ១៩៦៤ ភោគ ឆាយ បានទៅចូលរួមប្រជុំនៅផ្ទះទឹកនៅជ្រោយអំពិល អ្នកដែលទៅចូលរួមប្រជុំមាន ហ៊ូ យន់, ហ៊ូ នឹម, វ៉ាន់ ទិព្វសុវណ្ណ, ប៉ុក ដឺកុមារ, ទីវ អុល, គ្រូយួន (ធុច) និងក្រឡាបញ្ជីម្នាក់ ។ អង្គប្រជុំបានកំណត់ដាក់ផែនការយ៉ាងច្បាស់គឺ ទីវ អុល ក្តាប់សមាគមគ្រូនិងសមាគមចំរើនវិជ្ជា ហើយសហការជាមួយសមាគមផ្សេងៗឲ្យបានជិតស្និទ្ធ ។ ប៉ុក ដឺកុមារ ក្តាប់កាសែត «ឡាដេប៉ែស» ខាងទិសនយោបាយ ហើយជំរុញបង្កើតសមាគមអ្នកនិពន្ធកាសែតមួយ ។ ភោគ ឆាយ រួមជាមួយនិស្សិតដទៃទៀតបង្កើតសមាគមនិស្សិតមួយ ។

ថ្ងៃ២២ ខែ១២ ឆ្នាំ១៩៦៤ សមាគមនិស្សិតទូទៅមួយដែលមានឈ្មោះថា «សមាគមទូទៅនៃនិស្សិតខ្មែរនៅកម្ពុជា» ត្រូវបានប្រកាសបង្កើតឡើងដោយមានការរួមសហការរវាង ភោគ ឆាយ, វ៉ាន់ ពីនី និស្សិតសាលាភូមិន្ទរដ្ឋបាល, ទួន សុខផល្លា និង ឈុន សុខនួន និស្សិតសាលាវិស្វករ ។ ភោគ ឆាយ បានជាប់ឈ្មោះជាប្រធានសមាគមនេះ ។ គោលការណ៍ជាចំបងរបស់សមាគមគឺបង្កើតឡើងដើម្បីជួយឧបត្ថម្ភសិស្សនិងនិស្សិតក្រីក្រដែលចង់បន្តការសិក្សានៅភ្នំពេញ ។ សមាគមនេះបានទទួលការគាំទ្រយ៉ាងខ្លាំងពីមជ្ឈដ្ឋានជុំវិញ សូម្បី

តែសម្តេច សីហនុ ក៏ផ្ញើថវិកាចំនួន១សែនរៀលមកជួយដែរ ក្រៅពីនេះនៅមានជំនួយពីអ្នកធំមានមុខមាត់មួយចំនួនទៀត ជាពិសេសគឺ វ៉ាន់ ទិព្វសុវណ្ណ ។

ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៦៤ ភោគ ឆាយ បានចូលរួមក្នុងពិធីជ្រើសរើសគណៈកម្មាធិការនាយកថ្មីរបស់សមាគមកម្ពុជបុត្រ ។ បន្ទាប់ពីអង្គប្រជុំបានបញ្ចប់នៅល្ងាចថ្ងៃនោះ ភោគ ឆាយ បានទៅរួមបាយជាមួយ ហ៊ូ យន់, វ៉ាន់ ទិព្វសុវណ្ណ និង គ្រូយួន និងប្រជុំគ្នាអំពីសភាពការណ៍នយោបាយសកលលោក និងនយោបាយក្នុងប្រទេស ។ នៅទីបំផុត ហ៊ូ យន់ សរុបថា ត្រូវតែមានបក្សមួយច្បាស់លាស់ដោយមានកម្លាំងយុវជននៅតាមសមាគមផ្សេងៗជាកម្លាំងស្នូល ។

ដើមខែ២ ឆ្នាំ១៩៦៥ មានប្រជុំសមាគមមិត្តភាពខ្មែរ-ចិនដើម្បីជ្រើសរើសគណៈកម្មាធិការថ្មី។ ភោគ ឆាយ បានចូលរួមក្នុងពិធីនេះហើយបានជាប់ឆ្នោតជាសមាជិកនៃគណៈកម្មាធិការសមាគមនោះផង ។ ចំណែក វ៉ាន់ ទិព្វសុវណ្ណ បានជាប់ជាស្នងការគណនេយ្យ ។ ចេញពីប្រជុំ វ៉ាន់ ទិព្វសុវណ្ណ សុំជួបពិគ្រោះការងារជាមួយ ភោគ ឆាយ ។ វ៉ាន់ ទិព្វសុវណ្ណ ចាប់ផ្តើមនិយាយអំពីគោលបំណងវាយរំលំរបប សីហនុ និងអំពីអង្គការ «សេ-អ៊ី-អា» ។ គាត់និយាយថា «ខ្ញុំសព្វថ្ងៃស្ថិតនៅក្នុងអង្គការមួយដែលប្តូរផ្តាច់វាយរំលំរបប សីហនុ គឺអង្គការ «សេ-អ៊ី-អា»។ ភោគ ឆាយ ស្រឡាំងកាំងរួចសួរថា «ម៉េចបានជាបង ទៅទាក់ទងនឹង «សេ-អ៊ី-អា» ទៅវិញ តើហេតុផលយ៉ាងម៉េច?» វ៉ាន់ ទិព្វសុវណ្ណ ឆ្លើយថា «សព្វថ្ងៃខ្ញុំពាក់ផ្លាកខ្មែរក្រហមដូចគេដូចឯងដែរ តែអង្គការខ្ញុំជាអង្គការ «សេ-អ៊ី-អា» ។ ខ្ញុំចង់វាយសីហនុឲ្យឈ្នះឆាប់...។» ហើយក្នុងអំឡុងពេលបុណ្យចូលឆ្នាំខ្មែរនាឆ្នាំ១៩៦៥ ភោគ ឆាយ ត្រូវបាន វ៉ាន់ ទិព្វសុវណ្ណ និង គី សៀងហូ ធ្វើពិធីបញ្ចូលជាសមាជិក «សេ-អ៊ី-អា» នៅជើងភ្នំទឹកពុលក្នុងភូមិសាស្ត្រខេត្តបាត់ដំបង ។ ក្នុងពិធីបញ្ចូលនោះមានការផឹកទឹកសម្បថប្តូរស្លាប់រស់ជាមួយគ្នាទៀតផង (ចម្លើយសារភាពលើកទី៣និយាយថាគាត់បានចូល «សេ-អ៊ី-អា» តាំងពីខែ៣ ឆ្នាំ១៩៧/៦៣) ។ ក្នុងរយៈពេលស្នាក់នៅជើងភ្នំទឹកពុល ភោគ ឆាយ បានសួរយោបល់ វ៉ាន់ ទិព្វសុវណ្ណ អំពីរបៀបដឹកនាំនិងគ្រប់គ្រងសមាគមនិស្សិត ។ វ៉ាន់ ទិព្វសុវណ្ណ បានឲ្យយោបល់ថា «យើងត្រូវក្លែងខ្លួនធ្វើជាក្រហម សមាគមក៏ត្រូវមានពណ៌ក្រហម ព្រោះសីហនុកំពុងដើរនយោបាយក្រហម យើងអែបសីហនុផង វាយសីហនុផងដើម្បីយកពេលប្រមូលកម្លាំង ។ ដូច្នេះយើងកុំខ្លាចដេរអាមេរិក ។»


រូបអ្នកទោសគុកទួលស្លែង

ថ្ងៃទី១ ខែសីហា ឆ្នាំ១៩៦៥ ដោយមានការជ្រោមជ្រែង ពី ចៅ សេង ចាងហ្វាងកាសែត «ឡាដេប៉ែស» ភោគ ឆាយ ក៏ត្រូវបាន «រដ្ឋាភិបាល» ស្តេច សីហនុ ចាត់ឲ្យដឹកនាំគណៈប្រតិភូយុវជនមួយក្រុមទៅធ្វើទស្សនកិច្ចនៅប្រទេស ចិន រយៈពេលជិត២ខែ ។ ក្រោយពេលត្រឡប់មកពីប្រទេសចិនវិញ ភោគ ឆាយ លែងហ៊ានជួបពិភាក្សាការងារជាមួយ វ៉ាន់ ទិព្វសុវណ្ណ នៅ

ពេលថ្ងៃទៀត ។ ពួកគេជួបគ្នាតែពេលយប់ដើម្បីគេចពីការតាមដានរបស់គិញ «រដ្ឋាភិបាល» ។

ដើមខែមករា ឆ្នាំ ១៩៦៦ ភោគ ឆាយ (អាយុ ២៩ឆ្នាំ) បានចូលរួមប្រជុំនៅសមាគមកម្ពុជបុត្រជាមួយតំណាងសមាគមផ្សេងៗចំនួនជាង១០នាក់ មាន ហ៊ូ នឹម តំណាងសមាគមមិត្តភាព ខ្មែរ-ចិន, ទីវ អុល តំណាងសមាគមចំរើនវិជ្ជា, កែ គឹមហួត តំណាងសិស្សនៅសាលាតាខ្មៅ, ព្រំ សំអារ និងគ្រួសារ តំណាងសមាគម គ្រូ, វ៉ាន់ ទិព្វសុវណ្ណ តំណាងអ្នកធ្វើជំនួញ, មានតំណាងសមាគមបុគ្គលិកសុរិយោដី, សមាគមរថភ្លើង ចំណែកខាងនិស្សិតមាន ភោគ ឆាយ ជាតំណាង ។ គឺជាការប្រជុំសម្ងាត់ក្រោមអធិបតីភាពរបស់ ហ៊ូ យន់ ។ ខ្លឹមសារនៃអង្គប្រជុំគឺបង្កើតអង្គការចម្រុះមួយមានលក្ខណៈសម្ងាត់ដែលមានសមាជិកជាង១០នាក់ និងមាន ហ៊ូ យន់ ជាប្រធាន, ហ៊ូ នឹម ជាអនុប្រធាន។ ហ៊ូ យន់ បានសន្មត់ពាក្យអង្គការចំរុះនេះថាជា **អង្គការបណ្តូល** ដំបូង ។ ភារកិច្ចរបស់អង្គការនេះគឺសមាគមនីមួយៗ ជាសមាជិកត្រូវជំរុញជាសម្ងាត់ធ្វើយ៉ាងណាឲ្យមហាជនគាំទ្រកាន់តែច្រើន ហើយត្រូវរក្សាការសម្ងាត់ កិច្ចការនេះដឹងតែចំពោះតំណាងធំៗដែលបានមកចូលរួមប្រជុំទេ ។

នៅខែមករាឆ្នាំ១៩៦៦ នេះដែរ ភោគ ឆាយ បានជាប់ឆ្នោតជាប្រធានសមាគមនិស្សិតជាលើកទីពីរ ។ ប៉ុន្តែដើមឆ្នាំ១៩៦៦នេះ មាននិន្នាការនយោបាយពីរប្រយុទ្ធគ្នានៅក្នុងសមាគម គឺទី១ៈ មានការទាមទារឲ្យពង្រីកសកម្មភាពរបស់សមាគម ហើយយកផ្លាកសមាគមធ្វើជារបាំងដោយយកកម្លាំងសិស្សចំរើនវិជ្ជា កម្ពុជបុត្រ និងតាខ្មៅ ធ្វើជាកម្លាំងស្នូល ។ មតិនេះបានទទួលការគាំទ្រពីនិស្សិតសាលាគ្រូ ។ ទី២ៈ ទាមទារឲ្យពង្រីកសមាគម ធ្វើសកម្មភាពតាមលក្ខណៈច្បាប់របស់រដ្ឋដោយយកការរៀនសូត្រធ្វើជាមូលដ្ឋាន ហើយត្រូវយកសាលាបច្ចេកទេសសូវៀតធ្វើជាទីស្នាក់ការធំ ។ គំនិតនេះត្រូវបានគាំទ្រដោយនិស្សិតសាលាសូវៀត ។ ដោយមានការជូនយោបល់ពី វ៉ាន់ ទិព្វសុវណ្ណ, ភោគ ឆាយ ជ្រើសរើសយកជំហរទី១ ដើម្បីបន្លំខ្លួនធ្វើជាខ្មែរក្រហមតទៅទៀត ។ គាត់បានរៀបចំធ្វើពិធីបដិសណ្ឋារកិច្ចមួយយ៉ាងធំអញ្ជើញភ្ញៀវឲ្យច្រើន មានបញ្ចាំងភាពយន្តជូនទស្សនាដោយឥតគិតថ្លៃចំនួនពីរថ្ងៃពីរយប់ ។ ពិធីនេះបានការអញ្ជើញចូលរួមពី ប៉ែន នុត និង សឺន សាន ។ សិស្សសាលាជាច្រើនក៏បានទៅមើលកុនដែលមានឈ្មោះថា «សង្គ្រាមខុងម៉ីង» ។ ដោយសារពិធីដ៏ធំដុំនេះបានធ្វើឲ្យសមាគមនិស្សិតអាចប្រមូលបានសមាជិកកាន់តែច្រើនឡើងៗ ។ ក្នុងអំឡុងពេលនោះអ្នកអង្គម្ចាស់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី (ទំព័រ៤៨នៃចម្លើយសារភាពនេះ) ។

ខែ៧ ឆ្នាំ១៩៦៦ ចៅ សេង បានជួយជ្រោមជ្រែងឲ្យ ភោគ ឆាយ បានចូលរួមក្នុងគណៈប្រតិភូមួយទៅប្រទេសគុយបា ។ ចុងខែ៨ ឆ្នាំ១៩៦៦ ក្រោយពេលត្រឡប់មកពីប្រទេសគុយបាមិនយូរប៉ុន្មាន ភោគ ឆាយ ត្រូវបាន «រដ្ឋាភិបាល» ស្តេច សីហនុ តែងតាំងជាអគ្គនាយកនៃក្រុមហ៊ុនសូណាព្រីម តាមការស្នើសុំរបស់ ចៅ សេង ដែលពេលនោះជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ។ ក្រុមហ៊ុននេះមានបុគ្គលិកជាង៤០០នាក់ ។

នៅខែធ្នូ ឆ្នាំ១៩៦៦ ភោគ ឆាយ បានចូលរួមប្រជុំក្នុងអង្គការសមាគមចំរុះក្រោមការដឹកនាំរបស់ ហ៊ូ យន់ ។ អង្គប្រជុំជ្រើសតាំងគណៈកម្មាធិការថ្មីនៃអង្គការចំរុះដែលមានការផ្លាស់ប្តូរសមាជិកខ្លះ និងមានបន្ថែមសមាជិកខ្លះឡើងដល់ចំនួន ១៧រូបគឺ ហ៊ូ យន់ ប្រធាន, ហ៊ូ នឹម អនុប្រធាន, ទីវ អុល អគ្គលេខាធិការ, តាម៉ាន់ តំណាងសមាគមកម្ពុជបុត្រ ជាអគ្គលេខាធិការរង និងមានសមាជិក៧រូបគឺ ភោគ ឆាយ តំណាងសមាគមនិស្សិត, កែ គឹមហួត តំណាងសិស្សសាលាតាខ្មៅ, តំណាងកម្មកររថភ្លើង, តំណាងបុគ្គលិកសុរិយោដី, តំណាងកម្មករកំពង់ផែ, តំណាងកម្មកររោងចក្ររដ្ឋ និងតំណាងកម្មកររោងចក្រឯកជន ។ ទីប្រឹក្សាមាន៦រូប ភាគច្រើនសុទ្ធតែចាស់ៗដែល ភោគ ឆាយ ពុំដែលស្គាល់ឈ្មោះក្នុងនោះមាន វ៉ាន់ ទិព្វសុវណ្ណ និងតាវ៉ីង ។ ឆ្លៀតឱកាសនោះ ហ៊ូ យន់ ក៏ស្នើរៀបចំពិធីតាំងពិពណ៌ និងលក់វត្ថុសិល្បៈបុរាណចិនដែលមានតម្លៃជាង២លានរៀល ជាអំណោយរបស់ស្ថានទូតចិនចំពោះសមាគមមិត្តភាព ខ្មែរ-ចិន ។ **(នៅមានត)** សាន់ កល្យាណ

◆ **ខាយបំផ្លិចបំផ្លាញផ្លូវគមនាគមន៍**

# ចម្លើយសារភាពៈ ប្រវត្តិអ្នកទោសអង្គការ ឃួន សុន ហៅ កឹម ផាន នៅភូមិភាគបូព៌ា

**(តពីលេខមុន)** មកដល់ខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥ ឈ្មោះ ស៊ែល, យ៉ា, ឈិត, និងឈ្មោះ ឆែម បានឲ្យ កឹម ផាន យកសំបុត្រទៅឲ្យឈ្មោះ សួន, សែន, សាត, វន, សាម៉ន, សារ៉ាត់, ពិន, សាគុន និងឈ្មោះ យ៉ា ដើម្បីឲ្យមកប្រជុំនៅចកវត្តមាននៅក្នុងពេលប្រជុំនោះមានចំនួន១៦នាក់ ដែលក្នុងនោះមានឈ្មោះ យ៉ា ជាលេខាសេនាធិការ, ឆែម ជាអនុលេខាសេនាធិការ, ស៊ែល សមាជិកទី១ ទទួលខុសត្រូវខាងប្រធាននយោបាយ, ឈិត ជាសមាជិកទី២ ទទួលខុសត្រូវខាងភស្តុភារ, សត្យា ជាសមាជិកទី២ ទទួលខុសត្រូវខាងក្រសួងនយោបាយ, ធឿន ជាគណៈយុវកកនៃមន្ទីរសេនាធិការ, សាម៉ន ជាលេខាវរសេនាធំលេខ១៣០ តំបន់២៣, សាត ជាលេខាវរសេនាធំលេខ១១២ តំបន់២៣, ជាអនុលេខាវរសេនាតូចលេខ៩០, សែន ជាលេខាកងវរសេនាតូចលេខ៧៥, សួន ជាលេខាកងវរសេនាតូចកាំភ្លើងធំ, ពិន ជាអនុលេខាវរសេនាធំលេខ១៣០ តំបន់២៣, កាវន អនុលេខាកងវរសេនាធំ លេខ១១២, សារ៉ាត់ ជាអនុលេខាកងវរសេនាតូចលេខ៧៣ យ៉ាន ជាអនុលេខា-ឃស៊ើបការណ៍សេនាធិការ, និងឈ្មោះ សាគុន ជាលេខា-ឃស៊ើបការណ៍សេនាធិការ ។

ក្រោយពេលប្រជុំហើយ កឹម ផាន បានឮឈ្មោះ យ៉ា និយាយអំពីការងារដែលត្រូវអនុវត្តលើផែនការធ្វើសកម្មភាពនៅក្នុងស្រុកប្រសូត្រ ពោលគឺត្រូវប្រឆាំងលើដំណើរការកសាងប្រទេស និងត្រូវរៀបចំកម្លាំងឲ្យបានស្រួលក្នុងការអនុវត្តជាបន្តទៀត ហើយកម្លាំងរបស់ឈ្មោះ សែន ត្រូវធ្វើការអុកឡុកក្នុងមូលដ្ឋានស្រុកប្រសូត្រ ។ បន្ទាប់មកឈ្មោះ យ៉ា បានឲ្យ កឹម ផាន ទៅហៅ គឹម, ហ៊ាង, ពិន, ម៉ាន, និងឈ្មោះ ស៊ុន ដើម្បីណែនាំឲ្យធ្វើសកម្មភាពបោកគ្រាប់បែកក្នុងមូលដ្ឋានស្រុកសំរោង ។ ពេលទទួលបានការណែនាំហើយក៏បានយកផែនការនោះទៅអនុវត្តដោយបានចុះទៅបោកគ្រាប់បែកនៅព្រៃពែក ប៉ុន្តែផែនការនោះមិនបានសម្រេចទេ ព្រោះត្រូវបែកការណ៍ ហើយត្រូវកងទ័ពបដិវត្តន៍ដេញបាញ់ ។ ដោយឡែកសកម្មភាពរបស់ឈ្មោះ ស៊ែល និង កឹម ផាន គឺបានចុះទៅមុខសញ្ញាផ្លូវជាតិលេខ១ ដើម្បីអនុវត្តសកម្មភាពក្បត់ដោយបើកដៃឲ្យកងទ័ពវៀតណាមបាញ់ផ្លោងមកលើប្រជាជនបណ្តាលឲ្យស្លាប់ប្រជាជនអស់ជាច្រើននាក់ ។ ក្រោយមកទៀតឈ្មោះ ស៊ែល បានឲ្យ កឹម ផាន យកសំបុត្រទៅឲ្យឈ្មោះ សាត, សាម៉ន, ពិន, សែន, កាវន, សួន, សារ៉ាត់ និងឈ្មោះ ជា ដើម្បីប្រជុំដាក់ផែនការអំពីការបើកដៃឲ្យកងទ័ពវៀតណាមចូលមកធ្វើសកម្មភាពនៅព្រៃកូនគីរ ដោយទុកឲ្យពួកគេ (កងទ័ពវៀតណាម) នៅកន្លែងនោះសិនហើយ កុំឲ្យបងប្អូនបាញ់ ។

ក្រោយមកឈ្មោះ ស៊ែល និងឈ្មោះ ផន បានទៅកន្លែង គឿង ដើម្បីឲ្យកម្លាំងរបស់ គឿង ចូលមកធ្វើសកម្មភាពបាញ់ផ្លោង ហើយឲ្យចូលមកនៅស្រុកប្រសូត្រ ព្រៃចំណារដែលមានកម្លាំងរបស់ ផន នៅទីនោះស្រាប់ផង ។ ការទាក់ទងរបស់ឈ្មោះ ស៊ែល និង ផន ជាមួយឈ្មោះ គឿង ដែលជាលេខាកងពលលេខ៥នៃកងទ័ពវៀតណាម គឺស្ថិតនៅភូមិអំពិល ។

ក្រោយពីទាក់ទងរួចហើយឈ្មោះ ស៊ែល បានឲ្យ កឹម ផាន ទៅកន្លែងរបស់ សាម៉ន, ពិន, សែន, សារ៉ាត់, សាត, សួន, យ៉ា, សាគុន, កាវន, និងឈ្មោះ គឹម ហ៊ាង ឲ្យមកប្រជុំនៅមន្ទីរតំបន់ ។ វត្តមាននៅក្នុងពេលប្រជុំនោះមានឈ្មោះ សូ ជាលេខាតំបន់២៣, គួន ជាអនុលេខាតំបន់២៣, ឆែម ជាលេខាសេនាធិការ, ស៊ែល ជាអនុលេខាសេនាធិការ, ឈិត ជាសមាជិក, សួន ជាលេខាកងវរសេនាតូចកាំភ្លើងធំ, សែន ជាលេខាវរសេនាតូចលេខ៧៥, ពិន ជាអនុលេខាវរសេនាធំលេខ១៣០, កាវន ជាអនុលេខាវរសេនាធំលេខ១១២ តំបន់២៣, សាម៉ន ជាលេខាកងវរសេនាធំលេខ១៣០ តំបន់២៣, សាត ជាលេខាកងវរសេនាធំលេខ១១២ តំបន់២៣, សារ៉ាត់ ជាអនុលេខាកងវរសេនាតូចលេខ៧៣, ជា

ជាអនុលេខាកងវរសេនាតូចលេខ៩០ សាគុន ជាលេខា-យស៊ើបការណ៍, គីមហ៊ាង ជាសមាជិកបច្ចេកទេសពេទ្យតំបន់២៣, យ៉ាន ជាអនុលេខា-យស៊ើបការណ៍, សាលីវ ជាលេខាស្រុកប្រសូត្រ, ផន ជាលេខាស្រុកកំពង់រោទិ៍, សត្យា ជាសមាជិកផ្នែកនយោបាយ និងឈ្មោះ គឿន ជាគណៈយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) មន្ទីរសេនាធិការ ។ ពេលនោះ គីម ផាន នៅអង្គុយខាងក្រៅ ប៉ុន្តែបានស្តាប់ឮផែនការរបស់ឈ្មោះ សូ ដោយបាននិយាយថា «យើងត្រូវធ្វើសកម្មភាពឆ្នាំ១៩៧៦ យើងត្រូវរៀបចំកម្លាំងរបស់យើងគ្រប់មុខសញ្ញាដើម្បីធ្វើការអុកឡុកបោកគ្រាប់បែកនៅគ្រប់មូលដ្ឋាន» ។ ពេលប្រជុំចប់ឈ្មោះ ស៊ើល ទទួលមុខសញ្ញានៅខាងស្រុកប្រសូត្រ និងស្រុកចន្ទ្រា ពេលនោះឈ្មោះ ស៊ើល, គីម ផាន, សែង, ណន បានទៅដល់សមរភូមិជីភូ ហើយកងទ័ពវៀតណាមចាប់ផ្តើមធ្វើសកម្មភាពចូលមកមេសថ្ងក ដែលឃ្លាតពីព្រំដែនប្រហែល១០គីឡូម៉ែត្រ ។ ក្នុងពេលជាមួយគ្នានោះឈ្មោះ ស៊ើល ក៏បានបញ្ជាកងទ័ពផ្ទាល់ដោយឲ្យឈ្មោះ ការ៉ន ដកទ័ពថយមកក្រោយវិញ ។ ឆ្លៀតពេលនោះ កងទ័ពវៀតណាមចាប់ផ្តើមធ្វើសកម្មភាពកាប់សម្លាប់កងចល័តនិងប្រជាជនអស់៧០នាក់ និងចាប់យកប្រជាជនទៅក្នុងប្រទេសវៀតណាមអស់ចំនួន៦០នាក់ ។ ក្រោយពីកងទ័ពវៀតណាមធ្វើសកម្មភាពហើយ ឈ្មោះ ស៊ើល និង គីម ផាន បានចុះទៅកន្លែងរបស់ឈ្មោះ ការ៉ន នៅមេសថ្ងក ហើយ ស៊ើល បាននិយាយថា «មិត្តត្រូវចុះទៅឲ្យជាប់នឹងសមរភូមិជាមួយបងប្អូនងាយស្រួលលើដំណើរការធ្វើសកម្មភាពរបស់យើងតទៅទៀត» ។ ក្រោយមកទៀតឈ្មោះ ស៊ើល ឲ្យ គីម ផាន យកសំបុត្រទៅឲ្យ ថាន់ (កងទ័ពវៀតណាម) ហើយ ថាន់ បានប្រាប់ គីម ផាន ថា «លើបញ្ជាកងទ័ពរបស់ខ្ញុំមិនទាន់ជុំគ្នាទេ» ។ រួចហើយ គីម ផាន បានយកដំណឹងនេះទៅប្រាប់ឈ្មោះ ស៊ើល វិញ ។ ពេលនោះឈ្មោះ សូ ក៏បានហៅក្រុមក្បត់របស់ខ្លួនមកប្រជុំគ្នានៅគគីសោមក្នុងស្រុកប្រសូត្រដែរ ។

ពេលប្រជុំ គីម ផាន និង សេង បានឮឈ្មោះ សូ និយាយថា «ថ្ងៃនេះខ្ញុំជម្រាបផែនការមួយចំនួនក្នុងខែធ្នូ ឆ្នាំ១៩៧៧ នាពេលខាងមុខនេះវៀតណាមចូលមកក្នុងទឹកដីខេត្តស្វាយរៀងរបស់យើងទាំងមូល មិត្តត្រូវរៀបចំកម្លាំងរបស់យើងឲ្យបានស្រួល ដើម្បីបើកផ្លូវឲ្យកងទ័ពវៀតណាមចូលមក ទី១-បើកផ្លូវការអី(ច្រកផ្លូវវៀតណាម)ចូលមកពីខាងកើត ទី២-បើកផ្លូវក្រៀង(ច្រកផ្លូវវៀតណាម)ឲ្យកងទ័ពវៀតណាមចូលមកតាមផ្លូវជាតិលេខ១៣» ។ ក្រោយពីប្រជុំហើយឈ្មោះ ស៊ើល បានចាត់ឲ្យ គីម ផាន ទៅទាក់ទងនៅកន្លែងឈ្មោះ ថាំង (កងទ័ពវៀតណាម) កាន់ខាងលេខាកងពលលេខ៧ ដើម្បីយកសំបុត្រទៅឲ្យ ហើយឈ្មោះ ថាំង បានប្រាប់ គីម ផាន វិញថា «កម្លាំងរបស់ខ្ញុំដែលទៅនៅតាខុបនោះខ្ញុំដកមកវិញហើយ» ។

នៅខែធ្នូ ឆ្នាំ១៩៧៧ វេលាម៉ោង៥ទៀបភ្លឺកងទ័ពវៀតណាមក៏ចាប់ផ្តើមផ្ទុះអាវុធគ្រប់មុខសញ្ញា ហើយកងទ័ពវៀតណាមបានចូលមកដល់គគីសោម ដែលមានខ្សែរបស់ សូ និង ស៊ើល ហើយពេលនោះ ឈ្មោះ ស៊ើល បានបញ្ជាកងទ័ពរបស់ខ្លួនឲ្យដកថយគ្រប់មុខសញ្ញា ។ នៅក្នុងខែដដែលនេះដែរ ស៊ើល បានឲ្យកងទ័ពវៀតណាមយកឡានដឹកគ្រាប់គ្រប់ធុន និងយកកាំភ្លើងធុន១២០លីចំនួន១ដើមយកទៅវត្តក្តៀងរាយ ខាងកើតស្រុកប្រសូត្រ ។ ក្រោយពីកងទ័ពវៀតណាមបានយកឡានដឹកគ្រាប់គ្រប់ធុន និងកាំភ្លើង១២០លីចំនួន១ដើមមកដាក់ រួចហើយឈ្មោះ ស៊ើល ក៏បានចុះធ្វើសកម្មភាពនៅមុខសញ្ញាស្រុករមាសហែក ហើយឈ្មោះ ស៊ើល បានឲ្យឈ្មោះ សេង និង គីម ផាន ទៅហៅ សាម៉ន, ពិន, ការ៉ន, សួន និងឈ្មោះ សាត ដើម្បីមកប្រជុំនៅវត្តដូងចាស់ ។ វត្តមាននៅពេលប្រជុំនោះមានឈ្មោះ ស៊ើល ជាគណៈសេនាធិការ, សាម៉ន ជាលេខាកងវរសេនាធំលេខ១៣០ តំបន់២៣, សាត ជាលេខាកងវរសេនាធំលេខ១១២, ពិន ជាអនុលេខាកងវរសេនាធំលេខ១៣០, ការ៉ន ជាអនុលេខាកងវរសេនាធំលេខ១១២ និងឈ្មោះ សួន ជាលេខាកងវរសេនាធំកាំភ្លើងធំ ។ ផែនការប្រជុំមាន៣មុខសញ្ញា គឺឲ្យកងទ័ពវៀតណាមចូលមកតាមផ្លូវបាតត្រាស់ឡើងមកខាងត្បូងខាងទួលប្រសាទ, ឲ្យកងទ័ពវៀតណាមចូលតាមវត្តតាឯក ឆ្ពោះមកទិសខាងលិច និងឲ្យកងទ័ពវៀតណាមចូលមកតាមច្រកចេកមាស ។

## សកម្មភាពក្បត់ប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហមក្នុងឆ្នាំ១៩៧៨

នៅខែកុម្ភៈ ឆ្នាំ១៩៧៨ ស៊ើល បានហៅឈ្មោះ ស៊ាន,

សេង, ម៉ាន, សាមិត និង គឹម ផាន ដើម្បីណែនាំលើបញ្ហាធ្វើសកម្មភាពបោកគ្រាប់បែកដាក់ឡានតូចរបស់កម្មាភិបាលខ្មែរក្រហមនិងឲ្យបោកគ្រាប់បែកនៅតាមមូលដ្ឋានមន្ទីរក្រសួងរបស់បដិវត្តន៍ ។ ក្រោយពីទទួលការណែនាំហើយ ឈ្មោះ ម៉ាន និង ឈ្មោះ ស៊ាន បានធ្វើសកម្មភាពបោកគ្រាប់បែកដាក់ឡានរបស់កម្មាភិបាលរបស់ខ្មែរក្រហមដូចជាឡានរបស់ឈ្មោះ ពីន និងឡានរបស់ឈ្មោះ ណាត ចំនួនពីរគ្រាប់ ។ ប៉ុន្តែមិនបានសម្រេចតាមការណែនាំឡើយ ព្រោះគ្រាប់បែកបានធ្លាក់ពីក្រោយឡានត្រង់ថ្នល់កែងនៅទួលក្រូច ។ ក្រោយមកទៀត គឹម ផាន បានឲ្យ ស៊ើល និយាយគ្នាជាមួយឈ្មោះ ចាន់ ជាអនុលេខាស្រុកប្រសូត្រ ដោយមានខ្លឹមសារថា «ខ្ញុំទាក់ទងមិត្តលើកម្លាំងឲ្យធ្វើសកម្មភាពចូលមកក្នុងស្រុកប្រសូត្រ ពីព្រោះកម្លាំងរបស់មិត្ត ថាំង បច្ចុប្បន្នចូលមកនៅទួលប្រសាទហើយ» ។ ក្រោយពីទាក់ទងជាមួយឈ្មោះ ថាំង (កងទ័ពវៀតណាម) ជាលេខាកងពលលេខ៣ រួចហើយឈ្មោះ ស៊ើល ក៏បានវិលត្រឡប់មកវិញ ។

នៅខែមីនា ឆ្នាំ១៩៧៨ ឈ្មោះ ស៊ើល បានឲ្យ គឹមផាន ទៅបោកគ្រាប់បែកសម្លាប់កម្មាភិបាលខ្មែរក្រហមឈ្មោះ ពីន និង ណាត ម្តងទៀត ។ ពេលដែល គឹម ផាន ធ្វើដំណើរពីផ្ទៃងមកជាមួយ សាត ហើយពេលមកដល់ត្រង់ថ្នល់កែងភូមិក្រូច ត្រង់ផ្ទះរបស់កងទ័ពស្រុកសំរោង គឹម ផាន បានផ្ញើកាំភ្លើងអាកាចំនួន១ដើម និងខោអាវមួយកំផ្លេទុកនៅទីនោះ ហើយ បានដើរសំដៅទៅកន្លែងរបស់ ពីន និង ណាត ក្នុងគោលបំណងសម្លាប់កម្មាភិបាលខ្មែរក្រហមទាំងពីររូបនេះ ។ ប៉ុន្តែពេលនោះស្រាប់តែត្រូវកងទ័ពរបស់ឈ្មោះ ពីន ចាប់ខ្លួន គឹម ផាន តែម្តងនៅវេលាម៉ោង១២យប់ ។

យោងប្រភពឯកសារលេខ «J០០៧៥៨» ដែលជាប្រភេទឯកសារចម្លើយសារភាពរបស់ គឹម ផាន ដែលត្រូវពួកខ្មែរក្រហមចោទថា ជាជនក្បត់បដិវត្តន៍មានតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «ប្រវត្តិសកម្មភាពក្បត់របស់ គឹម ផាន» ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ មានចំនួន២៩សន្លឹកនៃឯកសារដើម និងចម្លើយសារភាពរបស់ គឹម ផាន ធ្វើឡើងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨ ក្រោមការសួរចម្លើយរបស់មិត្ត ដូ ។ ចម្លើយនេះមានបញ្ជាក់ដោយអ្នកសួរដាក់ថា «**អ្នកសារភាពសរសេរដោយដៃផ្ទាល់របស់ គឹម ផាន**» ។ ចម្លើយសារភាពនេះបានចម្លងជាអក្សរអង្គុលីលេខចប់នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ ។ លើសពីនេះទៀតចម្លើយសារភាពមានបញ្ជាក់អំពីកម្លាំងក្បត់ចំនួន៤៥នាក់ ក្នុងនោះកម្លាំងដែលមិនទាន់ចាប់ខ្លួនបានមានចំនួន៣៥នាក់ និងកម្លាំងដែលចាប់បានមានចំនួន១០នាក់ ។ ប៉ុន្តែចំណុចសំខាន់នៃឯកសារនេះ គឺមានចំណាររបស់ ឌុច ប្រធានគុកទួលស្លែង បានសរសេរផ្ញើទៅថ្នាក់លើមានខ្លឹមសារថា «***បងជាទីគោរព, អានេះវាចូលទៅប្រុងបោកគ្រាប់បែកកន្លែងបងពីន ម៉ោង១២យប់ ។ មានរាយការណ៍ជូនអង្គការម្តងហើយដាក់ំណត់ហេតុ ។ ចម្លើយលម្អិតលើកនេះក៏មិនស៊ីជម្រៅប៉ុន្មានដែរ វានិយាយត្រឹមតែវាជានិរសារត់សំបុត្រ និងរត់ពាក្យរបស់មេៗវាទាំងបងយ៉ួន ទាំងបងខ្មែរ ។ ឯកសារនេះជូនបង៨៩ពីរច្បាប់ហើយ, ដោយ គោរព, ឌុច ២៧-៣-៧៨*** » ។ «***ទុកឯកសារ, ទ-ទ ២៨-៣-៧៨ (បានទទួលនៅថ្ងៃទី ២៨ ខែមីនា ឆ្នាំ១៩៧៨)*** » ។

សុភារិទ្ធ

## ពាក្យស្លោកខ្មែរក្រហម

◆ផ្តើមគំនិតរបស់បដិវត្តន៍ គឺខ្លួនទីពឹងខ្លួន។

◆មានតែប្រជាជនទេដែលអាចកសាងប្រវត្តិសាស្ត្រសកលលោក។

◆ខ្មែរទន់ទើបចចចំណងបានល្អ។

(សៀវភៅ ញ៉ុក សារុន)

◆សេចក្តីស្រេកឃ្លានជារោគមានអានុភាពជាងគេទាំងឡាយ។

◆វាយសម្រុកសម្រេចផលស្រូវឆ្នាំ១៩៧៨ បីតោនកន្លះ និង ៧តោនក្នុង១ហិកតា ឱ្យបានមួយរយភាគរយជាច់ខាត។

(សៀវភៅលេខ១០៧៦ កណាហ)

◆ពង្រីកសង្គ្រាមឈ្លបឱ្យបានធំទូលាយគ្រប់តំបន់។

◆រួមផ្សំការប្រយុទ្ធនិងការចលនាបំបាក់បំបែកជួរទាហានខ្មាំង

◆វាយទីតាំងឃ្លាំងសម្ភារខ្មាំង។

(សៀវភៅលេខ១៩៨ កណាហ)

**(តពីលេខមុន)** ថាសហ្វីល «មីក្រូហ្វីល» ដែលបានចម្លងរូប ហើយនោះក៏បានផលិតបន្តនូវឯកសារមិនមែនជាប្រភេទចម្លើយសារភាពដែលត្រូវបានស្រាវជ្រាវឃើញក្នុងគុកទួលស្លែង ។ ហើយលើសពីនេះទៀតថាសហ្វីលទាំងនោះក៏ផ្ទុកនូវកំណត់ត្រាបញ្ជីចេញចូល និងកំណត់ហេតុនៃការសម្លាប់ ចម្លើយសារភាពវាយអង្គុយលីលេខដែលធ្វើឡើងដោយតំបន់ និងអង្គភាពយោធា និងការិយាល័យរដ្ឋបាល ព្រមទាំងសៀវភៅសិក្សាសរសេរដោយដៃទាក់ទងនឹងប្រធានបទជាច្រើនដូចជានយោបាយរបៀបសម្គាល់យន្តហោះ គណិតវិទ្យា វិជ្ជាពេទ្យ កាំភ្លើងធំនិង កាំភ្លើងធុនតូច ។ មិនតែប៉ុណ្ណោះឯកសារដែលមិនមែនជាចម្លើយសារភាពរួមមានលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា សុន្ទរកថានិងទិសបញ្ជាការផ្សារពីមជ្ឈិមបក្សព្រមទាំងទិនានុប្បវត្តិអំពីទ្រឹស្តីដែលហៅថា «ទង់បដិវត្តន៍» និង «យុវជនបដិវត្តន៍» ដែលចែកចាយដោយសមាជិកបក្ស ។ ឯកសារទាំងអស់ត្រូវបានចម្រាញ់ចេញពីគុកទួលស្លែងផ្ទាល់តែម្តងដែលរួមបញ្ចូលទាំងរបាយការណ៍នៃត្រីមាសទីមួយឆ្នាំ ១៩៧៧ អក្សរសរសេរដោយអ្នកសួរចម្លើយដែលរាយការណ៍ពីការធ្វើទារុណកម្មចំពោះអ្នកទោស បទបញ្ជាសម្រាប់ឆ្មាំគុក និងចំណាររបស់ «ឌុច» ដែលជាប្រធានគុក «ទួលស្លែង ឬមន្ទីរស-២១» និយាយអំពីបញ្ហាជាច្រើន រួមមានការធ្វើវិភាគរបស់ខ្លួនលើចម្លើយសារភាពនៅក្នុងឯកសារសរសេរដៃមួយដែលប្រហែលជាត្រូវបានសរសេរនៅដើមឆ្នាំ១៩៧៨ មានចំណងជើងថា «ផែនការចុងក្រោយ» ។ ឯកសារដែលមិនមែនជាចម្លើយសារភាពដែលផ្តល់ពត៌មានដ៏ច្រើនបំផុតដែលថតចម្លងហើយដោយសកលវិទ្យាល័យខនែល គឺជាសៀវភៅសិក្សាមួយក្បាលមានកម្រាស់៥៥ទំព័រ ចងក្រងដោយអ្នកសួរចម្លើយនៅឆ្នាំ១៩៧៦ ។



## សម្លេងពីមន្ទីរ ស-២១
### វគ្គទី១: ការរកឃើញមន្ទីរ ស-២១
### ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ

អត្ថបទនេះនឹងត្រូវបានលើកយកមកពិភាក្សាលម្អិតនៅជំពូកទី៥ ។

នៅពេលដែលការថតចម្លងឯកសារត្រូវបានបញ្ចប់នៅឆ្នាំ ១៩៩៣ គេគិតថា ថាសហ្វីលទាំងអស់នោះគឺមានឯកសារដែលសំខាន់ៗដែលនៅសេសសល់ពីគុកទួលស្លែង ។ ប៉ុន្តែនាឆ្នាំ១៩៩៥ បណ្ណសារដ្ឋានស-២១ មួយផ្នែកទៀតនៅក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជា ត្រូវបានបង្ហាញដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ហៅកាត់ថា «ឌីស៊ីខេម» ដែលកាលណោះជាសាខាមួយនៃកម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បង្កើតឡើងដោយសកលវិទ្យាល័យយែល ក្រោមជំនួយឧបត្ថម្ភរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ក្នុងគំនិតមួយដើម្បីប្រមែប្រមូលនិងចងក្រងឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារថ្មីដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាហាក់ដូចជាត្រូវបានយកចេញពីបណ្ណសារដ្ឋានរបស់រដ្ឋមន្ត្រីការពារប្រទេសនិងសន្តិសុខជាតិនៃរបបកម្ពុជាប្រជា-ធិបតេយ្យ សុន សេន ដែលរួមចំណែកក្នុងការត្រួតពិនិត្យគុកនេះ ។ អត្ថបទចម្លើយសារភាពជាង៥០ ក្នុងចំណោមឯកសារថ្មីនេះ ដែលប្រមូលបាននេះមានចំណារសរសេរដោយដៃរបស់ សុន សេន ។ នៅលើក្របមុខនៃឯកសារភាគច្រើនមានសរសេរជាអក្សរវៀតណាមបញ្ជាក់ថាឯកសារនេះត្រូវបានពិនិត្យពីសំណាក់អាណាព្យាបាលវៀតណាមនៅកម្ពុជា នាទសវត្សរ៍ឆ្នាំ៨០ ។

ឯកសារដែលត្រូវបានរកឃើញថ្មីទាំងនោះមានចម្លើយសារភាពរាប់សិប និងឯកសាររដ្ឋបាលសំខាន់ៗមួយចំនួនដែលមិនមាននៅក្នុងបណ្ណសារដ្ឋានស-២១ ដូចជាការប្រជុំជីវភាពស្វ័យទិតៀនរបស់កម្មាភិបាលនៅគុកស-២១ ព្រមទាំងសៀវភៅសរសេរចងក្រងដោយអ្នកសួរចម្លើយថ្នាក់លើ ។ ឯកសាររបស់

កម្ពុជាប្រជាធិបតេយ្យដែលគ្មានការទាក់ទងនឹងគុកស-២១ ក៏ត្រូវបានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ហើយជាការប្រាកដណាស់ថាឯកសារទាំងនោះនឹងមានសារៈប្រយោជន៍ចំពោះអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់អំពីរបបកម្ពុជាប្រជាធិបតេយ្យ ។

ឯកសាររាប់រយផ្សេងទៀតនៅគុកស-២១ដែលមិនត្រូវបានថតចម្លងជាមីក្រូហ្វីលនោះ ក៏បានហូរចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ គឺចាប់តាំងពីឆ្នាំ១៩៩៦មក ។ ឯកសារទាំងនេះរួមមានអត្ថបទផ្សេងៗ កាលវិភាគសួរចម្លើយមួយចំនួន បញ្ជីឈ្មោះអ្នកទោសដែលឈឺ ឯកសារដែលផ្ញើមកភ្ជាប់ជាមួយអ្នកទោសមកកាន់មន្ទីរស-២១ ហើយនិងសៀវភៅសិក្សាសរសេរដៃជាង២០០ទៀត ។ **សៀវភៅពីរក្បាលដែលមានសារៈប្រយោជន៍ពិសេសជាងគេត្រូវបានរៀបរៀងឡើងក្នុងចន្លោះឆ្នាំ១៩៧៧ និង១៩៧៨ ដោយប្រធានសួរចម្លើយឈ្មោះ ម៉ម ណាយ ហៅ ចាន់ ជាមួយអ្នកសួរចម្លើយពីរនាក់ទៀតឈ្មោះ ទុយ និង ប៉ុន ។**

ម្យ៉ាងវិញទៀត ដំណើរការស្វែងរកឯកសារនៅគុកស-២១ ចាប់ផ្តើមឡើងនៅខែមករា ឆ្នាំ១៩៧៩ ហើយមកដល់សព្វថ្ងៃក៏នៅតែដំណើរការជាបន្តឥតឈប់ឈរ ។ ឯកសារដ៏សន្ធឹកសន្ធាប់ដែលមានដល់ឥឡូវនេះហាក់ដូចជាមានលក្ខណៈគ្រប់គ្រាន់ហើយសម្រាប់ការសិក្សាលម្អិតអំពីមន្ទីរស-២១នេះ ។ អ្នកនិពន្ធជនជាតិយូហ្គោស្លាវីម្នាក់ឈ្មោះ មីឡូវ៉ាន ជីឡាស់ បានកត់សម្គាល់ថា «របៀបចាត់ចែងគុក និងរបៀបដែលជនជាប់ឃុំឃាំងត្រូវបានធ្វើបាបនោះគឺបានបង្ហាញជារូបភាពពិតត្រង់ផ្លូវមួយនៃសង្គម ជាពិសេសបង្ហាញពីគំនិតនិងរបៀបធ្វើការរបស់អ្នកដែលដឹកនាំសង្គមនោះ» ដែលហាក់ដូចជាចំណាប់អារម្មណ៍មួយពិសេសដែលមានលក្ខណៈសមស្របគ្នាទៅនឹងមន្ទីរស-២១ និងរបបកម្ពុជាប្រជាធិបតេយ្យ ។ បើយើងមើលឯកសារទាំងនោះយ៉ាងដិតដល់ ហើយស្តាប់សម្តីជនរងគ្រោះជាច្រើនដែលរស់នៅក្រោមលក្ខខណ្ឌដ៏លំបាកវេទនានោះ យើងនឹងអាចយល់ដឹងរឿងអ្វីមួយអំពីខ្លួនឯងផ្ទាល់ ។

នៅខែសីហា ឆ្នាំ១៩៨១ ខ្ញុំបានចំណាយពេលជិតមួយម៉ោងចូលមើលគុកទួលស្លែង ។ ចាប់តាំងពីឆ្នាំ១៩៩០ ខ្ញុំបានវិលត្រឡប់មកមើលសារមន្ទីរជាច្រើនដង ។ ថ្វីត្បិតតែ ឬប្រហែលដោយសារបុគ្គលិកនៅសារមន្ទីរទួលស្លែងទទួលរាក់ទាក់ស្វាគមន៍ ខ្ញុំតែងមានអារម្មណ៍រង្វេងវង្វាន់ដោយសារទីកន្លែងនេះ ។ រាល់ពេលដែលខ្ញុំមកធ្វើទស្សនកិច្ចខ្ញុំមានអារម្មណ៍រន្ធត់យ៉ាងខ្លាំងដោយសារទិដ្ឋភាពផ្ទុយគ្នាស្រឡះរវាងបរិវេណដែលស្ងប់ស្ងាត់ចាំងជះដោយពន្លឺព្រះអាទិត្យគ្រប់ច្រកល្ហកនិងរូបពិពណ៌ដែលគួរឲ្យរន្ធត់រវាងបន្ទប់រៀនដែលដុសលាងសស្អុះមានក្រាលឥដ្ឋពណ៌លឿង និងឧបករណ៍ធ្វើទារុណកម្មនៅក្នុងបន្ទប់ទាំងនោះហើយនិងរវាងក្មេងៗដែលកំពុងរត់លេងខាងក្រៅអគារនិងរូបថតក្មេងៗពាក់កណ្តាលខ្លួនដែលកំពុងត្រូវបានបណ្តើរយកទៅសម្លាប់ចោល ។

នៅឯសារមន្ទីរ ភ្នែកជនរងគ្រោះនៅក្នុងរូបថតពាក់កណ្តាលខ្លួនដែលដាក់តាំង ជាពិសេសភ្នែករបស់ស្ត្រី និងកូនក្មេងហាក់ដូចជាតាមសម្លឹងខ្ញុំមិនដាក់ភ្នែក ។ ដោយដឹងនូវអ្វីដែលជនរងគ្រោះមិនបានដឹងថា ការដែលជនរងគ្រោះម្នាក់ៗកំពុងតែប្រឈមមុខនឹងសេចក្តីស្លាប់ នៅពេលដែលខ្លួនត្រូវថតរូបយកនោះធ្វើឲ្យរូបភាពនោះផ្តល់ឲ្យយើងនូវអារម្មណ៍តក់ស្លុតអស់ស្មារតី ហើយរូបថតទាំងនោះធ្វើឲ្យយើង ជាពិសេសរូបខ្ញុំផ្ទាល់មានអារម្មណ៍ព្រឺព្រួចជាងរូបថតមនុស្សស្លាប់ ឬការគូររូបពិពណ៌នាអំពីការធ្វើទារុណកម្មដ៏សាហាវដែលគូរក្រោយឆ្នាំ១៩៧៩ ដោយអ្នកដែលរួចចាកផុតពីសេចក្តីស្លាប់នៅគុកទួលស្លែងម្នាក់ឈ្មោះ វ៉ាន់ ណាត នោះទៅទៀត ។

ស្ទើរតែគ្រប់ដំណើរទស្សនកិច្ចរបស់ខ្ញុំ តែងតែមានសត្វសារិកាកែវលោតទៅលោតមករំលងផ្លូវដែលមានស្មៅដុះស៊ុបទ្រុបជុំវិញ ។ មាន់រងាវព្រួសូររំពងជុំវិញផ្ទះអ្នកស្រុក លាយឡំនឹងសម្លេងចរាចរណ៍នៅលើដងមហាវិថីមុនីវង្ស សូររហ៊ឹមៗនៅទិសខាងកើត ឬក៏នៅក្នុងរដូវប្រាំងមានសំឡេងភ្លេងអាពាហ៍ពិពាហ៍តាមប្រពៃណីព្រះពុទ្ធសាសនានៅជិតទីតាំងគុកទួលស្លែងនោះទៀតផង ។ សម្លេងនៅទសវត្សរ៍ឆ្នាំ៧០ មានលក្ខណៈខុសគ្នាពីសម្លេងនាពេលនៃការធ្វើទស្សនកិច្ចរបស់ខ្ញុំ ។ កាលណោះរៀងរាល់រាត្រីនៅក្នុងទីក្រុងដែលងងឹតសូន្យនិងស្ងាត់ជ្រងំ អ្នកធ្វើការនៅក្នុងគុកទួលស្លែងដែលគេដាក់ឲ្យប្រចាំការនៅលើមហាវិថីមុនីវង្ស បានឮសម្លេងមនុស្សដែលកំពុងត្រូវបានធ្វើទារុណកម្មស្រែកឲ្យ

ជួយ ។ មិនតែប៉ុណ្ណោះ អ្នកដែលនៅរស់រានមានជីវិតព្រមទាំង អ្នកដែលបានធ្វើការនៅក្នុងគុក ក៏បានចែករំលែកនូវការចងចាំរបស់ខ្លួនអំពីការឮសំឡេងស្រែកយំទាំងក្តីឈឺចាប់នៅពេលរាត្រី ។

ដោយចេះតែដើរៗជុំវិញសារមន្ទីរ ស្រូបយកពត៌មានពីបណ្ណសារដ្ឋាននៃគុកទួលស្លែង និងដោយស្តាប់នូវការរ៉ាយរ៉ាប់របស់អ្នកដែលនៅរស់រានមានជីវិតនិងអ្នកដែលបម្រើការងារនៅក្នុងគុកនេះ យើងក៏នៅតែអាចឮសំឡេងខ្មោចជាច្រើនកំពុងដង្ហោយហៅដោយទំនួញឈឺចាប់ពីក្នុងគុកនោះឲ្យជួយ ។ សម្លេងជនរងគ្រោះទាំងនោះសណ្ឋិតនៅក្នុងលើសាច់រឿងដែលរៀបរាប់បន្ត ។

អត្តភាព យោធា ។ល។និង។ល។

ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដែលជាស្ថាប័នស្វយ័តដ៏ល្អឥតខ្ចោះ លោក អៀវីង លី ហ្វូវ៉ីត យល់ថាប្រទេសកម្ពុជាទាំងមូលបានប្រែក្លាយយ៉ាងឆាប់រហ័សទៅជា «បរិយាកាសមួយដូចក្នុងបន្ទប់បិទជិត» ដែលនៅដាច់ចេញពីពិភពខាងក្រៅ ។ ប្រទេសជាតិបានគ្រប់គ្រងដោយមនុស្សមួយក្តាប់តូចដែលភាគច្រើនជាអតីតគ្រូបង្រៀនដែលងប់ងុលនឹងនយោបាយ ។ អ្នកទាំងនេះយល់ថា ការត្រួតត្រា ការដាក់ទោស និងការកែប្រែមនុស្សដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួនជាភារកិច្ចយូរអង្វែង ។ កម្មាភិបាលទទួលបន្ទុកស-២១ ស្ថិតក្រោមការត្រួតពិនិត្យរបស់មជ្ឈិមបក្ស ។ ស្រដៀងគ្នានេះដែរកម្មាភិបាល







## ស-២១ ស្ថាប័នស្វយ័ត

ក្នុងសៀវភៅរបស់គាត់ក្រោមចំណងជើងថា «សិទ្ធិជ្រកកោន» ដែលមានសេចក្តីអធិប្បាយដ៏ក្បោះក្បាយ សង្គមវិទូ អេវីង ហ្គូវមិន បានឲ្យនិយមន័យ «ស្ថាប័នស្វយ័ត» ថាជាកន្លែងស្នាក់នៅនិងធ្វើការរបស់ក្រុមមនុស្សដែលត្រូវបានដាក់ក្នុងស្ថានភាពដូចគ្នា ហើយគាត់ផ្តាច់ចេញពីសង្គមទាំងមូលមួយរយៈពេល ។ ក្រុមមនុស្សនេះរស់នៅរួមគ្នាក្នុងជីវិតមួយដែលត្រូវបានបិទជិតឈឹង និងគ្រប់គ្រងជាផ្លូវការ ។ លោក អេវីង បន្តហៅស្ថាប័ននេះថា ជាកន្លែងបង្ខំមនុស្សឲ្យកែប្រែ និងធ្វើការពិសោធន៍តាមបែបធម្មជាតិលើអ្វីៗដែលអាចធ្វើបានចំពោះមនុស្ស ។ ស្ថាប័ននេះរួមមានសាលារៀន វត្តអារាម មន្ទីរពេទ្យ

ទាំងនេះត្រូវបានបិទបាំងពីភ្នែកអ្នកខាងក្រៅ ហើយក្នុងនាមជាសមាជិកកងវរសេនាធំឯករាជ្យ កម្មាភិបាលស-២១ទាំងនេះធ្វើការក្រោមវិន័យយោធា ។ មន្ទីរស-២១ មជ្ឈិមបក្ស បក្សកុម្មុយនិស្តកម្ពុជា ក៏ដូចជារដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ អាចត្រូវបានយល់ថាជា «កន្លែងបង្ខំមនុស្សឲ្យកែប្រែ» កាន់តែច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។

តាមការឲ្យនិយមន័យរបស់លោក អេវីង ស-២១គឺជារូបភាពដ៏អាក្រក់បំផុតមួយនៃស្ថាប័នស្វយ័ត ។ បេសកកម្មរបស់ស-២១គឺការពារមជ្ឈិមបក្ស ។ ស-២១បំពេញបេសកកម្មនេះមួយផ្នែកដោយការកាប់សម្លាប់អ្នកទោសទាំងអស់ និងមួយផ្នែកទៀតដោយការប្តូរជីវប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកទោសទាំងនោះ

ទៅតាមតម្រូវការ និងការសង្ស័យនានារបស់បក្ស ។ ការត្រួតពិនិត្យលើជីវប្រវត្តិ លើអ្នកទោស និងលើបុគ្គលិកក្នុងមន្ទីរ ស-២១ មានលក្ខណៈតឹងតែងនិងមាន «វិន័យ» សាំញ៉ាំទៀតផង ។ លក្ខណៈបែបនេះអនុញ្ញាតឲ្យអ្នកមើលការខុសត្រូវអាចត្រួតត្រា និងដឹកនាំការកែប្រែអ្នកទោសទាំងនោះបានយ៉ាងមានប្រសិទ្ធិភាព ។

មន្ទីរស-២១មានផ្នែកស៊ើបអង្កេត ផ្នែកតុលាការ និងផ្នែកប្រឆាំងចារកម្ម ។ ឯកសារខ្លះហៅស-២១ថាជា «ក្រសួង» ឯកសារខ្លះទៀតហៅស-២១ថាជា«មន្ទីរ»ទៅវិញ ។ ស្ថាប័ននៃប្រទេសកុម្មុយនិស្តដែលមានលក្ខណៈដូចសន្តិបាលនៃប្រទេសកម្ពុជារួមមាន ភ្នាក់ងារសម្ងាត់នៃអតីតសហភាពសូវៀត (NKVD), ភ្នាក់ងារសម្ងាត់នៃអតីតអាល្លឺម៉ង់ខាងកើត (Stasi) និងភ្នាក់ងារសម្ងាត់នៃប្រទេសចិន (CCEG) ។ មន្ទីរស-២១ក៏មានលក្ខណៈប្រហាក់ប្រហែលការិយាល័យសហព័ន្ធស៊ើបអង្កេត (FBI) របស់សហរដ្ឋអាមេរិក និង(M១៥) របស់អង់គ្លេសដែរ ។ តាមពិតទៅ ប្រទេសភាគច្រើននៃសតវត្សរ៍ទី២០សុទ្ធតែមានស្ថាប័នសន្តិសុខជាតិរបស់ខ្លួនរៀងៗខ្លួន ។ ខុសពីស្ថាប័នសន្តិសុខជាតិប្រទេសដទៃ មន្ទីរស-២១ពុំបានពង្រាយភ្នាក់ងាររបស់ខ្លួនទៅតាមទីជនបទ ឬទៅក្រៅប្រទេស និងពុំមានការិយាល័យរៀបចំគោលនយោបាយមជ្ឈិមឡើយ ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ គ្រប់មុខងារនៃមន្ទីរស-២១ត្រូវបានបំពេញស្ទើរតែទាំងអស់នៅទួលស្លែង ។ ដោយហេតុផលទាំងនេះហើយដែលខ្ញុំសម្រេចយកឈ្មោះមន្ទីរស-២១ ឈ្មោះសន្តិបាល និងឈ្មោះទួលស្លែង មកប្រើជំនួសគ្នាទៅវិញទៅមក ។

កម្ពុជាប្រជាធិបតេយ្យពុំមានក្រមច្បាប់និងប្រព័ន្ធតុលាការទេ ។ ថ្វីបើបេសកកម្មនិងភារកិច្ចអ្នកធ្វើការនៅមន្ទីរស-២១ពុំមានចែងក្នុងច្បាប់ក៏ពិតមែន ប៉ុន្តែយើងអាចសង្កេតឃើញថា បេសកកម្មនិងភារកិច្ចទាំងនេះមានលក្ខណៈប្រហាក់ប្រហែលនឹងបេសកកម្មនិងភារកិច្ចរបស់ប៉ូលីសសម្ងាត់សូវៀត ដែលមានចែងក្នុងច្បាប់ចុះខែកុម្ភៈ ឆ្នាំ១៩៣៦ ដែរ ។ តាមច្បាប់នេះ ប៉ូលីសសម្ងាត់សូវៀតមានភារកិច្ច «លាតត្រដាងនិងប្រឆាំងទប់ទល់រាល់ទិន្នាការ និងការវិវឌ្ឍ ដែលប្រឆាំងនឹងរដ្ឋហើយត្រូវចាត់ គ្រប់វិធានការដែលខ្លួនយល់ថាចាំបាច់និងមានប្រសិទ្ធិភាពដើម្បីសម្រេចគោលដៅនេះ» ។

បើនិយាយឲ្យកាន់តែច្បាស់ជាងនេះទៀត ស-២១មានលក្ខណៈជាកន្លែងសម្រាប់សួរចម្លើយនិងធ្វើទារុណកម្មជាជាងកន្លែងសម្រាប់ឃុំឃាំងមនុស្ស ។ ទោះបីជាអ្នកទោសត្រូវបានឃុំឃាំងនិងធ្វើទណ្ឌកម្មនៅទីនោះ ប៉ុន្តែពុំមាននរណាម្នាក់ធ្លាប់ត្រូវបានដោះលែងឡើយ ។ មន្ទីរស-២១ត្រូវបាន «របបខ្មែរក្រហម» ប្រើប្រាស់ក្នុងគោលបំណងចម្បងសម្រាប់បញ្ជូនមនុស្សទៅរកសេចក្តីស្លាប់ ។ មនុស្ស២នាក់ដែលមាននាទីគ្រប់គ្រងសន្តិបាលរាយការណ៍ផ្ទាល់ជូនក្រុមអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលគេស្គាល់ថាជាមជ្ឈិមបក្ស ឬក្បាលម៉ាស៊ីនសម្រាប់សមាជិកបក្ស និងជាអគ្គការលើអគ្គការ ឬបងខាងលើសម្រាប់អ្នកមិនមែនជាសមាជិក ។ មជ្ឈិមបក្សជាខួរក្បាលរបស់ប្រទេសជាតិទាំងមូល ។ សមាជិកមជ្ឈិមបក្សត្រូវបានផ្លាស់ប្តូរជារឿយៗ លើកលែងតែសមាជិកដែលមានឋានៈខ្ពស់បំផុតដូចជា ប៉ុល ពត, នួន ជា, តាម៉ុក, សុន សេន និង ខៀវ សំផន ដែលបានរក្សាសមាជិកភាពរបស់ខ្លួនពេញមួយរបបនោះនិងរហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ ។ សមាជិកកំពូលទាំងនោះមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធបំផុតជាមួយប្រតិបត្តិការរបស់ស-២១ ។ **(នៅមានត)**



# គ្រោះថ្នាក់នៃអព្យាក្រឹតភាព

## ការបែកបាក់ទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិក ឆ្នាំ១៩៦៥

***(តពីលេខមុន)*** ប្រសិនជាពុំមានការរីកវិវឌ្ឍក្នុងការដោះស្រាយបញ្ហាវាយទន្ទ្រានតាមព្រំដែនកម្ពុជាទាំងនេះទេ ចលនាទាមទារយូរអង្វែងរបស់ទ្រង់ សីហនុ ឲ្យមានសន្និសីទក្រុងហ្សឺណែវអំពីបញ្ហាកម្ពុជានឹងមានជាបន្ត ។ ការអំពាវនាវថ្មីឲ្យមានសន្និសីទបែបនេះបានលេចចេញពីសន្និសីទប្រជាជនឥណ្ឌូចិនដែលឧបត្ថម្ភដោយទ្រង់សីហនុ ។ បន្ទាប់ពីបរាជ័យនាឆ្នាំ១៩៦៤ ទ្រង់បានកោះប្រជុំសន្និសីទនេះនាខែកុម្ភៈ ឆ្នាំ១៩៦៥ ក្នុងការទទួលបាននូវការសន្យាដ៏ពេញចិត្តពីសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តអាស៊ីភាគអគ្នេយ៍របស់អាមេរិកចំពោះការគោរពនូវអព្យាក្រឹតភាពនិង បូរណភាពដែនដីរបស់កម្ពុជា ។ ទ្រង់ សីហនុ សង្ឃឹមថារកឃើញមធ្យោបាយក្នុងការកម្រិតការប្រយុទ្ធគ្នាក្នុងតំបន់នឹងសម្រេចបាននូវការធានាអព្យាក្រឹតភាពនិងបូរណភាពដែនដីនៃប្រទេសរបស់ព្រះអង្គដែលចង់បានជាយូរយារណាស់មកហើយ ។ អ្នកចូលរួមសំខាន់បំផុតក្នុងសន្និសីទប្រជាជន ឥណ្ឌូចិន គឺរណសិរ្សមាតុភូមិវៀតណាមខាងជើង និងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង ។ ប៉ុន្តែមានក្រុមឆ្វេងនិយម និងអព្យាក្រឹតនិយមផ្សេងទៀតជិត៤០មកពីប្រទេសកម្ពុជា ឡាវ និងវៀតណាមបានចូលរួមក្នុងសន្និសីទនោះដែរ ។

ដោយពុំមានការដកចេញទាំងស្រុងនូវវត្តមានអាមេរិក វៀតណាមខាងជើង រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង និងចិន ពុំបានចាប់អារម្មណ៍ធ្វើការចរចារកដំណោះស្រាយក្នុងប្រទេសវៀតណាមឡើយ ។ ដោយសារមូលហេតុនេះសន្និសីទប្រជាជនឥណ្ឌូចិនដែលរៀបចំឡើងដោយទ្រង់ សីហនុ បានទទួលបរាជ័យក្នុងការអំពាវនាវឲ្យមានសន្និសីទអន្តរជាតិថ្មីមួយដើម្បីដោះស្រាយបញ្ចប់សង្គ្រាមនៅវៀតណាម ។ នេះគឺជាការខកចិត្តមួយរបស់ទ្រង់ សីហនុ ព្រោះទ្រង់ខ្លាចឥទ្ធិពលនៃជ័យជម្នះទាំងស្រុងរបស់វៀតណាមខាងជើង ថ្វីបើទ្រង់មាននិន្នាការប្រឆាំងអាមេរិកយ៉ាងខ្លាំងក្លាក៏ដោយ ។ ទ្រង់ សីហនុ បានថ្លែងទៅកាន់អ្នកយកពត៌មានថា ចំពោះកម្ពុជាពួកកុម្មុយនិស្តវៀតណាមខាងជើងគឺអាក្រក់បំផុត «អាក្រក់ជាងចិននិងរុស្ស៊ី» ។ ពួកអាមេរិកបានសម្តែងនូវការពេញចិត្តចំពោះបរាជ័យដ៏ប្រត្យក្សនេះ ។ មន្ត្រីអាមេរិក លោក ប៉ែចេសិន បានសួរអ្នកការទូតអាមេរិកដែលបានមកជួបជុំគ្នាក្នុងប្រទេសហ្វីលីពីនថា «តើនេះជាមេរៀនដ៏ល្អទៅថ្ងៃមុខសម្រាប់ទ្រង់សីហនុឬ?» ។ ទោះបីជាយ៉ាងនេះក្តី សន្និសីទបានទ្រទ្រង់នូវបំណងមួយផ្សេងទៀតរបស់ទ្រង់ សីហនុ គឺការអំពាវនាវឲ្យមានសន្និសីទហ្សឺណែវថ្មីមួយសម្រាប់កម្ពុជា ។

គំនិតថ្មីបង្កើតឲ្យមានសន្និសីទអន្តរជាតិអំពីបញ្ហាកម្ពុជាបានស្ថិតនៅទ្រឹងគ្មានសកម្មភាពអស់រយៈពេល១ឆ្នាំ ហើយចម្លើយដំបូងរបស់លោក ប៉ែចេសិន ចំពោះការអំពាវនាវថ្មីនេះគឺ «វាហាក់ដូចជាមានកម្លាំងជំរុញពីក្រោយតិចជាងករណីមុនៗក្នុងអតីតកាល» ។ ប៉ុន្តែនៅថ្ងៃ៣មេសា (ឆ្នាំ១៩៦៥) ជាកិច្ចឆ្លើយតបចំពោះសំណូមពររបស់កម្ពុជាដែលសុំឲ្យមានសហប្រធានសម្រាប់សន្និសីទក្រុងហ្សឺណែវ ចក្រភពអង់គ្លេស និងសហភាពសូវៀតបានផ្តល់ការយល់ព្រមចំពោះគោលគំនិតនេះ ។ ភ្លាមៗនោះអង់គ្លេសក៏បានយល់ព្រមជាគោលការណ៍ចំពោះគំនិតបង្កើតឲ្យមានសន្និសីទអន្តរជាតិអំពីបញ្ហាកម្ពុជាដែរ ។

ឥរិយាបថដែលសហរដ្ឋអាមេរិកបានឆ្លើយតបនឹងសំណើនេះបានធ្វើឲ្យមានភាពខ្វែងគំនិតគ្នាក្នុងសហគមន៍ការទូតអាមេរិក ។ ស្ថានទូតអាមេរិកប្រចាំក្រុងព្រៃនគរ និងបាងកក បានចេញសេចក្តីព្រមានធ្ងន់ៗថា ការយល់ព្រមរបស់អាមេរិកចំពោះសន្និសីទបែបនេះគឺជាសញ្ញាមួយនៃភាពទន់ខ្សោយ ។ រដ្ឋាភិបាលក្រុងព្រៃនគរក៏ធ្វើការជំទាស់ខ្លាំងក្លាដែរចំពោះរឿងនេះ ។ ចំណែកឯក្រុងភ្នំពេញឯណោះវិញ លោក ប៉ែចេសិន បានគិតថាការឆ្លើយតបជាវិជ្ជមានរបស់សហរដ្ឋអាមេរិក «ប្រហែលជាអាចជួយស្រោចស្រង់» ទំនាក់ទំនងរវាងអាមេរិកនិងកម្ពុជាបាន ។ ចំពោះប្រទេសកាណាដានិងបារាំងវិញ ប្រទេសទាំងពីរនេះបានផ្តល់នូវចម្លើយគាំទ្រចំពោះសន្និសីទនេះ ។

ថ្វីបើមានការខ្វែងគំនិតគ្នាក្តី ក្រសួងការបរទេសមាននិន្នាការគាំទ្រដោយផ្តល់ប្រសិទ្ធិភាពដល់សន្និសីទនេះ ។ សំខាន់បំផុត

គឺការថ្លែងតាមកញ្ចក់ទូរទស្សន៍របស់ប្រធានាធិបតី លីនដុន ចនសុន (ក្នុងអាណត្តិចន្លោះឆ្នាំ១៩៦៣-៦៩) នៅសកលវិទ្យាល័យ ចនហបគីន សហរដ្ឋអាមេរិក នាថ្ងៃទី៧ ខែមេសា ក្នុងនោះ លោកប្រធានាធិបតីបានសុខចិត្តចូលរួមក្នុង «ការពិភាក្សាដោយគ្មានលក្ខខណ្ឌ» អំពីបញ្ហាវៀតណាម ។ តើសហរដ្ឋអាមេរិកអាចបដិសេធមិនពិភាក្សាអំពីស្ថានការណ៍របស់កម្ពុជាដែលធ្វើឲ្យមានភាពប្រទូស្តរាយតិចតួចជាងបញ្ហាវៀតណាមបានទេ? ជាប្រតិកម្មតបនឹងសំណើរបស់លោកប្រធានាធិបតី មានមតិលើកឡើងថា សន្និសីទអាចផ្តល់ឲ្យពួកកុម្មុយនិស្តនូវមធ្យោបាយការពារមុខមាត់របស់ខ្លួនតាមរយៈការពិភាក្សាមុនពេលសន្និសីទនោះមកដល់ ។ ម្យ៉ាងទៀតសន្និសីទនេះក៏ផ្តល់ផងដែរនូវមធ្យោបាយការពារមុខមាត់ចំពោះការមិនអនុញ្ញាតឲ្យរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងចូលរួមក្នុងការជជែកពិភាក្សាបែបនេះដោយសារចលនានេះមិនបានចូលរួមក្នុងសន្និសីទហ្សឺណែវឆ្នាំ១៩៥៤ ។

សហរដ្ឋអាមេរិកនៅតែមានការប្រយ័ត្នប្រយែង ។ ក៏ដូចពេលមុនដែរ សហរដ្ឋអាមេរិកសង្ឃឹមថា កិច្ចព្រមព្រៀងលើបញ្ហាសំខាន់ៗត្រូវបានធ្វើឡើងក្រៅផ្លូវការស្រេចបាច់ទៅហើយ ដូច្នេះសន្និសីទពុំអាចធ្វើឲ្យមានអ្វីច្រើនលើសពីការគ្រាន់តែផ្តល់សច្ចាប័នលើការស្រុះស្រួលគ្នាដែលបានសម្រេចជាមុនឡើយ ។


កុម្មុំនីស្ដ កុម្មុំនីស្ដរី សាលាសង្គមក្នុងរបប លន់ ណុល

ជាក់ស្តែង រដ្ឋាភិបាលអង់គ្លេសបម្រុងតែនឹងបញ្ជូនអតីតរដ្ឋមន្ត្រីការបរទេសរបស់ខ្លួន ប៉ាទ្រីក ហ្គរ៍ឌិន វ៉ករ មកកាន់តំបន់អាស៊ី-អគ្នេយ៍ដើម្បីពិនិត្យមើលថាតើសន្និសីទអំពីកម្ពុជា ឬខ្សាវអាចនាំទៅដល់ការបើកកិច្ចពិភាក្សាអំពីបញ្ហាវៀតណាមដែរឬទេ ។ សហរដ្ឋអាមេរិកបានស្នើថា បេសកកម្មរបស់ ហ្គរ៍ឌិន វ៉ករ គួរត្រូវកែតម្រូវដោយធ្វើការស្ទាបស្ទង់ប្រតិកម្មរបស់បណ្តារដ្ឋដែលពាក់ព័ន្ធ ដើម្បីឲ្យដឹងថាតើអាចមានការស្រុះស្រួល គ្នាអំពី «បញ្ហាព្រំដែនកម្ពុជាឬទេ» ។

សូម្បីតែការជូនយោបល់បែបនេះក៏ទទួលនូវការទិតៀនពីសំណាក់ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំក្រុងបាងកក ហ្គ្រាហាម ម៉ាទីន ដែលយល់ថាគំនិតរបស់ ហ្គរ៍ឌិន វ៉ករ ដែលបានថ្លែងទៅកាន់ប្រជាជនថៃ អំពីបញ្ហាព្រំដែនមានលក្ខណៈគ្រោះថ្នាក់យ៉ាងប្រាកដ ។ នៅឯក្រុងព្រៃនគរឯណោះវិញ លោកឯកអគ្គរដ្ឋទូតអាមេរិក ម៉ាក្សវែល ថៃល័រ ពុំសាទរចំពោះចលនាណាមួយដែលនាំទៅដល់ការបង្កើតឲ្យមានសន្និសីទទេ ប៉ុន្តែពេញចិត្តចំពោះបេសកកម្មរបស់ ហ្គរ៍ឌិន វ៉ករ ព្រោះគាត់យល់ថាការពិតវាគឺជាមធ្យោបាយពន្យារពេលមួយទេ ។ ថ្ងៃបន្ទាប់នោះ រដ្ឋមន្ត្រីការបរទេសអាមេរិក រ៉ាស់ និង ចច ប៊ុនឌី «ទីប្រឹក្សាជំនិតរបស់ប្រធានាធិបតីកេណ្ណឌី» បានពិភាក្សាអំពីបេសកកម្មនេះជា

មួយនាយករដ្ឋមន្ត្រីចក្រភពអង់គ្លេស ហារ៉ូល វីលសុន និងមន្ត្រីចក្រអង់គ្លេសផ្សេងៗទៀត ។ មន្ត្រីអាមេរិកនិងចក្រភពអង់គ្លេសក៏បានឯកភាពគ្នាថា ហ្វ័រឌិន វ៉ារឃើរ «នឹងចុះស្ទង់ឥរិយាបថក្នុងក្រុងភ្នំពេញ បាងកក និងព្រៃនគរ ហើយពួកនោះបានកំណត់យ៉ាងច្បាស់ដែរថា ហ្វ័រឌិន វ៉ារឃើរ នឹងមិននិយាយក្នុងនាម «ឬតំណាងឲ្យ» សហរដ្ឋអាមេរិកទេ ។ នេះមានន័យថា សេចក្តីសម្រេចយ៉ាងច្បាស់លាស់របស់សហរដ្ឋអាមេរិកអំពីសន្និសីទអាចត្រូវពន្យារយ៉ាងតិចណាស់ក៏ពីរសប្តាហ៍ដែរ ដូច្នេះផ្តល់ពេលវេលាដល់ការគិតនិងពិភាក្សាថែមទៀត ។

ថ្វីបើមានការពិភាក្សារវាងលោក រ៉ាស់ និង ប៊ុនឌី ជាមួយនាយករដ្ឋមន្ត្រីចក្រភពអង់គ្លេស វីលសុន អំពីបេសកកម្មរបស់ ហ្វ័រឌិន វ៉ារឃើរ ក្តី ក្រសួងការបរទេសចក្រភពអង់គ្លេសយល់ថា ជំហររបស់អាមេរិកធ្វើឲ្យមានភាព «រំជើបរំជួល» ។ លោករដ្ឋមន្ត្រីការបរទេសចក្រភពអង់គ្លេស ម៉ៃឃើល ស្ទេវត យល់ថា សហរដ្ឋអាមេរិកកំពុងតែបង្កការរាំងស្ទះជាថ្មីទៀត ហើយលោកបារម្ភខ្លាចសូវៀតដកសំណើរបស់ខ្លួនវិញ ។ រដ្ឋមន្ត្រីអាមេរិកបានរាយការណ៍នៅក្រុងឡុងថាគាត់បាន «គូសបញ្ជាក់រួចហើយថាយើងពុំមានពេលវេលាសម្រាប់លេងល្បែងជាមួយនឹងគំនិតសន្និសីទទេ ។ ការទាមទារឲ្យមានភាពប្រញាប់ប្រញាល់របស់ ស្ទេវត មានលក្ខណៈត្រឹមត្រូវ ។ ហើយការឆ្លើយតបជាវិជ្ជមាន និងឆាប់រហ័សរបស់អាមេរិកប្រហែលជាអាចទប់ស្កាត់បាតុកម្មនៅទូតអាមេរិកនិងការបែកបាក់ទំនាក់ទំនងនាពេលក្រោយមក ។

នៅគ្រានោះ ហ្វ័រឌិន វ៉ារឃើរ បានចាប់ផ្តើមបំពេញបេសកកម្មរបស់គាត់ ។ ក្នុងប្រទេសថៃ ឯកអគ្គរដ្ឋទូតអាមេរិក ម៉ាទីន បានឆ្លើយតបប្រឆាំងចំពោះមន្ត្រីជនជាតិអង់គ្លេសរូបនេះ ។ ម៉ាទីន បានសន្និដ្ឋានថា ហ្វ័រឌិន វ៉ារឃើរ ចង់ឃើញ «ការកើតឡើងនូវសហព័ន្ធរដ្ឋសង្គមនិយមតាមបែបតីតូ (កុម្មុយនិស្ត ប៉ុន្តែឯករាជ្យពីប្លុកកុម្មុយនិស្តរបស់សហភាពសូវៀត) ក្នុងប្រទេសវៀតណាម ។ ជាលទ្ធផលដែលឯកអគ្គរដ្ឋទូតអាមេរិក ម៉ាទីន យល់ថា ជាការធ្វើឲ្យអាមេរិកបរាជ័យដ៏ខ្ទេចខ្ទាំគ្រប់ទិសទី និងថែមទាំងជម្រុញឲ្យមានសង្គ្រាមរំដោះជាតិក្នុងទ្វីបអាហ្វ្រិក និងអាមេរិកខាងត្បូងទៀតផង ។ ការស្នើរបស់ ហ្វ័រឌិន វ៉ារឃើរ ឲ្យមានការកាត់បន្ថយសកម្មភាពយោធាអាមេរិកក្នុងប្រទេសវៀតណាម ពិសេសទាក់ទងទៅនឹងការទម្លាក់គ្រាប់បែកនៅវៀតណាមខាងជើង ក៏ធ្វើឲ្យលោកអគ្គរដ្ឋទូត ម៉ាទីន មានការខឹងសម្បារយ៉ាងខ្លាំង ។ ទាក់ទងនឹងបញ្ហាកម្ពុជា លោកឯកអគ្គរដ្ឋទូត ម៉ាទីន បានទាយទុកថា ប្រសិនបើថៃមានអារម្មណ៍ថាខ្លួនត្រូវបានគំរាមកំហែងដោយសន្និសីទដែលបានស្នើឡើងនេះ ថៃនឹងដកការកំហិតរបស់ខ្លួនចំពោះសកម្មភាពខ្មែរសេរី និងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីឲ្យមានការ «ផ្លាស់ប្តូររបបគ្រប់គ្រងក្នុងប្រទេសកម្ពុជាជាក់ជាមិនខាន» ។

រដ្ឋមន្ត្រីការបរទេសអាមេរិក លោក រ៉ាស់ ខ្លួនឯងនៅតែមានការប្រយ័ត្នប្រយែង ។ ប៉ុន្តែកម្លាំងជម្រុញកំពុងចាប់ផ្តើមងាកទៅរកការគាំទ្រសន្និសីទអំពីបញ្ហាកម្ពុជា ។ ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំប្រទេសឥណ្ឌា លោក ឆេស្ទឺ មូល បានបញ្ជូនសារទូរលេខមួយដែលមានសេចក្តីថា ការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះសន្និសីទកម្ពុជាអាចជួយផ្សះផ្សាទំនាក់ទំនងដែលកំពុងស្ថិតនៅក្នុងភាពតានតឹងជាមួយឥណ្ឌា ។ ឯកអគ្គរដ្ឋទូតអាមេរិក ណេវិន បានតបពីប្រទេសភូមាមកថា ចិនមើលឃើញថាសន្និសីទកម្ពុជាជាជំហានទីមួយឆ្ពោះទៅរកការដោះស្រាយដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាម ។ សំខាន់ជាងនេះទៅទៀតលោក ចេម ថមសុន និង ឆេស្ទឺ ខូភឺ សន្និដ្ឋានថាការទទួលយកសន្និសីទនេះមានគុណសម្បត្តិច្រើនជាងគុណវិបត្តិ ។ សូម្បីតែមន្ត្រីថៃក៏បានបង្ហាញដែរថាប្រទេសថៃអាចយល់ព្រមចំពោះការបង្កើតឲ្យមានសន្និសីទដែលធ្វើឲ្យអគ្គរដ្ឋទូតអាមេរិក ម៉ាទីន មានការបារម្ភយ៉ាងពិតប្រាកដ ។

កត្តាបន្ថែមដែលគាំទ្រដល់ការទទួលយករបស់អាមេរិកគឺរដ្ឋាភិបាលរបស់លោកប្រធានាធិបតី ចនសុន ត្រូវការការគាំទ្រចំពោះការពង្រីកសង្គ្រាមរបស់អាមេរិកក្នុងប្រទេសវៀតណាម ។ លោករដ្ឋមន្ត្រីការបរទេសអាមេរិក រ៉ាស់ ទទួលស្គាល់ថា «យើងអាចមានការលំបាកក្នុងការឆ្លើយថា «ទេ» ចំពោះសន្និសីទដែលទាក់ទងដល់សេចក្តីត្រូវការរបស់យើងផ្ទាល់ក្នុងការប្រមូលផ្តុំការគាំទ្រក្នុងស្រុកនិងអន្តរជាតិសម្រាប់អ្វីដែលហាក់ដូចជាការកើនឡើងមិនអាចចៀសផុតនៃកិច្ចប្រឹងប្រែងរបស់យើងក្នុងតំបន់អាស៊ី-អគ្នេយ៍» ។ **(នៅមានត)** **វ៉ែយនគុន វ៉ែ្លមម័រ**

# គំរូមួយនៃភ័ស្តុតាងឯកសារដែលធ្លាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

## (ភាគ២)

### មន្ទីរស-២១ ការវិនិច្ឆ័យផ្អែកតាមក្រដាសស្នាមទាក់ទងនឹងកម្មាភិបាលខ្មែរក្រហម

សំណុំឯកសារ «ចម្លើយសារភាព» តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានប្រភពដើមចេញពីមន្ទីរស-២១ ដែលមានចំណារបញ្ជាក់ការចម្លងជូន និងផ្ញើជូនទៅកម្មាភិបាលនានាដទៃទៀត បានធ្វើឲ្យការអះអាងរបស់ នួន ជា តាម៉ុក និង អៀង សារី ថាពួកខ្លួនពុំបានដឹង និងគ្មានទោសពៃរ៍ទាល់តែសោះ គ្មានមូលដ្ឋានមាំដើម្បីគាំទ្រការអះអាងបែបនេះតទៅទៀត ។ មិនតែប៉ុណ្ណោះឯកសារចម្លើយសារភាពទាំងនោះបានជួយឲ្យសំណុំភ័ស្តុតាងប្រឆាំងនឹង កែ ពក កាន់តែមានភាពរឹងមាំទៀតផង ។

សំណុំឯកសារនៅមជ្ឈមណ្ឌលកម្ពុជារួមមាន «ចម្លើយសារភាព» ឬឯកសារមន្ទីរស-២១ ដែលមានលក្ខណៈស្រដៀងគ្នានេះ (ឧទាហរណ៍របាយការណ៍ស្តីអំពី «ប្រវត្តិរូប» នៃកម្មាភិបាលដែលត្រូវបានចាប់ដាក់មន្ទីរឃុំឃាំង) ដែលត្រូវបានចារសម្រាប់ផ្ញើជូនទៅមនុស្សចំនួន២០រូប រួមបញ្ចូលទាំងប្រធានមន្ទីរស-២១ ឌុច និង សុន សេន (ស្លាប់នៅឆ្នាំ១៩៩៧) ។ ក្នុងចំណោមមនុស្ស១៨រូបទៀត មនុស្សប្រាំនាក់ដែលនៅរស់នាពេលបច្ចុប្បន្នគឺ នួន ជា, តាម៉ុក, អៀង សារី, កែ ពក និង ស៊ូ មេ៉ត ។ «ចម្លើយសារភាព» ចំនួន២៧ មានចំណារបញ្ជាក់ច្បាស់ថា ផ្ញើជូនទៅ នួន ជា ច្រើនជាងអ្នកដទៃទៀតក្នុងចំណោមមនុស្ស១៨រូបនេះ រួមបញ្ចូលទាំង ប៉ុល ពត ដែលត្រូវបានចារថា «ផ្ញើជូន» ។ «ចម្លើយសារភាព» តែមួយគត់ដែលចំណារនោះដាក់ថា ផ្ញើជូនឈ្មោះ ប៉ុល ពត តែម្តង ។ ចម្លើយសារភាពចំនួន៧ទៀត មានចំណារផ្ញើជូនទៅតាម៉ុក ចម្លើយសារភាព២ផ្ញើជូន អៀង សារី ចម្លើយសារភាព៤ ផ្ញើជូន កែ ពក និង៧ទៀត ផ្ញើជូន ស៊ូ មេ៉ត ។ ជាបន្ថែម «ចម្លើយសារភាព» ចំនួន៣៣ មានចំណារផ្ញើជូនទៅ «អង្គការ» ហើយនិងចម្លើយសារភាព២១ទៀតផ្ញើជូនទៅ «បង» ដែលអាចមានន័យថា ប៉ុល ពត ឬ នួន ជា ឬទាំងពីរ ។ ស្រដៀងគ្នានេះដែរ «ចម្លើយសារភាព» ចំនួន៩ មានចំណារផ្ញើជូនភូមិភាគកណ្តាលដោយពុំមានអ្វីបញ្ជាក់បន្ថែមទៀត ហើយចម្លើយសារភាពទាំងនេះអាចត្រូវបានផ្ញើជូន កែ ពក ។ ដូច្នេះសំណុំឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថា នួន ជា អាចបានបំពេញតួនាទីយ៉ាងហោចណាស់ជាតួនាទីដ៏សំខាន់មួយក្នុងការចាត់ការចំពោះ «ចម្លើយសារភាព» ទាំងនោះដូចជា ប៉ុល ពតដែរ ហើយប្រហែលជាមានតួនាទីសំខាន់ជាង ប៉ុល ពត ទៀតផង ។ ភ័ស្តុតាងឯកសារនេះ



កែ ពក

ទំនងជាបានគាំទ្រសេចក្តីថ្លែងការណ៍របស់ ឌុច ទៅកាន់អ្នកកាសែតនានាថា «នួន ជា គឺជាមនុស្សដ៏សំខាន់ក្នុងការកាប់សម្លាប់យ៉ាងវគ្គាល» នៅមន្ទីរស-២១ ពីព្រោះ នួន ជា មានការពាក់ព័ន្ធដោយផ្ទាល់នឹងការកាប់សម្លាប់ភាគច្រើន ច្រើនជាង ប៉ុល ពត ទៅទៀត ។ សណ្ឋាននៃការផ្ញើ «ចម្លើយសារភាព» សម្រាប់ផ្ញើជូនក៏បានចង្អុលពីតួនាទីដ៏សំខាន់មួយសម្រាប់លេខាភូមិភាគដូចជា តាម៉ុក និង កែ ពក នៅក្នុងការត្រួតពិនិត្យចម្លើយសារភាពទាំងនេះ ហើយបង្ហាញថា អៀង សារី ក៏មានការពាក់ព័ន្ធក្នុងបញ្ហាទាំងនេះដែរ ។

### «ចម្លើយសារភាព» និងការជីងពុដែលនាំឲ្យមានពិរុទ្ធភាពៈ នួន ជា, កែ ពក, តាម៉ុក, អៀង សារី, ស៊ូ ម៉េត

តាមពិត បើពិចារណាទៅលើលក្ខខណ្ឌនៃការបង្ខិតបង្ខំដើម្បីជម្រិតយកចម្លើយសារភាពទាំងនោះ គ្មានអ្វី «នៅក្នុងចម្លើយសារភាពទាំងនោះ» ដែលតុលាការត្រឹមត្រូវមួយអាចទទួលយកបានជាភ័ស្តុតាងប្រឆាំងនឹងជនទាំងឡាយដែលបានផ្តល់ «ចម្លើយសារភាព» ដែលទំនងជាបង្ខំឲ្យធ្វើឡើងក្នុងគោលដៅបង្ហាញថាជាការសារភាពពិតមែន ។ ដូចដែលលោក ទីតែម៉ បានគូសបញ្ជាក់រួចមកហើយថា «ភ័ស្តុតាង...ដែលទទួលបានដោយមធ្យោបាយនានា» ដូចជាការធ្វើទារុណកម្មដែល«មិនស្របទៅតាមគោលការណ៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិ» ហើយដែល «នាំឲ្យមានការមន្ទិលសង្ស័យជាច្រើន» អំពីភាពអាចជឿជាក់បាននៃភ័ស្តុតាង «ដែលជុយស្រឡះនិងបង្ខូចតម្លៃភ័ស្តុតាង» នៃការវិនិច្ឆ័យទោសជនទាំងឡាយណាដែល «បានសារភាព» ។ ផ្ទុយទៅវិញក្នុងករណីជាក់លាក់ដែល «ចម្លើយសារភាពទាំងនេះ» មានភ័ស្តុតាងបញ្ជាក់ថាមធ្យោបាយបង្កើតចម្លើយសារភាពទាំងនោះរំលោភបំពានច្បាប់មនុស្សធម៌អន្តរជាតិដូចជាអំពើទារុណកម្មដើម្បីជម្រិតយកចម្លើយសារភាព នោះចម្លើយសារភាពទាំងនេះយ៉ាងហោចណាស់ជា «ភ័ស្តុតាង» ដ៏មានសុពលភាព «ប្រឆាំងនឹងបុគ្គលទាំងឡាយ» ដែលរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិនោះ ។ ហេតុដូច្នេះ លោក ទីតែម៉ បានធ្វើការសន្និដ្ឋានថា «ចម្លើយសារភាពទាំងនេះ» គួរតែ «ក្នុងកម្រិតអប្បបរមាបំផុតត្រូវបានចាត់ទុកថាអាចទទួលយកបានសម្រាប់បម្រើគោលដៅនៃការប្រមូលភ័ស្តុតាង» ដើម្បីបង្ហាញថា «មន្ត្រី» បក្សកុម្មុយនិស្តកម្ពុជាដែលនៅរស់ «បានទទួលច្បាប់ចម្លងនៃចម្លើយសារភាពទាំងនេះ» «ហើយប្រហែលជាអាចត្រូវបានចាត់ទុកថាជាភ័ស្តុតាងថាអំពើឃោរឃៅព្រៃផ្សៃនានាត្រូវបានប្រព្រឹត្តនៅក្នុងការជម្រិតយក»ចម្លើយសារភាពទាំងនោះ ។ ជាការពិតណាស់ឯកសារមួយចំនួនដែលមានចំណារផ្ញើជូនទៅកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ ដែលនៅរស់រួមមានទាំងការកត់សម្គាល់បន្ថែមពីអ្នកសួរចម្លើយ ដោយបាននិយាយបញ្ជាក់យ៉ាងច្បាស់ៗថា ទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីបង្ខំឲ្យអ្នកទោស «សារភាព» ។

**(នៅមានត)**

**ស៊ីច ហេង៉រ**



គំនរឆ្អឹងជនរងគ្រោះដែលត្រូវបាន គាស់ពីរណ្តៅសាកសពដើមទសវត្សរ៍ទី៨០



# ទារុណកម្ម

**ក) គាលការណ៍ច្បាប់ទូទៅ និងបទដ្ឋានដាច់ខាត**

ការធ្វើទារុណកម្មតំណាងឲ្យបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋមួយចំនួនទៀតដែលសហគមន៍អន្តរជាតិចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជាឧក្រិដ្ឋកម្មប្រឆាំងនឹងគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិកើតដោយទំនៀមទម្លាប់ដែលចងរដ្ឋទាំងអស់ឲ្យមានកាតព្វកិច្ចគោរពអនុវត្ត ។ តុលាការឧទ្ធរណ៍របស់សហរដ្ឋអាមេរិកបានទទួលស្គាល់សញ្ញាណនេះនៅក្នុងរឿងក្តីរវាងលោក ហ្វីឡាទីក និង ប៉េណា អ៊ីរ៉ាឡា ( 630 F.2d 876 [2d Cir.1980]) ដោយធ្វើការសន្និដ្ឋានផ្អែកទៅលើអង្គហេតុដែលថាការធ្វើទារុណកម្មគឺត្រូវបានហាមឃាត់ជាចំហ ឬដោយប្រយោលដោយរដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសប្រហែល៥៥ ដោយធម្មនុញ្ញអង្គការសហប្រជាជាតិដោយសេចក្តីប្រកាសរបស់សហប្រជាជាតិជាបន្តបន្ទាប់ សន្ធិសញ្ញា និងកិច្ចព្រមព្រៀងជាអន្តរជាតិជាច្រើនទៀត ។ ទោះបីជាការធ្វើទារុណកម្មត្រូវបានគេទទួលស្គាល់យ៉ាងច្បាស់ថាជាបទដ្ឋានដាច់ខាតមួយក៏ដោយអនុសញ្ញាប្រឆាំងទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្សពុំទាន់បានទទួលស្គាល់ក្នុងឋានៈជាអន្តរជាតិបែបនេះឡើយ ។

**b-អនុសញ្ញាប្រឆាំងទារុណកម្មនិងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស**

កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៥ អង្គការសហប្រជាជាតិបានអនុម័តជាឯកច្ឆ័ន្ទនូវសេចក្តីប្រកាសស្តីពីការការពារសិទ្ធិមនុស្សគ្រប់រូបឲ្យចៀសផុតពីការធ្វើទារុណកម្ម ។ «ក្នុងឆ្នាំ១៩៨១ អង្គការសហប្រជាជាតិបានបង្កើតឡើងនូវមូលនិធិសប្បុរសជនដើម្បីជួយជនរងគ្រោះដោយអំពើទារុណកម្ម ។ ក្នុងឆ្នាំ១៩៩៣ មូលនិធិនេះបានទទួលថវិកាចំនួន២លានដុល្លារសហរដ្ឋអាមេរិកពីបណ្តារដ្ឋចំនួន២៥» ។ សេចក្តីប្រកាសនេះបានជម្រុញឲ្យមហាសន្និបាតរបស់អង្គការសហប្រជាជាតិអនុម័តអនុសញ្ញាប្រឆាំងទារុណកម្មនិងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្សនៅក្នុងឆ្នាំ១៩៨៤ ។ អនុសញ្ញាប្រឆាំងទារុណកម្មនេះបានចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ ។ «ខ» ពីរក្នុងចំណោម«ខ»ផ្តល់ជម្រើសទាំងឡាយនៃអនុសញ្ញានេះគឺមាត្រា២១ និង២២ អនុញ្ញាតឲ្យភាគីរដ្ឋទាំងឡាយទទួលស្គាល់នូវសមត្ថកិច្ចរបស់គណៈកម្មាធិការប្រឆាំងអំពើទារុណកម្មដើម្បីធ្វើការពិចារណា

ពាក្យបណ្តឹងរបស់បុគ្គល ឬរដ្ឋ (ជាប្រទេស) ទាំងឡាយដែលប្តឹងអំពីការរំលោភបំពាននានាដែលប្រព្រឹត្តដោយភាគីរដ្ឋជាហត្ថលេខីនៃអនុសញ្ញាស្តីអំពីការធ្វើទារុណកម្មនេះ ។ ប្រទេសកម្ពុជាបានក្លាយជាប្រទេសហត្ថលេខីចំពោះអនុសញ្ញានេះកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ប៉ុន្តែពុំបានឲ្យសច្ចាប័នចំពោះ «ខ» ទាំងឡាយដែលផ្តល់ជម្រើសទាំងនោះឡើយ ។

គោលដៅនៃអនុសញ្ញានេះគឺមិនមែនដើម្បីបង្កើតឡើងនូវការហាមឃាត់ថ្មីមួយប្រឆាំងនឹងការធ្វើទារុណកម្មនោះទេ ប៉ុន្តែគឺដើម្បីពង្រឹងការហាមឃាត់ដែលធ្លាប់មានពីមុនមកហើយស្តីអំពីការធ្វើទារុណកម្មដែលបានបង្កើតឡើងក្នុងច្បាប់អន្តរជាតិ ។ «ខ»សំខាន់ៗទាំងឡាយនៃអនុសញ្ញានេះមានដូចខាងក្រោមនេះ÷



-កំណត់និយមន័យការធ្វើទារុណកម្មថាជាអំពើទាំងឡាយណាដែលបង្កឲ្យមានការឈឺចាប់ ឬខូចខាតជាដំណំទាំងលើផ្លូវកាយ និងសតិបញ្ញាមកលើបុគ្គលនោះ ឬបុគ្គលទីពីរ ក្នុងគោលបំណងទទួលព័ត៌មាន ឬចម្លើយសារភាពពីបុគ្គលទាំងនោះ ។ នៅពេលដែលអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើងក្រោម ឬដោយការ ញុះញង់ ឬដោយការយល់ព្រម ឬដឹងឮពីមន្ត្រីសាធារណៈម្នាក់ ឬ អ្នកដទៃទៀតដែលមានមុខនាទីជាផ្លូវការ ។ **មាត្រា១ វាក្យខណ្ឌ១**

-ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការដ៏មានប្រសិទ្ធិភាពនានាដើម្បីទប់ស្កាត់រាល់ការធ្វើទារុណកម្មគ្រប់បែបយ៉ាងនៅក្នុងទឹកដីរៀងៗខ្លួន ។ **មាត្រា២ ។**

-ពុំអាចយកលក្ខខណ្ឌលើកលែង ឬបទបញ្ជាពីថ្នាក់លើមកធ្វើជាយុត្តិកម្ម ឬការអះអាងកែតម្រូវចំពោះការធ្វើទារុណកម្ម ការផ្តន្ទាទោស និងការប្រព្រឹត្តផ្សេងទៀតដែលមានលក្ខណៈឃោរឃៅអមនុស្សធម៌ ឬអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្សឡើយ ។ **មាត្រា២ វាក្យខណ្ឌ ២និង៣**

-រាល់ភាគីរដ្ឋទាំងឡាយមិនត្រូវបញ្ជូនបុគ្គលម្នាក់ទៅប្រទេសមួយដែលនៅទីនោះមានលក្ខណៈសម្គាល់ជាមូលដ្ឋានដែលអាចឲ្យជឿបានថា បុគ្គលនោះនឹងត្រូវស្ថិតនៅក្នុងស្ថានការណ៍គ្រោះថ្នាក់នៃការធ្វើទារុណកម្មឡើយ ។ **មាត្រា៣ ។**

-ភាគីរដ្ឋនីមួយៗត្រូវបង្កើតឡើងនូវដែនសមត្ថកិច្ចព្រហ្មទណ្ឌលើការធ្វើទារុណកម្ម និងនាំយកមកកាត់ទោសនូវអ្នកប្រព្រឹត្តអំពើទារុណកម្មដែលចាប់បានក្នុងទឹកដីរបស់ខ្លួន ឬត្រូវធ្វើបត្យាប័នអ្នកទាំងនោះទៅប្រទេសដទៃទៀត ដើម្បីយកទៅកាត់ទោស ។ **មាត្រា៤ និង៥ ។**

-ជនរងគ្រោះដោយអំពើទារុណកម្មត្រូវមានសិទ្ធិធ្វើការប្តឹងផ្តល់នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច និងទទួលសិទ្ធិដែលត្រូវបានផ្តល់ឲ្យក្នុងការទាមទារសំណងការខូចខាត ។ **មាត្រា១៣ និង១៤**

-ចម្លើយសារភាពដែលទទួលបានក្រោមអំពីទារុណកម្មត្រូវទុកជាមោឃៈ ឬដកចេញពីការប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងតុលាការមួយ លើកលែងតែការយកមកប្រើដើម្បីបង្ហាញពីការប្រព្រឹត្តអំពើទារុណកម្ម «ដើម្បីដាក់ទោសលើជនល្មើស» ។ **មាត្រា១៥ ។**

ទោះបីជាប្រទេសកម្ពុជាពុំបានចុះហត្ថលេខាលើអនុសញ្ញាស្តីអំពីការធ្វើទារុណកម្មមុនពេលរបបខ្មែរក្រហមឡើងកាន់អំណាចក៏ដោយ ក៏អាចមានការទាញហេតុផលបញ្ជាក់ថា ការហាមឃាត់

ទាំងឡាយដែលមានចែងក្នុងអនុសញ្ញាទាំងនេះក៏បានចងតាមផ្លូវច្បាប់ឲ្យប្រទេសដែលមិនបានចុះហត្ថលេខាតាមរយៈការហាមប្រាមក្នុងបទដ្ឋានដាច់ខាតដែលហាមការធ្វើទារុណកម្មជាដាច់ខាត ។ ពាក្យថា «កម្រិតនៃការប្រព្រឹត្ត» អាចពង្រីកដែនសមត្ថកិច្ចនៃអនុសញ្ញានេះឲ្យចូលមកធ្វើអន្តរាគមន៍ក្នុងច្បាប់ព្រហ្មទណ្ឌ និងពន្ធនាគារក្នុងស្រុក ប្រសិនបើលក្ខខណ្ឌជីវិតទាំងឡាយនៅក្នុងអគារ ឬស្ថាប័នទាំងឡាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ដូចជាមន្ទីរពេទ្យ និងមជ្ឈមណ្ឌលកុមារកំព្រាត្រូវបានរំលោភបំពានយ៉ាងឃោរឃៅដែលបណ្តាលឲ្យបាត់បង់តម្លៃជាមនុស្ស ។ រដ្ឋទាំងឡាយពុំអាចធ្វើបដិបញ្ញ (ទាត់ចោល) នូវបញ្ញត្តិនៃការហាមឃាត់មិនឲ្យធ្វើទារុណកម្ម និងការប្រព្រឹត្តផ្សេងទៀតដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ឬការប្រព្រឹត្តផ្សេងទៀតដែលមានលក្ខណៈឃោរឃៅបែបនេះ ។

### ក) កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

កតិកាសញ្ញានេះបានចូលជាធរមានកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ។ មាត្រា៧ នៃកតិកាសញ្ញានេះបានចែងថា «គ្មាននរណាម្នាក់ត្រូវទទួលរងនូវការធ្វើទារុណកម្ម និងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តផ្សេងទៀតដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្សឡើយ ។ ជាពិសេសគ្មាននរណាម្នាក់ត្រូវបានគេយកទៅធ្វើការពិសោធន៍បម្រើការស្រាវជ្រាវខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ» ។ កតិកាសញ្ញានេះការពារបុគ្គលទាំងឡាយដែលស្ថិតនៅក្នុងដែនដីនិងដែនសមត្ថកិច្ចនៃរដ្ឋហត្ថលេខីនោះ ។ រដ្ឋទាំងឡាយត្រូវ «ធានាឲ្យប្រាកដ» នូវសិទ្ធិទាំងឡាយដែលទទួលស្គាល់ដោយកតិកាសញ្ញានេះនោះមានន័យថារដ្ឋទាំងឡាយមានកាតព្វកិច្ចទប់ស្កាត់ការរំលោភបំពានលើសិទ្ធិទាំងនេះដោយបុគ្គលក៏ដូចជាមន្ត្រីនៃរដ្ឋទាំងនោះ ។ កាតព្វកិច្ចនេះមិនត្រឹមតែសំដៅទៅលើវិធានការជាវិជ្ជមានទាំងឡាយដែលអនុវត្តដោយមន្ត្រីនៃរដ្ឋទាំងនោះទេ ប៉ុន្តែថែមទាំងសំដៅទៅលើការខកខានមិនបានផ្តល់ឲ្យនូវលក្ខខណ្ឌរស់នៅជាអប្បបរមានៅក្នុងមន្ទីរឃុំឃាំងទាំងឡាយនិងការខកខានមិនបានផ្តល់នូវការព្យាបាលផ្នែកវេជ្ជសាស្ត្រគ្រប់គ្រាន់ ។

ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញានេះកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ ហើយបានក្លាយទៅជាភាគីសមាជិកនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ។ កាលពីឆ្នាំ១៩៨៩ ប្រទេសកម្ពុជាពុំបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមដែលផ្តល់សិទ្ធិដល់ភាគីជាហត្ថលេខីក្នុងការជ្រើសរើស (ភាសាអង់គ្លេសហៅថា Optional Protocol) នៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលផ្តល់សិទ្ធិអំណាចដល់គណៈកម្មាធិការសិទ្ធិមនុស្សដើម្បីទទួល និងពិចារណាអំពីទំនាក់ទំនងនានាពីបុគ្គលទាំងឡាយដែលបានអះអាងថាជាជនរងគ្រោះដោយការរំលោភបំពានលើសិទ្ធិទាំងឡាយដែលបានរៀបរាប់នៅក្នុងកតិកាសញ្ញានេះ ។ ការដាក់ឲ្យអនុវត្តនូវកតិកាសញ្ញានេះពឹងផ្អែកជាចម្បងទៅលើស្ថាប័ន



ជាតិនៃបណ្តារដ្ឋទាំងឡាយ ។ ភាគីរដ្ឋទាំងឡាយត្រូវតែធានាឲ្យប្រាកដថាមនុស្សទាំងឡាយនៅក្នុងដែនដីក្រោមការគ្រប់គ្រងរបស់ខ្លួនដែលជាជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងកតិកាសញ្ញានេះត្រូវទទួលនូវការសងជំងឺចិត្តដ៏សមស្របពីអ្នកដែលរំលោភបំពាន ។ ជាងនេះទៅទៀតគណៈកម្មាធិការសិទ្ធិមនុស្សអាចទទួលដោះស្រាយពាក្យបណ្តឹងទាំងនោះ ។ ភាគីទាំងឡាយក៏អាចចូលជាសមាជិកនៃពិធីសារបន្ថែមខាងលើដែលផ្តល់រដ្ឋនេះនូវដែនសមត្ថកិច្ចចំពោះការរំលោភបំពាននានាដែលបានកើតឡើងនៅក្នុងដែនដីនៃភាគីរដ្ឋមួយទៀតដរាបណាភាគីរដ្ឋទាំងពីរព្រមទទួលយកសមត្ថកិច្ចរបស់គណៈកម្មាធិការសិទ្ធិមនុស្សដើម្បីជំនុំជម្រះពាក្យបណ្តឹងដែលអនុញ្ញាតឲ្យបុគ្គលទាំងឡាយដាក់ពាក្យបណ្តឹងមកគណៈកម្មាធិការនេះចំពោះការរំលោភបំពានលើសិទ្ធិនានាដែលធានាដោយកតិកាសញ្ញានេះ ។ ពាក្យបណ្តឹងទាំងឡាយអាចត្រូវបានអនុញ្ញាតឲ្យប្តឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិក្រោមយន្តការណាមួយក្នុងចំណោមយន្តការទាំងពីរខាងលើនេះបានលុះត្រាតែមធ្យោបាយតាមផ្លូវច្បាប់នៅក្នុងស្រុកត្រូវបានប្តឹងគ្រប់លទ្ធភាពហើយពុំមានប្រសិទ្ធិភាព ។

### ១) ឧបករណ៍ច្បាប់ក្នុងតំបន់ និងអន្តរជាតិដែលហាមឃាត់ការធ្វើទារុណកម្ម

លើសពីកតិកាសញ្ញាខាងលើនេះទៀត នៅមានឧបករណ៍ច្បាប់ក្នុងតំបន់ និងអន្តរជាតិដែលហាមឃាត់ការធ្វើទារុណកម្ម រួមមានសេចក្តីប្រកាសសកលស្តីអំពីសិទ្ធិមនុស្សមាត្រា៥ និងអនុសញ្ញាអឺរ៉ុបស្តីអំពីសិទ្ធិមនុស្សមាត្រា៣រួម ។ ក្រៅពីនេះកម្រិតបទដ្ឋានដាច់ខាតមួយទៅចំពោះការប្រព្រឹត្តមកលើអ្នកទោសចែងថា «ការដាក់ទណ្ឌកម្មវាយដំមកលើរាងកាយ ការដាក់ទណ្ឌកម្មដោយដាក់ក្នុងគុកងងឹត និងការដាក់ទណ្ឌកម្មសាហាវឃោរឃៅអមនុស្សធម៌ ឬអំពើដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ត្រូវហាមឃាត់ជាដាច់ខាតមិនឲ្យយកមកអនុវត្តនៅក្នុងការដាក់ទណ្ឌកម្មលើអ្នកទោសចំពោះជំពូកបទល្មើសនីងវិន័យឡើយ» ។ បទដ្ឋាននេះត្រូវបានអនុម័តជាឯកច្ឆ័នដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ ។ ជាទីបញ្ចប់ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យដែលបង្កើតឡើងនូវដែនសមត្ថកិច្ចរបស់តុលាការយោធាអន្តរជាតិនៅនូរិមប៊ឺក រួមបញ្ចូលនូវការធ្វើទារុណកម្មថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិមួយ ។ មាត្រារួមទី៣នៃអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ស្តីអំពីការការពារជនរងគ្រោះដោយសង្គ្រាម បានហាមឃាត់នូវបទល្មើសដូចខាងក្រោមនៅក្នុងករណីជម្លោះប្រដាប់អាវុធមួយដែលពុំមានលក្ខណៈអន្តរជាតិ និងដែលបានកើតឡើងនៅក្នុងទឹកដីនៃរដ្ឋហត្ថលេខីមួយនៅពេលដែលបទល្មើសទាំងនេះត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងអ្នកចូលរួមក្នុងជម្លោះទាំងនោះ÷

ក. ការប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គលរហូតដល់ធ្វើឲ្យបាត់បង់ជីវិត ជាពិសេសការប្រព្រឹត្តអំពើមនុស្សឃាតគ្រប់បែបយ៉ាងការធ្វើកាយវិកលកម្ម «ការវាយដំប្រំធាក់លើរាយកាយជាទម្ងន់» ការប្រព្រឹត្តសាហាវឃោរឃៅ និងការធ្វើទារុណកម្ម ។

ខ. ការចាប់ធ្វើជាចំណាប់ខ្មាំង

គ. ការប្រព្រឹត្តបែបហិង្សានានាបន្ថុចកិត្តិយសរបស់បុគ្គលដូចជាការធ្វើឲ្យអាម៉ាស់ និងការប្រព្រឹត្តថោកទាបដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ការចេញសាលក្រមកាត់ទោស និងការអនុវត្តការកាត់ទោសប្រហារជីវិត ដោយពុំមានចេញសេចក្តីសម្រេចជាមុនដោយតុលាការដែលមានស្រាប់ និងដោយពុំគោរពនូវនីតិវិធីនានាដែលបានធានាដោយច្បាប់ និងដែលត្រូវបានទទួលស្គាល់ដោយប្រជាជនដែលមានអរិយធម៌ជឿនលឿនថាជានីតិវិធីដែលមិនអាចអត់បានក្នុងដំណើរការកាត់ក្តីយុត្តិធម៌ ។

ក្រោមអនុសញ្ញាក្រុងហ្សឺណែវទាំង៤ ភាគីរដ្ឋទាំងឡាយត្រូវទទួលនូវការដាក់ទណ្ឌកម្មចំពោះភាគីទាំងឡាយដែលរកឃើញថាមានកំហុសរំលោភបំពានអនុសញ្ញានោះធ្ងន់ធ្ងរដោយធ្វើបត្យាប័ន ឬនាំយកជនដៃដល់ទាំងឡាយទៅជំនុំជម្រះក្តីដោយតុលាការក្នុងស្រុករបស់ខ្លួន ។ ការរំលោភបំពានធ្ងន់ធ្ងររួមមានអំពើទាំងឡាយដូចជាៈ ការសម្លាប់ដោយចេតនា ទារុណកម្ម ឬការប្រព្រឹត្តឃោរឃៅអមនុស្សធម៌ រួមទាំងការពិសោធន៍ផ្នែកជីវសាស្ត្រនានាដែលបណ្តាលឲ្យមានការឈឺចាប់ ឬមានរបួសធ្ងន់ធ្ងរដល់រាងកាយ និងសុខភាព ការរំលោភបំពានធ្ងន់ធ្ងរគឺជាបញ្ហាមួយស្ថិតក្នុងដែនសមត្ថកិច្ចជាសកលដូច្នេះរដ្ឋទាំងឡាយណាក៏ដោយក៏មានដែនសមត្ថកិច្ចយកជនប្រព្រឹត្តរំលោភបំពាននោះមកជំនុំជម្រះក្តី ។

**អេលីហ្សាប៊ែត ម៉ាន់ស្កាក់**

# លក្ខខណ្ឌនៃភ័ស្តុតាង

ការកសាងនូវសំណុំភ័ស្តុតាងគឺជាការសំខាន់ណាស់នៅក្នុងដំណើរការជំនុំជម្រះក្តីព្រហ្មទណ្ឌទាំងអស់ ។ ការកាត់ទោសរបបកម្ពុជាប្រជាធិបតេយ្យណាមួយនឹងត្រូវរិះរកបង្កើតឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើឧក្រិដ្ឋនៃបុគ្គលម្នាក់ៗ ។ ជាលទ្ធផលវាជាការចាំបាច់ដើម្បីបង្ហាញភ័ស្តុតាងឲ្យបានគ្រប់គ្រាន់ចំពោះបទល្មើសដែលបានចោទប្រកាន់ទៅលើចុងចោទដែលត្រូវបានចោទថាបានប្រព្រឹត្តបទល្មើសនោះ ។ ដើម្បីដាក់ទោសទៅលើបុគ្គល វាមិនទាន់គ្រប់គ្រាន់ទេដោយគ្រាន់តែបង្ហាញយ៉ាងងាយថាអំពើឧក្រិដ្ឋបានកើតឡើង ។ ភ័ស្តុតាងត្រូវតែផ្សារភ្ជាប់ពីឧក្រិដ្ឋកម្មនោះទៅនឹងបុគ្គលឲ្យបានយ៉ាងច្បាស់ជាទីបំផុតគឺ «**ហួសផុតពីការសង្ស័យដ៏សមហេតុសមផល**» ។

បញ្ហានីតិវិធីត្រឹមត្រូវនៅក្នុងការកាត់ក្តីក្នុងស្រុកតម្រូវឲ្យមានភ័ស្តុតាងដែលមានលក្ខណៈអាចទទួលយកបាន និងជឿទុកចិត្តបានក្នុងកម្រិតខ្ពស់ ។ ជាលទ្ធផលបន្ទុកដ៏ធ្ងន់ត្រូវបានដាក់ទៅលើព្រះរាជអាជ្ញានៅក្នុងនីតិវិធីព្រហ្មទណ្ឌណាក៏ដោយ ។ ក្នុងនាមជាព្រះរាជអាជ្ញាម្នាក់ គឺជាការសំខាន់ណាស់ដែលត្រូវដឹងពីធាតុផ្សំនៃអំពើឧក្រិដ្ឋដែលព្រះរាជអាជ្ញារូបនោះប៉ុនប៉ងបង្ហាញ ។ ព្រះរាជអាជ្ញា ក៏ត្រូវដឹងដែរថាភ័ស្តុតាងប្រភេទណានឹងត្រូវបានទទួលយកហើយភ័ស្តុតាងប្រភេទណានឹងមិនត្រូវបានទទួលយកនៅក្នុងតុលាការ ។ ចំណេះដឹងនេះនឹងជាមាគ៌ា ឬយានសម្រាប់តម្រែតម្រង់ការប្រមូល និងការបង្ហាញភ័ស្តុតាងរបស់ព្រះរាជអាជ្ញា ។

ស្តង់ដា „ខ្នាតគំរូ” នៃភ័ស្តុតាងនៅក្នុងច្បាប់ក្នុងស្រុកៈ

## I. *សេចក្តីផ្តើម*

គោលការណ៍ជាមូលដ្ឋាននៃភ័ស្តុតាងនៅក្នុងវេទិកាច្បាប់ណាក៏ដោយ គឺថាអ្នកវិនិច្ឆ័យអង្គហេតុជា «ចៅក្រម ឬក្រុមប្រឹក្សាចៅក្រម» ត្រូវតែសម្រេចចិត្តលើរឿងក្តី ***ដោយផ្អែកតែលើអ្វីដែលត្រូវបានបង្ហាញនៅក្នុងតុលាការ*** ។

អ្នកវិនិច្ឆ័យអង្គហេតុមិនអាចផ្អែកលើការយល់ដឹងផ្ទាល់ខ្លួន ឬសេចក្តីរាយការណ៍នៅក្នុងកាសែតពេលធ្វើសេចក្តីសម្រេចចិត្តក្នុងរឿងក្តីបានទេ ។ គ្រប់ព័ត៌មានទាំងអស់ដែលប្រើប្រាស់ដើម្បីសម្រេចលើរឿងក្តី ត្រូវតែស្របតាមច្បាប់នៅចំពោះមុខតុលាការ ។

ភ័ស្តុតាងត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអត្ថិភាពនៃអង្គហេតុពិតប្រាកដ ។ មានតែភ័ស្តុតាងដែលទាក់ទងទៅនឹងរឿងក្តីប៉ុណ្ណោះនឹងត្រូវអនុញ្ញាតឲ្យយកចូលក្នុងតុលាការ ។ ជាទូទៅការទាមទារចំពោះភាពទាក់ទងទៅនឹងរឿងក្តីតម្រូវឲ្យមានទំនាក់ទំនងផ្សារភ្ជាប់ពីរវាងភ័ស្តុតាងនិងសំណុំរឿងដែលត្រូវបង្ហាញៈ

១) ត្រូវតែមាន**ទំនាក់ទំនងបញ្ជាក់**រវាងភ័ស្តុតាងនិងអង្គហេតុ ដែលភ័ស្តុតាងត្រូវចង្អុលបង្ហាញទៅលើអង្គហេតុនោះ ។ ភ័ស្តុតាងនឹងត្រូវតែចង្អុលបង្ហាញថាពិត ឬមិនពិត នូវអង្គហេតុមួយចំនួនដែលត្រូវបានលើកឡើងដោយភាគីមួយ ។ ត្រូវតែមានទំនាក់ទំនងយ៉ាងច្បាស់រវាងភ័ស្តុតាងមួយដែលត្រូវបានផ្តល់ជូននិងចំណុចដែលភ័ស្តុតាងនោះលើកឡើង ។

២) ភ័ស្តុតាងត្រូវតែជាក់ស្តែង ។ និយាយម្យ៉ាងទៀតភ័ស្តុតាងត្រូវតែផ្សារភ្ជាប់ពីអង្គហេតុទៅនឹងអង្គច្បាប់ ។

***ភ័ស្តុតាងដោយផ្ទាល់ៈ*** ដោះស្រាយនូវបញ្ហាអង្គហេតុកំពុងជជែកវែកញែក ។

***ភ័ស្តុតាងនិទស្សន៍ ឬភ័ស្តុតាងប្រយោលៈ*** ជាភ័ស្តុតាងពុំអាចដោះស្រាយបញ្ហាកំពុងជជែកវែកញែកបានទេ ប្រសិនបើមិនមានប្រើប្រាស់ហេតុផលបន្ថែមទៀតទៅលើសេចក្តីអះអាងមួយដែលភ័ស្តុតាងនិទស្សន៍នេះសំដៅចង្អុលបង្ហាញ ។

យើងនឹងពិភាក្សាវត្ថុតាងនិងភ័ស្តុតាងជាកសិណ ។

## II. *វត្ថុតាង*

វត្ថុតាងជាភ័ស្តុតាងដែលតុលាការអាចដឹងបានគ្រាន់តែបានឃើញភ្លាម ។ បញ្ហានេះអាចផ្ទុយទៅនឹងភ័ស្តុតាងជាកសិណដែលទាក់ទងទៅនឹងសាក្សីផ្តល់កសិណនៅក្នុងសវនាការដើម្បីធ្វើឲ្យបានច្បាស់នូវការអះអាងអង្គហេតុណាមួយ ។ ជាមួយភ័ស្តុតាងកសិណ អ្នកវិនិច្ឆ័យនៃអង្គហេតុត្រូវតែពឹងផ្អែកលើការអង្កេត ការចងចាំ និងការរៀបរាប់របស់សាក្សី ។ វត្ថុតាងមានពីរប្រភេទៈ

ក) ***ភ័ស្តុតាងជាក់ស្តែងៈ*** ភ័ស្តុតាងដែលជាវត្ថុជាក់ស្តែង

មានតួនាទីពិតប្រាកដមួយចំនួននៅក្នុងសំណុំរឿង ។ ឧទាហរណ៍ៈ អាវុធធ្វើឃាតកម្ម រូបថតសកម្មភាពអំពើឧក្រិដ្ឋ ឬលិខិតស្នាមបញ្ជាឲ្យសម្លាប់នរណាម្នាក់ ។ វត្ថុដែលបង្ហាញជាភស្តុតាងគឺជាវត្ថុដែលបានប្រើប្រាស់នៅក្នុងអំពើឧក្រិដ្ឋជាក់ស្តែង ។

**ខ) ភស្តុតាងចង្អុលបង្ហាញៈ** ជាភស្តុតាងដែលហាក់ដូចជាចង្អុលបង្ហាញបញ្ហាសំខាន់ដល់ការកាត់ក្តីដូចជាផែនទី គំរូសេចក្តីសង្ខេប ។

## III. *ភាពអាចដាក់បញ្ចូលបាននៃភស្តុតាងទៅក្នុងតុលាការ*

មិនមែនគ្រប់ភស្តុតាងទាំងអស់នឹងត្រូវបានដាក់ជូនទៅក្នុងតុលាការនោះទេ ។ មូលដ្ឋានពិតប្រាកដមួយត្រូវតែបានលាតត្រដាងមុនពេលដែលភស្តុតាងមួយនោះត្រូវបានដាក់បញ្ចូលទៅក្នុងតុលាការ ។ និយាយម្យ៉ាងទៀត ភស្តុតាងជាក់ស្តែងនិងភស្តុតាងចង្អុលបង្ហាញត្រូវតែបានបញ្ជាក់ថាពិត មុនពេលភស្តុតាងនោះត្រូវបានដាក់ជូនទៅតុលាការ គឺថាភាគីដែលដាក់ជូនភស្តុតាងត្រូវតែបង្ហាញថាវត្ថុនោះគឺពិតតាមការពោលអះអាង ។ ការបញ្ជាក់ថាការពិតនេះកើតមានឡើងពេលដែលសាក្សីគាំទ្រចំពោះភស្តុតាងនោះ ។ ភាគីម្ខាងទៀតអាចទាញហេតុផលប្រឆាំងចំពោះការបញ្ជាក់ត្រឹមត្រូវនៃភស្តុតាងនេះ ។ ប្រសិនបើភាគីមួយនេះឈ្នះលើការទាញហេតុផល ភស្តុតាងនឹងមិនត្រូវបានដាក់ជូនទៅក្នុងតុលាការទេ ។ ភស្តុតាងទាំងពីរប្រភេទខាងលើនេះ ជាទូទៅមានស្តង់ដា (ឬខ្នាតគំរូ) នៃការទទួលយកដោយតុលាការផ្សេងៗគ្នា ។

### ក) «ខ្នាតគំរូ» នៃភាពអាចទទួលយកដោយតុលាការ

**១) ភស្តុតាងច្បាស់ជាក់ស្តែងៈ** ចំពោះភស្តុតាងជាក់ស្តែង ភាគីដែលដាក់ភស្តុតាងជូន«ទៅក្នុងតុលាការ» ត្រូវតែបង្ហាញថា ភស្តុតាងមួយនោះគឺពិតប្រាកដជាវត្ថុដែលបានប្រើប្រាស់ក្នុងពេលប្រព្រឹត្តអំពើឧក្រិដ្ឋ ។ ឧទាហរណ៍ៈ ព្រះរាជអាជ្ញាត្រូវតែបង្ហាញថាកាំភ្លើងដែលខ្លួនចង់ដាក់ជូនជាភស្តុតាងគឺប្រាកដជាកាំភ្លើងដែលបានប្រើប្រាស់ដោយឧក្រិដ្ឋជន ។ សាក្សីដូចជាអ្នកដែលបានឃើញអំពើមនុស្សឃាត និងប៉ូលិសដែលរកឃើញកាំភ្លើងនៅកន្លែងកើតហេតុនៃអំពើឧក្រិដ្ឋ នឹងត្រូវបានហៅមកឲ្យផ្តល់នូវមូលដ្ឋានចំពោះការដាក់កាំភ្លើងនេះទៅក្នុងភស្តុតាង ។ មានវិធីសាស្ត្រទូទៅពីរបែបសម្រាប់ធ្វើការបញ្ជាក់ថាពិតចំពោះភស្តុតាងច្បាស់លាស់ ។

**ក) អត្តសញ្ញាណកម្មពិសេសតែមួយគត់ៈ** វត្ថុនោះមានតែមួយគត់ក្នុងលក្ខណៈភាពមួយ ហើយកសិណសាក្សីបញ្ជាក់ថាវត្ថុដែលបង្ហាញជាភស្តុតាងនោះមានតែមួយគត់ដូចគ្នាបេះបិទ គឺជាវត្ថុដែលប្រើក្នុងពេលប្រព្រឹត្តិបទល្មើស ។

**ខ) ខ្សែសង្វាក់នៃការរក្សាភស្តុតាងៈ** មនុស្សម្នាក់ៗដែលបានកាន់ ឬទុក ឬផ្តល់នូវភស្តុតាង តាំងពីពេលដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តរហូតដល់ពេលបើកសវនាការ ត្រូវតែផ្តល់ជាកសិណបញ្ជាក់ថាជនល្មើសបានប្រើប្រាស់វត្ថុនោះ ។ ឧទាហរណ៍ៈ ប៉ូលិសបានរកឃើញអាវុធធ្វើឃាតកម្មមួយ ហើយក្រោយមក ប៉ូលីសប្រគល់កាំភ្លើងនោះទៅអង្គភាពស៊ើបអង្កេតដែលប្រគល់បន្តទៅផ្នែកជំនាញកោសល្យវិច័យ ហើយផ្នែកជំនាញកោសល្យវិច័យក៏ប្រគល់បន្តទៅឲ្យជំនាញការ ដេអិនអា DNA (ធាតុផ្សំគីមីដែលមានលក្ខណៈពិសេសដោយឡែកសម្រាប់ជីវិតនីមួយៗមានវត្តមាននៅក្នុងកោសិកានៃសត្វមានជីវិតរួមទាំងមនុស្ស ។ វាអាចត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការកំណត់


អៀង សារី

អត្តសញ្ញាណកម្មតាមរយៈកោសិកាណាមួយដែលបន្សល់ទុកនៅកន្លែងកើតហេតុ ដូចជា ទឹកមាត់ សក់ ឈាម...ជាដើម) រួចហើយប្រគល់ទៅឲ្យមេធាវី ។ បុគ្គលទាំងអស់នេះនឹងត្រូវធ្វើជាកសិណនៅឯតុលាការដើម្បីបង្ហាញថា កាំភ្លើងនៅក្នុងតុលាការជាកាំភ្លើងដែលបានរកឃើញនៅកន្លែងកើតហេតុ ។ ប្រព័ន្ធយ៉ាងល្អិតល្អន់នេះទប់ស្កាត់ការធ្វើឲ្យភ័ស្តុតាងមានលក្ខណៈទន់ខ្សោយ ។ ខ្សែសង្វាក់នៃសាក្សីនឹងត្រូវតែធ្វើកសិណដូចខាងក្រោមៈ

- នៅពេលណា និងតាមរបៀបណា ដែលសាក្សីមានការពាក់ព័ន្ធទៅនឹងវត្ថុតាងនោះ ។

- តើសាក្សីរក្សាទុកវត្ថុតាងនោះដោយរបៀបណាហើយ

- នៅពេលណា និងតាមរបៀបណាដែលសាក្សីប្រគល់វត្ថុតាងនោះទៅឲ្យអ្នកដទៃ



**២) ភ័ស្តុតាងចង្អុលបង្ហាញៈ** ចំពោះភ័ស្តុតាងចង្អុលបង្ហាញភាគីដែលដាក់បញ្ចូលភ័ស្តុតាងត្រូវតែបង្ហាញថា វត្ថុនោះតំណាងឲ្យ ឬចង្អុលបង្ហាញយ៉ាងត្រឹមត្រូវនូវអ្វីដែលភស្តុតាងបែបនេះត្រូវតំណាង ។ ឧទាហរណ៍ៈ ប្រសិនបើគ្មានកាំភ្លើងត្រូវបានរកឃើញព្រះរាជអាជ្ញាអាចយកគំរូនៃកាំភ្លើងមកបង្ហាញថានោះគឺជាប្រភេទកាំភ្លើងដែលត្រូវបាន «ឧក្រិដ្ឋជន» ប្រើប្រាស់ ។ សាក្សីនឹងត្រូវផ្តល់កសិណថាខ្លួនបានឃើញឧក្រិដ្ឋជនកាន់កាំភ្លើងដូចគ្នានឹងគំរូនៃកាំភ្លើងដែលបានផ្តល់ដោយព្រះរាជអាជ្ញា ។ ភាគីដែលដាក់បញ្ចូលភ័ស្តុតាងត្រូវតែបង្ហាញដែរថាការមានវត្ថុនេះជាភ័ស្តុតាង **មានប្រយោជន៍**សម្រាប់តុលាការ ។

## IV. ភ័ស្តុតាងដែលតុលាការមិនអាចទទួលយកបាន

ទោះបីជាភ័ស្តុតាងទាក់ទងទៅនឹងអង្គហេតុក្នុងសវនាការយ៉ាងណាក៏ដោយ តុលាការអាចសម្រេចដកភ័ស្តុតាងនោះចេញដោយផ្តល់មូលហេតុដទៃផ្សេងទៀត ។ ជាទូទៅចៅក្រមត្រូវបានផ្តល់នូវឆន្ទានុសិទ្ធ «ឬតស្សរភាព» ជាច្រើនដើម្បីសម្រេចថាតើភ័ស្តុតាងដែលទាក់ទងទៅនឹងរឿងក្តីគួរតែដកចេញឬយ៉ាងណា ។

**១) ការរើសអើងមិនត្រឹមត្រូវៈ** គ្រប់ភ័ស្តុតាងទាំងអស់ដែលអាចនាំទៅរកការរើសអើងមិនត្រឹមត្រូវចំពោះភាគីម្ខាងទៀតអាចត្រូវដកចេញ ។ ឧទាហរណ៍ៈ

ក) នៅក្នុងការកាត់ក្តីនៅក្នុងស្រុកជាច្រើនលើរឿងឃាតកម្ម រូបថតក្រោយពេលវះកាត់ទៅលើសាកសពដ៏គួរឲ្យខ្លាច ឬខ្មោចរអើមអាចត្រូវបានដកចេញ ឬមិនទទួលយក ។

ខ) ភ័ស្តុតាងនៃឧក្រិដ្ឋកម្មផ្សេងទៀតដែលបានប្រព្រឹត្តដោយចុងចោទនាពេលអតីតកាលនឹងត្រូវដកចេញដែរដោយឈរលើមូលដ្ឋានថា តុលាការអាចគិតក្នុងនិន្នាការថាជនចុងចោទទំនងជាបានប្រព្រឹត្តអំពើឧក្រិដ្ឋភាគច្រើន ប្រសិនបើជននោះមានប្រវត្តិជាឧក្រិដ្ឋជនពីអតីតកាល ហើយគិតថាការកាត់ក្តីឲ្យជាប់ទោសម្តងទៀតក៏មិនមែនជាការធ្វើឲ្យខូចកេរ្តិ៍ឈ្មោះរបស់ជននោះដែរ ។

**២) ភាពច្របូកច្របល់ៈ** ភ័ស្តុតាងដែលជាប់ទាក់ទងទៅនឹងសំណុំរឿងអាចត្រូវបានដកចេញ ប្រសិនបើភ័ស្តុតាង

នោះនឹងធ្វើឲ្យក្រុមប្រឹក្សាចៅក្រមច្របូកច្របល់ ឬនាំឲ្យក្រុមប្រឹក្សា ចៅក្រមទៅរកភាពភាន់ច្រឡំ ។

**៣) ការខ្ជះខ្ជាយពេលវេលាៈ** ភ័ស្តុតាងដែលមានការទាក់ទងអាចត្រូវបានដកចេញប្រសិនបើការបង្ហាញរបស់វានឹងធ្វើឲ្យចំណាយពេលឥតប្រយោជន៍ ជាឧទាហរណ៍ៈ នៅក្នុងការកាត់ក្តីអំពើឃាតកម្ម មិនចាំបាច់ត្រូវមានជំនាញការប្រាំនាក់ដើម្បីផ្តល់កសិណបញ្ជាក់ពីមូលហេតុនៃការស្លាប់នោះទេ ។

## V. ប្រភេទពិសេសនៃភ័ស្តុតាងជាក់ស្តែង និងភ័ស្តុតាងចង្អុលបង្ហាញ

***ក) ភ័ស្តុតាងជារូបភាពៈ*** ភ័ស្តុតាងជារូបថតភាគច្រើនត្រូវបានតុលាការទទួលយកមកពិចារណាដោយឈរលើហេតុផលថារូបថតតំណាងឲ្យកសិណផ្ទាល់មាត់ក្នុងលក្ខណៈជារូបភាព ។ សាក្សីនឹងធ្វើជាកសិណចំពោះអង្គហេតុ ហើយបន្ទាប់មកធ្វើជាកសិណថារូបភាពនោះតំណាងនូវអ្វីដែលសាក្សីបានឃើញ ។ តុលាការជាច្រើនមិនអនុញ្ញាតឲ្យយករូបថតទោសមួយមកជូនជាភ័ស្តុតាងទេ ប្រសិនបើគ្មានសាក្សីដែលអាចធ្វើជាកសិណថាខ្លួនបានឃើញកន្លែងកើតហេតុដែលជាប់ក្នុងរូបថតនោះ ។ សាក្សីដែលកោះហៅធ្វើជាកសិណពុំចាំបាច់ត្រូវតែជាអ្នកថតរូបនោះទេ ។ សាក្សីក៏អាចត្រូវបានកោះហៅឲ្យធ្វើជាកសិណចំពោះភាពអាចជឿទុកចិត្តបាននៃវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីផលិតជារូបថតនោះ ។ ក្នុងរបៀបនេះតុលាការទុកឲ្យរូបថតបកស្រាយពីភាពអាចយកជាការបានដោយខ្លួនឯង ។

**ខ) ឯកសារដែលសរសេរជាលាយល័ក្ខអក្សរៈ** ការបញ្ជាក់ឯកសារដែលសរសេរជាលាយល័ក្ខអក្សរថាជាឯកសារដើមពិតប្រាកដគឺមិនអាចធ្វើឡើងដោយការសន្មតនោះទេ ។ ផ្ទុយទៅវិញភាគីដែលដាក់ជូននូវឯកសារមួយជាភ័ស្តុតាងត្រូវមានបន្ទុកបញ្ជាក់ថា ឯកសារនោះជាឯកសារដើមពិតប្រាកដចំពោះមុខតុលាការ ។ ជាឧទាហរណ៍ ហត្ថលេខានឹងមិនត្រូវបានជឿជានិច្ចកាលចំពោះការបញ្ជាក់ពីភាពដើមពិតទៅលើប្រភពនៃឯកសារទេ ។ នរណាម្នាក់នឹងត្រូវតែធ្វើជាកសិណថាខ្លួនចំណាំហត្ថលេខានោះឬបានឃើញបុគ្គលនោះចុះហត្ថលេខាលើឯកសារដោយផ្ទាល់ ។ កាលៈទេសៈជុំវិញឯកសារនោះប្រហែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាឯកសារនោះជាឯកសារដើមពិតប្រាកដ ។ ឧទាហរណ៍ៈ កន្លែងដែលឯកសារនោះត្រូវបានរកឃើញ ប្រសិនបើឯកសារត្រូវបាននិយាយយោងទៅតាមឯកសារផ្សេងទៀត ប្រសិនបើឯកសារនោះស្រដៀងគ្នាទៅនឹងឯកសារដទៃទៀត និងប្រសិនបើឯកសារនោះមានសញ្ញា ឬដួងសញ្ញាប្លែកដាច់ពីគេ ។

**គ) ឯកសារចាស់ៈ** ឯកសារដែលចំណាស់បំផុតពុំតម្រូវឲ្យមានការបញ្ជាក់ភាពដើមពិតបែបនេះនៅក្នុងដែនសមត្ថកិច្ចនៃតុលាការភាគច្រើន ។ បញ្ហានេះពីព្រោះវាហាក់ដូចជាគ្មានសាក្សីណាដែលអាចធ្វើកសិណចំពោះប្រភពនៃឯកសារ ។ ដែនសមត្ថកិច្ចខុសគ្នាហើយអនុវត្តច្បាប់ផ្សេងគ្នាចំពោះឯកសារចំណាស់ៗ ប៉ុន្តែដែនសមត្ថកិច្ចជាច្រើនបញ្ជាក់ភាពដើមនៃឯកសារតាមរយៈថាឯកសារនោះមានអាយុលើសពី២០ ឬ៣០ឆ្នាំ ឯកសារនោះមានរូបលក្ខណៈមិនគួរឲ្យសង្ស័យ ហើយឯកសារនោះត្រូវបានផលិតឡើងពីកន្លែងសមហេតុសមផល ។

**ឃ) ឯកសារដែលបញ្ជាក់ថាជាឯកសារដើមពិតប្រាកដដោយខ្លួនឯងៈ** ឯកសារផ្លូវការ និងឯកសារកិច្ចព្រមព្រៀងមួយចំនួនមានលក្ខណៈបញ្ជាក់ថាពិតប្រាកដដោយខ្លួនឯង ពីព្រោះឯកសារនោះត្រូវបានបញ្ជាក់ដោយទីភ្នាក់ងាររដ្ឋាភិបាល ឬមុខសារការី ។

**ង) ក្រុមច្បាប់ភ័ស្តុតាងដ៏ល្អបំផុតៈ** ក្នុងអតីតកាលចាំបាច់ត្រូវបង្កើតនូវឯកសារដើម គឺពុំមែនជាឯកសារចម្លងទេ ។ ទោះបីជាយ៉ាងណាក្តីក្នុងសម័យម៉ាស៊ីនថតចម្លង (ហ្វូតូកូពី) ឯកសារចម្លងអាចត្រូវបានបង្កើតឡើង ហើយភាគីដែលបង្កើតឯកសារចម្លងនោះត្រូវតែបង្ហាញថាមានឯកសារដើម ។ ពេលណាបើភាគីម្ខាងទៀត សង្ស័យថាឯកសារនោះអាចក្លែងបន្លំ ឬប្រែកាឡៃ ទើបភាគីដែលផ្តល់ឯកសារថតចម្លងបែបនោះត្រូវតែដាក់ឯកសារដើមជូនតុលាការពិនិត្យ ។ **មូលហេតុក្នុងការដោះសារចំពោះការមិនមានឯកសារដើមរួមមានៈ** ការបាត់បង់ ឬការខូចខាតនៃឯកសារដើមការពិបាករកបំផុត ឬឯកសារនោះនៅក្រោមការកាន់កាប់របស់ភាគីទីបី ។ **(នៅមានត)**

**អេលីហ្សាប៊ែត ឌ៉ាន់ស្តាក់**

# ច្បាប់ស្ដីពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា របស់សហរដ្ឋអាមេរិក

បកប្រែក្រៅផ្លូវការដោយ ផាត កុសល

***ប្រការ៥៧១***. **ចំណងជើងសង្ខេប**

ប្រការនេះអាចដកស្រង់មកពិពណ៌នាបានថាជា «ច្បាប់ស្ដីពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា» ។

***ប្រការ៥៧២***. ***គោលនយោបាយ***

***ក) ភាពទូទៅៈ*** ស្របជាមួយនឹងច្បាប់អន្តរជាតិគោលនយោបាយរបស់សហរដ្ឋអាមេរិកគឺគាំទ្រកិច្ចប្រឹងប្រែងដើម្បីនាំសមាជិកខ្មែរក្រហមមកកាន់តុលាការដោយសារបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិរបស់ពួកនេះដែលបានប្រព្រឹត្តនៅប្រទេសកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

***ខ) ការជំរុញសកម្មភាពជាក់លាក់ៈ*** ក្នុងគោលដៅនេះសភាសហរដ្ឋអាមេរិកជំរុញឲ្យប្រធានាធិបតីៈ

១) ប្រមែប្រមូល ឬជួយដល់អង្គការ និងបុគ្គលនានាដែលមានលក្ខណៈសមស្របឲ្យប្រមូលនូវទិន្នន័យដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ។

២) លើកទឹកចិត្តដល់ការបង្កើតឲ្យមានតុលាការព្រហ្មទណ្ឌជាតិ ឬតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងកាលៈទេសៈដែលប្រធានាធិបតីយល់ថាសមស្របដើម្បីកាត់ទោសជនដាប់ចោទពីបទប្រល័យពូជសាសន៍នៅកម្ពុជា ហើយនិង

៣) ផ្ដល់ព័ត៌មានដែលប្រមូលបានដល់តុលាការជាតិឬអន្តរជាតិនោះតាមការចាំបាច់ដោយអនុលោមទៅតាមកថាខ័ណ្ឌទី១ ។

***ប្រការ៥៧៣***. ***ការបង្កើតការិយាល័យរបស់ក្រសួងការបរទេស***

***ក) ការបង្កើតៈ***

១) ថវិកាដែលត្រូវបានអនុញ្ញាតឲ្យតម្កល់ទុកចំណាយតាមច្បាប់នេះសម្រាប់ «កម្មវិធីផ្នែកការទូត និងកុងស៊ុល» មិនអាចយកទៅប្រើប្រាស់ចំពោះកាតព្វកិច្ច ឬការចំណាយណាមួយក្នុងចន្លោះឆ្នាំសារពើពន្ធ១៩៩៤ និង១៩៩៥ឡើយ លើកលែងតែក្នុងរយៈពេលមិនហួសពី៩០ថ្ងៃ បន្ទាប់ពីការអនុម័តច្បាប់នេះរួច រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកបានបង្កើតនូវ***ការិយាល័យស៊ើបអង្កេតការប្រល័យពូជសាសន៍នៅកម្ពុជា*** (ដែលហៅកាត់ក្នុងច្បាប់នេះថា «***ការិយាល័យ***») នៅក្នុងក្រសួងការបរទេសអាមេរិក ដោយដាក់ស្ថិតនៅក្រោមអនុរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ីខាងកើតនិងប៉ាស៊ីហ្វិក «ឬអនុរដ្ឋមន្ត្រីដែលឡើងកាន់តំណែងថ្មី» ។

២) ការិយាល័យនេះអាចធ្វើសកម្មភាពនៅក្នុង ឬនៅក្រៅប្រទេសកម្ពុជា ក៏ប៉ុន្តែថវិកាមិនតិចជាង៧៥ភាគរយសម្រាប់ការិយាល័យ និងសកម្មភាពរបស់ការិយាល័យនេះត្រូវប្រើប្រាស់ដើម្បីអនុវត្តសកម្មភាពនៅក្នុងប្រទេសកម្ពុជា ។

***ខ) គោលបំណងៈ*** តាមរយៈអង្គការនិងបុគ្គលនានាដែលរដ្ឋមន្ត្រីក្រសួងការបរទេសអាចចុះកិច្ចសន្យាជាមួយដើម្បីអនុវត្តដំណើរការ***ការិយាល័យ***នេះតាមគោលបំណងសមស្របរបស់***ការិយាល័យ***នេះគឺត្រូវទ្រទ្រង់ដល់កិច្ចប្រឹងប្រែងតាមភាពសមស្របដើម្បីនាំសមាជិកពួកខ្មែរក្រហមមកកាន់តុលាការអំពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិរបស់ពួកនេះដែលបានប្រព្រឹត្តក្នុងប្រទេសកម្ពុជាចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ កិច្ចខិតខំប្រឹងប្រែងទាំងនោះរួមមាន÷

១) ស៊ើបអង្កេតលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលប្រព្រឹត្តដោយមេដឹកនាំជាតិខ្មែរក្រហមក្នុងរយៈពេលនោះ

២) ផ្ដល់លទ្ធភាពឲ្យប្រជាជនកម្ពុជាងាយស្រួលរកបាននូវឯកសារកំណត់ហេតុនិងភស្តុតាងដទៃទៀតដែលជាលទ្ធផលនៃការស៊ើបអង្កេតនេះហើយដែលមានតម្កល់ទុកដោយ***ការិយាល័យ***នេះ ។

៣.ដាក់ជូនទិន្នន័យដែលទាក់ទងទៅឲ្យតុលាការព្រហ្មទណ្ឌ

ជាតិឬតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលអាចត្រូវបានបង្កើតឡើងដើម្បីធ្វើសវនាការជាផ្លូវការនិងកាត់ទោសអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម ហើយនិង

៤) រៀបរៀងនូវសំណើរបស់សហរដ្ឋអាមេរិកដើម្បីបង្កើតឲ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិមួយសម្រាប់កាត់ទោសជនជាប់ចោទទាំងនោះ ពីបទអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។

**គ) អាជ្ញាធរក្នុងការចុះកិច្ចសន្យាៈ** រដ្ឋមន្ត្រីការបរទេសត្រូវចុះកិច្ចសន្យាជាមួយនឹងបុគ្គល ឬអង្គការនានាដែលសមស្របក្នុងការអនុវត្តន៍នូវគោលបំណងរបស់**ការិយាល័យ**នេះដោយផ្អែកទៅលើលទ្ធភាពនៃថវិកាដែលបែងចែក ។

**ឃ) ការធ្វើសេចក្តីជូនដំណឹងដល់សភាអាមេរិកៈ** គណៈកម្មាធិការទំនាក់ទំនងបរទេស និងគណៈកម្មាធិការបែងចែកថវិកានៃព្រឹទ្ធសភា (សភាជាន់ខ្ពស់) និងសភាតំណាងប្រជាជន (សភាថ្នាក់ទាប) សហរដ្ឋអាមេរិកត្រូវទទួលបាននូវការជូនដំណឹងពីការអនុវត្តនូវអំណាចដូចមានចែងក្នុងប្រការទី៣៤ នៃច្បាប់ឆ្នាំ១៩៥៦ ស្តីអំពីអំណាចជាមូលដ្ឋានរបស់ក្រសួងការបរទេសដែលទាក់ទងដល់**ការិយាល័យ**នេះ ឬទាក់ទងដល់កម្មវិធី គម្រោងការងារ ឬសកម្មភាពរបស់**ការិយាល័យ**នេះក្នុងរយៈពេលយ៉ាងតិចបំផុត១៥ថ្ងៃមុនដោយអនុលោមតាមនីតិវិធីនានាដែលត្រូវអនុវត្តចំពោះការជូនដំណឹងផ្សេងៗដែលមានចែងក្នុងប្រការនោះ ។

## ប្រការ៥៧៤. បែបបទនៃការធ្វើរបាយការណ៍

**ក) ភាពទូទៅៈ** ក្នុងរយៈពេល៦ខែក្រោយពីកាលបរិច្ឆេទនៃការអនុម័តច្បាប់នេះ និងរៀងរាល់៦ខែជាបន្តបន្ទាប់មកទៀតប្រធានាធិបតីត្រូវបញ្ជូនទៅឲ្យគណៈកម្មាធិការសមស្របនៃសភាសហរដ្ឋអាមេរិកនូវរបាយការណ៍មួយដែលៈ

១) ពិពណ៌នាពីសកម្មភាពរយៈពេល៦ខែកន្លងមករបស់ការិយាល័យនេះ ហើយគូសបញ្ជាក់ពីអង្គហេតុថ្មីដែលស្វែងយល់បានពីការប្រព្រឹត្តរបស់ពួកខ្មែរក្រហមក្នុងអតីតកាល ហើយនិង

២) ពិពណ៌នាពីវិធានការនានាដែលប្រធានាធិបតីបានចាត់ការក្នុងរយៈពេល៦ខែកន្លងមក តាមរយៈសកម្មភាពនានាក្នុងប្រទេសកម្ពុជាដែលមិនទាក់ទងដល់កិច្ចការរបស់អង្គការសហប្រជាជាតិ ដើម្បីជំរុញការងារសិទ្ធិមនុស្សដើម្បីទ្រទ្រង់កិច្ចប្រឹងប្រែងនាំមេដឹកនាំនយោបាយនិងយោធារបស់ពួកខ្មែរក្រហមមកកាន់តុលាការ និងដើម្បីទប់ស្កាត់ការកើតមានជាថ្មីនូវអំពើរំលោភបំពានលើសិទ្ធិមនុស្សនៅកម្ពុជា ។

**ខ) និយមន័យៈ** សម្រាប់គោលដៅនៃប្រការនេះពាក្យថា «គណៈកម្មាធិការសមស្របនៃសភាអាមេរិក» មានន័យថា គណៈកម្មាធិការទំនាក់ទំនងការបរទេសនៃព្រឹទ្ធសភា និងគណៈកម្មាធិការកិច្ចការបរទេសនៃសភាតំណាងប្រជាជន ។



ទាហានខ្មែរក្រហមថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥

# កិច្ចខិតខំប្រឹងប្រែងរបស់សហរដ្ឋអាមេរិកលើបញ្ហាការកាត់ទោសមេដឹកនាំខ្មែរក្រហម



ប្រជាជនភាគច្រើននៅស្ទើរគ្រប់ប្រទេសនៅលើពិភពលោកមានការមមាញឹកក្នុងការចិញ្ចឹមជីវិតព្រមទាំងគ្រួសាររបស់ខ្លួនពុំមានពេលសម្រាប់ស្វែងយល់អំពីច្បាប់ និងប្រព័ន្ធនយោបាយរបស់ប្រទេសផ្សេងជាច្រើននៅលើពិភពលោកនោះទេ ។ នេះគឺជាការពិតចំពោះប្រជាជនកម្ពុជាក៏ដូចជាប្រជាជននៃបណ្តាប្រទេសផ្សេងៗទៀតនៅលើពិភពលោកដែរ ។ ប៉ុន្តែប្រជាជនកម្ពុជាអាចចាប់អារម្មណ៍ខ្លាំងក្នុងការស្វែងយល់អំពីរឿងដែលទាក់ទងនឹងច្បាប់ និងកិច្ចការនយោបាយនៃប្រទេសផ្សេងៗទៀតពីព្រោះថាការយល់ដឹងដែលនឹងទទួលបានផ្តល់នូវភាពផ្ទុយគ្នាស្រឡះគួរឲ្យចាប់អារម្មណ៍ទៅនឹងរបៀបដែលច្បាប់និងនយោបាយក្នុងប្រទេសកម្ពុជាដំណើរការ ។ ខ្ញុំសូមលើកយកឧទាហរណ៍មួយមកពីសហរដ្ឋអាមេរិកមកបំភ្លឺ ជាពិសេសច្បាប់នៅទីនោះដែលមានការទាក់ទងយ៉ាងច្រើនទៅនឹងការព្រួយបារម្ភរបស់ប្រជាជនកម្ពុជា ។

នៅក្នុងប្រទេសកម្ពុជា ជាទូទៅច្បាប់ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលដើម្បីការពារផលប្រយោជន៍របស់កម្ពុជាហើយផលប្រយោជន៍នោះកំណត់ឡើងដោយរដ្ឋាភិបាល ។ តែផ្ទុយមកវិញនៅសហរដ្ឋអាមេរិក ពលរដ្ឋសាមញ្ញតែងតែចូលរួមក្នុងការបង្កើតច្បាប់ក្នុងគោលបំណងបង្ខំឲ្យរដ្ឋាភិបាលអនុវត្តទៅតាមឆន្ទៈរបស់ប្រជាជន ។ការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងដំណើរការធ្វើច្បាប់នេះមានលក្ខណៈគួរឲ្យពិបាកជឿបន្តិច ប៉ុន្តែវាជាការពិត ។ ក្នុងប្រព័ន្ធច្បាប់របស់សហរដ្ឋអាមេរិកប្រជាជនធម្មតាអាចចូលរួមយ៉ាងសកម្មក្នុងការបង្កើតច្បាប់ដើម្បីធ្វើការផ្លាស់ប្តូរនយោបាយរបស់រដ្ឋាភិបាលដែលខ្លួនមិនឯកភាព ។នេះគឺជាមេរៀនជាមូលដ្ឋានមួយនៃភារកិច្ចទទួលខុសត្រូវរបស់ពលរដ្ឋដែលត្រូវបានយកមកបង្រៀននៅក្នុងកម្មវិធីបឋមសិក្សានិង

មធ្យមសិក្សានៅសហរដ្ឋអាមេរិក ។ ហើយការធ្វើដូច្នេះតាមពិត គឺដំណើរការបានល្អដែលពាក្យស្លោកមួយក្នុងចំណោមពាក្យស្លោក ដទៃជាច្រើនទៀតរបស់សហរដ្ឋអាមេរិកបានពោលថា រដ្ឋាភិបាល ត្រូវបានបង្កើតឡើង «**ដោយប្រជាជន មកដឹកនាំដោយប្រជាជន ដើម្បីបម្រើប្រជាជន**» ពុំមែនចែងឡើងដោយឥតប្រយោជន៍នោះទេ ។

ឧទាហរណ៍ជាក់ស្តែងមួយនៃករណីនេះត្រូវបានចែង ដោយច្បាប់មួយមានឈ្មោះថា «ច្បាប់ស្តីអំពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា» ។ នៅក្នុងឆ្នាំ១៩៨៩ ពលរដ្ឋអាមេរិកធម្មតាមួយក្រុមបានមូលមតិគ្នាចូលរួមធ្វើការដោយឈរលើក្តីព្រួយបារម្ភដូចគ្នាមួយថារដ្ឋាភិបាលសហរដ្ឋអាមេរិក មិនបានចាត់វិធានការឲ្យបានគ្រប់គ្រាន់ដើម្បីទប់ស្កាត់ការវិលត្រឡប់សាជាថ្មីនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហមមកកម្ពុជាឡើយ ។ ពលរដ្ឋមួយក្រុមនេះបានបង្កើតជាអង្គការស្ម័គ្រចិត្តឯកជនមួយហៅថា «**យុទ្ធនាការប្រឆាំងនឹងការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម**» ។ អង្គការនេះបានធ្វើការតស៊ូអស់រយៈពេលប្រាំឆ្នាំដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរនយោបាយរបស់សហរដ្ឋអាមេរិក ដោយបញ្ចុះបញ្ចូលរដ្ឋាភិបាលសហរដ្ឋអាមេរិកឲ្យចូលរួមកាន់តែសកម្មក្នុងការប្រឆាំងនឹងផែនការវិលត្រឡប់មកកាន់អំណាចសាជាថ្មីរបស់ពួកខ្មែរក្រហម និងការបន្តធ្វើបដិវត្តន៍ដ៏កខ្វក់ស្មោគគ្រោករបស់ពួកនេះ ។ គួរឲ្យកត់សម្គាល់ថាលោកឆាំង យុ ដែលជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជាកាលណោះ គឺជាបុគ្គលិកស្ម័គ្រចិត្តម្នាក់ក្នុងចំណោមបុគ្គលិកស្ម័គ្រចិត្តទាំងអស់ ដែលចាប់ផ្តើមធ្វើការតស៊ូនេះចាប់ពីដំបូងដៃមក ។ ក្រោយមក អង្គការនេះបានធ្វើឲ្យមានការអនុម័តច្បាប់ជាច្រើនក្នុងគោលបំណងជួយប្រជាជនកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងពួកខ្មែរក្រហម ។ ច្បាប់ថ្មីទាំងនេះដែលមានសារៈប្រយោជន៍ដ៏សំខាន់បំផុតត្រូវបានស្គាល់ជាទូទៅថា «ច្បាប់ស្តីអំពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា» ។

ច្បាប់ស្តីអំពីយុត្តិធម៌ចំពោះប្រល័យពូជសាសន៍នៅកម្ពុជា ត្រូវបានអនុម័តដោយសភារបស់សហរដ្ឋអាមេរិក នាដើមឆ្នាំ ១៩៩៤ ហើយត្រូវបានចុះហត្ថលេខាឲ្យចូលជាធរមានដោយប្រធានាធិបតីសហរដ្ឋអាមេរិក ប៊ីល គ្លីនតុន នៅខែឧសភា ឆ្នាំ១៩៩៤ ។ ច្បាប់នេះចែងថាៈ «គោលនយោបាយរបស់សហរដ្ឋអាមេរិកគឺគាំទ្រកិច្ចប្រឹងប្រែងដើម្បីនាំសមាជិកខ្មែរក្រហម មកកាន់តុលាការដោយសារបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិរបស់ពួកនេះដែលបានប្រព្រឹត្តនៅប្រទេសកម្ពុជាពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩» ។ ច្បាប់នេះក៏បានចែងទៀតថាប្រធានាធិបតីសហរដ្ឋអាមេរិកគួរតែ «ប្រមែប្រមូល ឬជួយដល់អង្គការ និងបុគ្គលនានាដែលមានលក្ខណៈសមស្របឲ្យប្រមូលនូវទិន្នន័យដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា» ។ ហើយចុងបញ្ចប់ច្បាប់នេះបានបង្គាប់ឲ្យលោកប្រធានាធិបតី «ជំរុញឲ្យមានការបង្កើតឲ្យមានតុលាការព្រហ្មទណ្ឌជាតិ ឬតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងកាលៈទេសៈដែលប្រធានាធិបតីយល់ថាសមស្របដើម្បីកាត់ទោសជនជាប់ចោទពីបទប្រល័យពូជសាសន៍នៅកម្ពុជា» ។ តាមពិតច្បាប់នេះ គឺជាការវិវត្តន៍ថ្មីមួយខុសប្លែករបស់នយោបាយសហរដ្ឋអាមេរិក មិនមែនចំពោះតែប្រទេសកម្ពុជាទេ ប៉ុន្តែថែមទាំងចំពោះរបៀបដែលសហរដ្ឋអាមេរិកឆ្លើយតបទៅនឹងការកើតឡើងនៃអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទូទាំងពិភពលោកទៀតផង ។

ឥឡូវយើងនាំគ្នាមើលថា តើច្បាប់ស្តីអំពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជាមានដំណើរការយ៉ាងណាចំពោះការផ្លាស់ប្តូរនយោបាយរបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា ដែលជាយថាហេតុនឹងនាំដល់ការវិវត្តន៍ជាជំហានសំខាន់ៗ នៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃៗទៀតនៅជុំវិញពិភពលោកនោះ ។ ជាលទ្ធផលផ្ទាល់ចេញពីច្បាប់នេះ នៅចុងឆ្នាំ១៩៩៤ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានផ្តល់ជំនួយធំមួយដល់កម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៃសកលវិទ្យាល័យយែល សហរដ្ឋអាមេរិក ។ សកលវិទ្យាល័យយែលបានបោះជំហានទៅមុខយ៉ាងលឿន ។ នៅខែមករា ឆ្នាំ១៩៩៥ បានបង្កើតឡើងនូវការិយាល័យមួយនៅទីក្រុងភ្នំពេញប្រទេសកម្ពុជា ហើយការិយាល័យនោះមានឈ្មោះថា មជ្ឈមណ្ឌលឯកសារកម្ពុជា ឬហៅកាត់ថា «ឌី ស៊ី ខេម» ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ពីឆ្នាំ១៩៩៥



កងអាវុធហត្ថនៃរបបសាធារណរដ្ឋខ្មែរ

ដល់ឆ្នាំ១៩៩៦មានតួនាទីជាមូលដ្ឋានប្រតិបត្តិនៃកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជានៃសកលវិទ្យាល័យយែលនៅក្នុងប្រទេសកម្ពុជាដោយជ្រៅជ្រះ **ការចងក្រងឯកសារការសិក្សាស្រាវជ្រាវ និងគម្រោងបណ្តុះបណ្តាលច្បាប់អន្តរជាតិ** ផ្សេងៗទាក់ទងនឹងការដាក់ពួកខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។ ដោយការងាររបស់អ្នកសិក្សានៃមជ្ឈមណ្ឌលឯកសារកម្ពុជាចេះតែបន្តរីកចំរើនទៅមុខឥតឈប់ឈរក្នុងការស្រាវជ្រាវនិងផ្សព្វផ្សាយជាសាធារណៈនូវពត៌មានថ្មីៗស្តីអំពីទំហំ និងកម្រិតនៃអំពើប្រល័យពូជសាសន៍របស់ពួកខ្មែរក្រហមនោះប្រព័ន្ធឃោសនាអន្តរជាតិរួមមានកាសែត, ទស្សនាវដ្តី ទូរទស្សន៍, វិទ្យុនិងប្រព័ន្ធអ៊ិនធ័រនែតបានចាប់ផ្តើមចាប់យករបាយការណ៍នៃរបកគំហើញទាំងនេះ ហើយផ្សព្វផ្សាយបន្តនៅជុំវិញពិភពលោក ។ ការធ្វើដូច្នេះបាននាំមកនូវការទាមទារជាអន្តរជាតិកាន់តែកើនឡើងនៅជុំវិញពិភពលោកឲ្យមានការស្វែងរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាដោយបានធ្វើឲ្យមានការកើនឡើងនូវការគាបសង្កត់ទៅលើអង្គការសហប្រជាជាតិឲ្យធ្វើការពិចារណាចំពោះការបង្កើតឡើងនូវតុលាការព្រហ្មទណ្ឌអន្តរជាតិមួយដើម្បីវិនិច្ឆ័យទោសបទឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម ។

នាខែមករា ឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយខ្លួនជាស្ថាប័នជាតិស្រាវជ្រាវជាតិឯករាជ្យមួយហើយជាលទ្ធផលផ្ទាល់នៃច្បាប់ស្តីអំពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ស្ថាប័នថ្មីហើយសំខាន់មួយត្រូវបានចាប់បដិសន្ធិឡើង ។ ប៉ុន្តែនោះវាមិនមែនជាលទ្ធផលនៃច្បាប់ស្តីអំពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជាតែមួយប៉ុណ្ណោះទេ ។ ដោយសារការងារចងក្រងឯកសារស្តីអំពីឧក្រិដ្ឋកម្មនានានៃរបបខ្មែរក្រហមចេះតែបន្តទៅមុខដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រដ្ឋាភិបាលសហរដ្ឋអាមេរិកក៏បានបន្តការផ្តួចផ្តើមគំនិតផ្សេងៗទៀតក្នុងការអនុវត្តនភារកិច្ចទទួលខុសត្រូវរបស់ខ្លួនក្រោមច្បាប់ស្តីអំពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ នាខែមេសា ឆ្នាំ១៩៩៨ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានពាំនាំសំណើមួយរបស់ខ្លួនទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអំពាវនាវឲ្យមានការបង្កើតឡើងនូវអង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិមួយដើម្បីធ្វើការវិនិច្ឆ័យទោសពួកខ្មែរក្រហមដែលមានលក្ខណៈប្រហាក់ប្រហែលនឹងតុលាការពីរដែលមានស្រាប់ដែលកំពុងជំនុំជម្រះឧក្រិដ្ឋកម្មអន្តជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉្វាន់ដា ។ ប៉ុន្តែសមាជិកក្រុមប្រឹក្សាអង្គការសហប្រជាជាតិមួយចំនួនបានតវ៉ាញត្អូញត្អែរថា តុលាការថ្មីដែលនឹងបង្កើតឡើងនៅក្នុងប្រទេសកម្ពុជានឹងត្រូវចំណាយអស់ប្រាក់ច្រើនពេក ហើយសាធារណរដ្ឋប្រជាមានិតចិនបានទាញហេតុផលជំទាស់ថារឿងខ្មែរក្រហមគឺជារឿងផ្ទៃក្នុងរបស់ប្រទេសកម្ពុជាសុទ្ធសាធ ។ ជាលទ្ធផលនៃការជឿងឆ្ងល់ទាំងនេះក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិមិនបានចាត់វិធានការចំពោះសំណើរបស់សហរដ្ឋមេរិក ស្តីអំពីរឿងតុលាការខ្មែរក្រហមឡើយ ។

ទន្ទឹមពេលជាមួយគ្នានេះដែរ ដោយមានការគាបសង្កត់កាន់តែខ្លាំងឡើងៗពីប្រទេសជាច្រើន អង្គការសហប្រជាជាតិក៏ចាប់ផ្តើមដំណើរការគំនិតផ្តួចផ្តើមរបស់ខ្លួនដើម្បីរិះរកលទ្ធភាពបង្កើតតុលាការមួយឡើង ។ នៅខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រុមអ្នកជំនាញមួយក្រុមតែងតាំងដោយអង្គការសហប្រជាជាតិក៏បានមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាដើម្បីពិនិត្យបញ្ហាថាតើមានភស្តុតាងគ្រប់គ្រាន់ឬទេសម្រាប់ធានាដល់ការឲ្យបង្កើត

តុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិក៏បានចំណាយពេលជាច្រើនថ្ងៃក្នុងការពិនិត្យពត៌មានដែលប្រមែប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នាខែកុម្ភៈ ឆ្នាំ១៩៩៩ ក្រុមអ្នកជំនាញការបានធ្វើរបាយការណ៍ទៅអគ្គលេខាអង្គការសហប្រជាជាតិដោយនិយាយថាពួកខ្លួនបានរកឃើញភ័ស្តុតាងដែលបង្ហាញថា ពួកខ្មែរក្រហមបានប្រព្រឹត្តខក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងបទខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត ហើយបានស្នើយោបល់ដល់អង្គការសហប្រជាជាតិឲ្យបង្កើតឡើងនូវតុលាការព្រហ្មទណ្ឌអន្តរជាតិមួយដើម្បីធ្វើការវិនិច្ឆ័យនូវបទខក្រិដ្ឋកម្មទាំងអស់នោះ ។ ក្នុងការផ្លាស់ប្តូរដ៏គួរឲ្យភ្ញាក់ផ្អើល រដ្ឋាភិបាលកម្ពុជាដែលធ្លាប់បានអំពាវនាវជាច្រើនឆ្នាំមកហើយឲ្យមានការបង្កើតតុលាការ ក៏ធ្វើការប្រកាសជំទាស់ភ្លាមថាខ្លួនលែងយល់ព្រមចំពោះគំនិតបែបនេះទៀតហើយ ។

ចាប់ពីពេលនោះមកអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានធ្វើការចរចាជាបន្តបន្ទាប់ក្នុងគោលបំណងស្វែងរករូបមន្តសម្របសម្រួលមួយដែលអាចអនុញ្ញាតឲ្យមានការបង្កើតឡើងនូវតុលាការខ្មែរក្រហមមួយ ។ សហរដ្ឋអាមេរិកដោយដើរតាមការទទួលខុសត្រូវរបស់ខ្លួនក្រោមច្បាប់ស្តីអំពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជាបានបន្តការគាំទ្ររបស់ខ្លួនចំពោះកិច្ចខិតខំប្រឹងប្រែងតាមមធ្យោបាយជាច្រើនយ៉ាង ។ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាលទ្ធផលផ្ទាល់នៃច្បាប់ស្តីអំពីយុត្តិធម៌អំពើប្រល័យពូជសាសន៍កម្ពុជាត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់ភ័ស្តុតាងស្តីអំពីខក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហមនៅពេលណាដែលតុលាការមួយនឹងត្រូវបានបង្កើតឡើងដោយថាហេតុនោះ ។

**ក្រេក អ៊ិចឆេសាន់**

*កំណាព្យ*

## សោកនាដកម្មរបស់ប្រជាជនកម្ពុជាក្រោមរបបខាលពិឃាត

**អ៊ុំច ស៊ុនឡាយ ប្រធានការិយាល័យខុទ្ទកាល័យសាលាខេត្តក្រចេះ**

| | | | |
|---|---|---|---|
| ប្រភេទទីមួយគឺប្រជា | រស់នៅយូរយារចាស់គ្រោតគ្រោត | នៅក្នុងមូលដ្ឋានមានដៅញាតិ | មុនរំដោះជាតិខែមេសា ។ |
| គឺជាប្រជាជនពេញសិទ្ធិ | អង្គការពិនិត្យមាំខ្ជាំងក្លា | ធ្វើជាប្រធានហ៊ានត្រួតត្រា | ចាត់ចែងធ្វើការបានទាំងអស់ ។ |
| ប្រភេទទីពីរគឺអ្នកណា | រស់តាមបណ្តាភូមិរំដោះ | នៃរបបចាស់គ្មានចន្លោះ | ចូលដល់ស្ម័គ្រស្មោះជាអ្នកត្រៀម ។ |
| ពួកអនុធនជាងកាត់សក់ | ជាងកាត់កញ្ចក់ពួកលក់តៀម | តាមតូបភូមិឃុំត្រូវឈប់ស្ងៀម | បិទទ្វារតូបតៀមទៅស្រុកស្រែ ។ |
| ពួកសិស្សនិស្សិតអនិតផង | ពលករប្អូនបងអាចារ្យដែរ | ពួកគ្រូបង្រៀននៅស្រុកស្រែ | និងពួកធ្លាប់តែជិះជាន់គេ ។ |
| ប្រភេទទីបីខ្ញីជីវិត | ប្រជាជនពិតមិនស្ថិតស្ថេរ | ក្រោមរបបចាស់តែងផាករេ | គឺពួកធ្លាប់ដេរបដិវត្តន៍ ។ |
| មានអ្នករាជការរបបមុន | រាជការបច្ចុប្បន្នដែលនិវត្តន៍ | វិលពីទីក្រុងទៅជនបទ | មានឈ្មោះប្រាកដក្នុងបញ្ជី ។ |
| មានឈ្មោះថាប្រជាជនផ្ញើ | មានសិទ្ធិដើរហើក្នុងនាទី | តែសហករណ៍ខ្លួនមិនលើសពី | ចាប់ពីចុងទីដល់ដើមភូមិ ។ |
| មិនអាចឆ្លងកាត់ភូមិផ្សេងទៀត | បើមានល្បិតស្មៀតត្រូវអប់រំ | វាវាស់ដីដើរដោយបន្ទំ | មេកងមេក្រុមជាអង្គការ ។ |
| មេពួកមេភូមិមេសហករណ៍ | សិទ្ធិធំម្ល៉េះហ្ន៎អាចប្រហារ | ធ្វើទារុណកម្មតាមប្រាថ្នា | គ្មានតុលាការជម្រះឡើយ ។ |
| សូម្បីកងឈ្លបកងចល័ត | ក៏អាចអារកាត់មិនកន្តើយ | ជាតុលាការកាត់ទោសហើយ | ត្បូងចបបុកដោយគល់ឬស្សី ។ |

# ២០ ឧសភា

របាយការណ៍បូកសរុបអំពីឧក្រិដ្ឋកម្មនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី ខៀវ សំផន ដែលធ្វើឡើងដោយគណៈកម្មាធិការរណសិរ្សស្រុកមោងឫស្សី ខេត្តបាត់ដំបង ក្នុងថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ បានសរសេរថា សភាជាតិ «នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា» បានអនុម័តក្នុងសម័យប្រជុំលើកទី៥ នីតិកាលទី១ ថ្ងៃទី១៥ ដល់១៨ ខែសីហា ឆ្នាំ១៩៨៣ យកថ្ងៃ២០ ឧសភា ជា «ទិវាចងកំហឹង» ចំពោះបនប្រល័យពូជ សាសន៍ ប៉ុល ពត អៀង សារី ខៀវ សំផន និងជាថ្ងៃដែលបនប្រល័យពូជសាសន៍បានចាប់ផ្តើមអនុវត្តគោលការណ៍ប្រល័យពូជសាសន៍យ៉ាងចំហនិងយ៉ាងឃោរឃៅព្រៃផ្សៃចំពោះប្រជាជនទូទាំងប្រទេស ។ ក្នុងនោះរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចេញសេចក្តីប្រកាសជាផ្លូវការថាប្រជាជនទូទាំងប្រទេសប្រមាណ ៣ ៣១៤ ៧៦៨នាក់ ត្រូវបានបាត់បង់ជីវិតក្រោមរបបដ៏សាហាវឃោរឃៅជាទីបំផុតក្នុងចុងសតវត្សរ៍ទី២០ ។ របាយការណ៍បូកសរុបនោះក៏បានសរសេរថា «ឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ និងសោកនាដកម្មដែលប្រជាជនកម្ពុជាទទួលរងគ្រោះជាង៣ឆ្នាំ ៨ខែ ២០ថ្ងៃ ក្រោមរបបប្រល័យពូជសាសន៍ជាទុក្ខលំបាករបស់ប្រជាជនកម្ពុជាគ្មានអ្នកនិពន្ធជាតិ និងអន្តរជាតិណាអាចសរសេររៀបរាប់បានឲ្យអស់ឡើយ» ។

កាលពី១០ឆ្នាំមុនការអនុម័តដោយសភាក្នុងឆ្នាំ១៩៨៣ យកថ្ងៃ២០ ឧសភា ជា «ទិវាចងកំហឹង» ពួកកុម្មុយនិស្តខ្មែរក្រហមបានកំណត់យកថ្ងៃនេះជាថ្ងៃអបអរកំណើតសហករណ៍ដែលមិនធ្លាប់មានពីមុនមកនៅក្នុងសង្គមកម្ពុជា ។ សៀវភៅថ្នាក់ទី២បោះពុម្ពផ្សាយលើកទី១ ដោយរបបកម្ពុជាប្រជាធិបតេយ្យដែលបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៧៦ បានសរសេរថា «***សហករណ៍យើងបានចាប់កំណើតនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ក្នុងភ្លើងសង្គ្រាមបដិវត្តន៍ដ៏សន្ធោរសន្ធៅប្រជាជនយើងបានវាយឈ្នះចក្រពត្តិអាមេរិក និងពួកអាក្បត់ជាតិ ហើយបានដឹករំលើងឫសគល់វណ្ណៈសក្តិភូមិ ម្ចាស់ដី និងនាយទុន រំដោះទឹកដី និងប្រជាជនទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥***» ។



ចន្លោះខែសីហា ឆ្នាំ១៩៨៣ ដល់ខែធ្នូ ឆ្នាំ១៩៨៥ ប្រជាជនដែលរួចពីស្លាប់ចំនួន ១ ១៦៦ ៣០៧នាក់ ក្នុងខេត្តចំនួន ១៥ បានធ្វើញត្តិរួមគ្នា ចំនួន១២៥០ ដែលក្នុងញត្តិទាំងនោះបានរាយរាប់ពីចំនួនសមាជិកដែលបានស្លាប់ក្រោមរបបខ្មែរក្រហម ។ ថ្វីដ្បិតតែញត្តិទាំងនោះមានសណ្ឋានដូចៗគ្នា «ដែលស្តែងបញ្ជាក់ពីការរៀបចំឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា» ដើម្បីគាំទ្រសេចក្តីសម្រេចរបស់សម័យប្រជុំសភាលើកទី៥ នីតិកាល និងស្នើសុំឲ្យអង្គការសហប្រជាជាតិបណ្តេញបន ប៉ុល ពត អៀង សារី ចេញពីកៅអីអង្គការសហប្រជាជាតិ យ៉ាងណាក៏ដោយការពិតជាសំខាន់ស្ថិតនៅត្រង់ថាប្រជាជនជាងមួយលាននាក់ដែលតំណាងឲ្យជនរងគ្រោះទូទាំងប្រទេសដែលបានចាកផុតពីសេចក្តីស្លាប់ក្រោមរបបប្រល័យពូជសាសន៍បានអំពាវនាវដល់អន្តរជាតិថា របបខ្មែរក្រហមបានប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃមកលើប្រជាជាតិកម្ពុជាទាំងមូល ហើយទាមទារឲ្យមានការស្វែងរកយុត្តិធម៌ពិតប្រាកដមួយដល់កម្ពុជា ។ ជាអកុសលញត្តិទាំងអស់នេះពុំត្រូវបានផ្ញើជូនទៅដល់អង្គការសហប្រជាជាតិទេ ហើយការទាមទាររកយុត្តិធម៌ពុំត្រូវបានអើពើសោះឡើយ ។ ផ្ទុយទៅវិញរបបខ្មែរក្រហមបន្តទទួលជោគជ័យនៅក្នុងយុទ្ធនាការអំពាវនាវឲ្យបណ្តាប្រទេសជាច្រើនលើឆាកអន្តរជាតិឲ្យគាំទ្រដល់រដ្ឋាភិបាលរបស់ខ្លួនដោយឈរលើហេតុផលថាប្រទេសកម្ពុជានាពេលនោះត្រូវបានឈ្លានពានដោយប្រទេសវៀតណាម ។

ទោះបីជា ទិវា២០ ឧសភា និងញត្តិទាំងនោះត្រូវបានអ្នកវិភាគបស្ចិមប្រទេសយល់ថា ជាការរៀបចំឡើងដោយរបបថ្មី (សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា) ដើម្បីបម្រើនយោបាយរបស់ខ្លួនក៏ដោយ ក៏ការពិតមួយដ៏សំខាន់ដែលពុំអាចប្រកែកបានមកទល់ពេលនេះគឺថាប្រជាជនកម្ពុជាបានបន្តការពុះពារស្រែកប្រាប់ពិភពលោករហូតដល់ថ្ងៃដែលមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ខែតុលា ឆ្នាំ១៩៩១ ថារបបខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ព្រៃផ្សៃបំផុតនៅក្នុងសតវត្សរ៍ទី២០កន្លងមកនេះ ហើយក្រាញនៀលក្នុងការទាមទាររកយុត្តិធម៌ជូនគ្រួសារនិងញាតិសន្តានរបស់ខ្លួននិងក្រើនរំលឹកប្រាប់ប្រជាជនកម្ពុជាឲ្យចងចាំអតីតកាលដ៏ឈឺចាប់នេះ និងទប់ស្កាត់ឲ្យបានកុំឲ្យរបបបែបនេះកើតឡើងសាជាថ្មីតាមរយៈទិវា «ចងកំហឹង» ថ្ងៃ ២០ ឧសភា នេះ ។ ចាប់តាំងពីឆ្នាំ១៩៩២មក មកទល់នឹងពេលនេះការប្រារព្ធទិវា «ចងកំហឹង» នេះត្រូវបានបាត់រូបភាពជាសាធារណៈ ឬមានកម្រិតតូច ហើយភាគច្រើនប្រារព្ធឡើងដោយស្ងៀមស្ងាត់នៅក្នុងរង្វង់គណបក្សប្រជាជនតែប៉ុណ្ណោះ ។ នេះទំនងជាដោយសារការផ្លាស់ប្តូរនយោបាយចំពោះបញ្ហាខ្មែរក្រហមដែលពេលនោះបានក្លាយជាភាគីនយោបាយស្របច្បាប់នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ហើយថ្មីៗនេះទៀតសក្តានុពលនយោបាយនិងយោធាខ្មែរក្រហមបានចុះខ្សោយ ក៏ប៉ុន្តែការអះអាងថាការថមថយចុះនៃទំហំនៃទិវានេះបញ្ជាក់ថាប្រជាជនកម្ពុជាបានបំភ្លេចនូវការឈឺចាប់ដោយសាររបបនេះពុំមែនជាការត្រឹមត្រូវឡើយ ។ ថ្វីដ្បិតតែប្រជាជនកម្ពុជាគ្រប់រូបមមាញឹកនឹងកិច្ចការ ឬប្រកបរបរចិញ្ចឹមជីវិតជាធម្មតា ក៏ប៉ុន្តែភាពព្រៃផ្សៃរបស់ពួកខ្មែរក្រហមដែលបានប្រព្រឹត្តលើក្រុមគ្រួសារខ្លួននៅតែដក់ជាប់នៅក្នុងជម្រៅចិត្តជានិច្ច ។ ភស្តុតាងជាក់ស្តែងដូចជាគុក មន្ទីរសន្តិសុខ រណ្តៅសាកសពពុំទាន់បាត់ស្លាកស្នាមពីភូមិដ្ឋានរបស់ជនរងគ្រោះនៅឡើយទេ ។ ប្រជាជនកម្ពុជានឹងបន្តរស់នៅតែរូបកាយ ក៏ប៉ុន្តែវិញ្ញាណរបស់ខ្លួននឹងជាប់ឃុំឃាំងក្នុងអតីតកាលជារៀងរហូតប្រសិនបើពុំបានផ្តល់យុត្តិធម៌ពិតប្រាកដមួយ ។ បូជនីយដ្ឋានតម្កល់អដ្ឋិធាតុមាននៅស្ទើរគ្រប់ស្រុកទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជាកំពុងបញ្ជាក់ប្រាប់ថាជនរងគ្រោះនៅតែចង់បាន«យុត្តិធម៌» ។ សំណួរភាគច្រើនដែលមីង មា អ៊ំស្រី អ៊ំប្រុស លោកតា លោកយាយជាច្រើនដែលមិនអាចរៀបរាប់ឈ្មោះអស់ ដែលខ្ញុំបានធ្លាប់ជួបសំណេះសំណាលនៅតាមបណ្តាភូមិស្រុកតែងសួរស្ទើរតែដូចៗគ្នាថា «នៅពេលណាទើប «គេ» កាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់នេះ? ឬថា «ខ្ញុំចង់ឲ្យពួក «មេដឹកនាំ» ខ្មែរក្រហមឆ្លើយប្រាប់ថាហេតុអ្វីបានជាសម្លាប់មនុស្សរាប់លាននាក់ដូច្នេះ? ឬហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ ប្តីខ្ញុំ ឬកូនខ្ញុំ?» ។

ខ្ញុំសង្ឃឹមថាទិវា២០ ឧសភា ឆ្នាំ២០០០នេះ ជាការក្រើនរំឭកដល់រដ្ឋសភាជាតិ ព្រឹទ្ធសភារដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិធ្វើការសម្រេចឲ្យបាននូវច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលមិនត្រឹមតែរក្សាបាននូវការបង្រួបបង្រួមជាតិ ក៏ប៉ុន្តែអាចផ្តល់យុត្តិធម៌ពិតប្រាកដមួយដល់ប្រជាជនកម្ពុជាក៏ដូចជាមនុស្សជាតិទាំងមូល ។

**ផាត កុសល**

# ប្រសាសន៍របស់សម្តេច ហ៊ុន សែន អំពីតុលាការខ្មែរក្រហម នៅក្នុងពិធីសម្ពោធការដ្ឋានសាងសង់មន្ទីរពេទ្យរបេងដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុន ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០០

## (ដកស្រង់ចេញពីទូរទស្សន៍ជាតិកម្ពុជាដោយ ឌ៉ាន់ថាន់ ពៅដារ៉ា)

ខ្ញុំមិនចុះហត្ថលេខាណាមួយជាដាច់ខាតមុនពេលដែលសភាអនុម័តច្បាប់ ។ ព្រោះអ្វី? ព្រោះថា សភា ឬព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ព្រះមហាក្សត្រ យើងត្រូវតែគោរពមិនអាចទៅធ្វើកិច្ចព្រមព្រៀងនេះជាមួយកិច្ចព្រមព្រៀងអន្តរជាតិដែលមានរាប់រយឆ្នាំ ហើយកម្ពុជាទៅចុះហត្ថលេខាចូលនៅក្នុងអនុសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិនានា ហើយមកសុំសច្ចាប័នរបស់សភា តែនេះគឺជាច្បាប់ដែលបង្កើតថ្មីដោយសភាយើងមិនអាចទៅធ្វើកិច្ចព្រមព្រៀងជាមួយនឹងបរទេសណា ហើយមកសង្កត់សភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងព្រះមហាក្សត្រឲ្យទទួលយកនូវគំនិតរបស់យើងទេ ។ ខ្ញុំបានស្នើសុំការយោគយល់នេះចំពោះអគ្គលេខាធិការអង្គការសហប្រជាជាតិ តែយើងអាចធ្វើបានចំពោះការប្តូរលើសារលិខិតគ្នា ការប្តូរសារលិខិតគ្នាទៅវិញទៅមក ហើយដែលការប្តូរសារលិខិតនោះអាចរៀបរាប់បានពីចំណុចនេះ ឬចំណុចនោះ ក៏ប៉ុន្តែចំណុចមួយត្រូវតែច្បាស់ គឺមិនមែនចាប់បង្ខំឲ្យសភាធ្វើការអនុម័តទៅតាមអ្វីដែលខ្ញុំបានចុះកិច្ចព្រមព្រៀងជាមួយ បានប្តូរសារជាមួយនឹងអង្គការសហប្រជាជាតិទេ ។ អ៊ីចឹងទេបានជាខ្ញុំពន្យល់ទៅឯកឧត្តមកូហ្វីអាណាន់ម្តងហើយម្តងទៀតថា ខ្ញុំមិនអាចធ្វើបានទេហើយសូមកុំភាន់ច្រឡំថា នេះមិនមែនជាសន្ធិសញ្ញាអន្តរជាតិដែលកម្ពុជាទៅចូលរួមហើយបានម៉ោសុំសភាទេ តែនេះជាច្បាប់ដែលសភាត្រូវអនុម័តតែម្តង ព្រឹទ្ធសភាត្រូវអនុម័តតែម្តង ។ វាខុសនៅចំណុចនេះ ហើយបើសិនជាតាមលិខិតរបស់ឯកឧត្តមកូហ្វីអាណាន់បញ្ជូនមកខ្ញុំនៅថ្ងៃទី២៥នោះ ២៥ខែមេសានោះ បញ្ជាក់ថាវាអាចផ្លាស់ប្តូរនូវសារលិខិត ឬធ្វើ...បង្កើតជាកិច្ចព្រមព្រៀងបានមុនសភាអនុម័ត ។ ប៉ុន្តែអ្វីដែលសំខាន់ សភាអនុម័តទៅតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលជាមួយសហប្រជាជាតិ ។ ដូច្នេះមានន័យថាម៉េច? រឿងត្រង់ហ្នឹងហើយ ដែលខ្ញុំប្រឆាំងខ្ញុំជំទាស់ ។ បើសិនជានៅតែជំទាស់តទៅទៀត នៅបន្តខ្ញុំតទៅទៀត គឺខ្ញុំនឹងបន្តមិន...មិនធ្វើអ្វីទាំងអស់ ព្រោះខ្ញុំមិនអាចបំពានបាន ។ តើឲ្យខ្ញុំយកចិត្តកូហ្វីអាណាន់ យកចិត្តបរទេស ឬត្រូវយកចិត្តសមាជិកសមាជិការដ្ឋសភា ព្រឹទ្ធសភា យកចិត្តក្រុមប្រឹក្សាធម្មនុញ្ញ និងគោរពព្រះមហាក្សត្រ ។ នេះជាបញ្ហា ។ គេត្រូវដឹងអំពីការលំបាក និងនីតិវិធីការងារ ។ អ្វីដែលគេបានធ្វើម៉ោលើខ្ញុំកន្លងទៅមិនមែនត្រឹមតែមិនបានបង្ហាញពីការគោរពចំពោះឯករាជ្យ និងអធិបតេយ្យភាពរបស់កម្ពុជាទេ ក៏ប៉ុន្តែសូម្បីតែនីតិវិធី និងរបៀបរបបការងារនៃអង្គការនីតិប្រតិបត្តិ បញ្ញត្តិ និងតុលាការដែលបានបែងចែកពីគ្នា គេមិនបានធ្វើផង ។ ដូច្នេះហើយបានជាធ្វើឲ្យយើងខ្ញុំមានការខកចិត្តយ៉ាងខ្លាំង ក៏ប៉ុន្តែខ្ញុំគិតថា បញ្ហាទាំងឡាយដែលបានកើតប៉ុន្មានថ្ងៃមុននេះគឺវាមិនក្លាយទៅជាឧបសគ្គនៃការជឿនលឿនទៅមុខនៃដំណើរឆ្ពោះទៅរកការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។ ខ្ញុំសង្ឃឹមថា ដូចគ្មានអ្វីកើតឡើងក្នុងប៉ុន្មានថ្ងៃកន្លងទៅចុះ ។ អ្វីដែលបានកើតការកិច្ចព្រមព្រៀងរវាង ចន ឃែរី ជាមួយខ្ញុំគឺអាចយកជាការបាន ។ ឥឡូវនេះខ្ញុំកំពុងរង់ចាំ ចន ឃែរី ធ្វើការជាមួយ កូហ្វីអាណាន់ បានដល់ណា? គឺខ្ញុំនឹងរង់ចាំពត៌មាននោះ ព្រោះបើសិនជាមិនសុខចិត្តគោរពនូវអ្វីដែលជាអធិបតេយ្យ និងរបៀបរបបការងាររបស់កម្ពុជា ខ្ញុំសុខចិត្តយល់ព្រមនូវរូបមន្តជារូបមន្តដែលខ្ញុំបានប្រកាសនៅពោធិចិនតុងរួចហើយអំពីបញ្ហាទាក់ទងជាមួយនឹងរបៀបរបបដោះស្រាយការមិនចុះសម្រុងរវាងសហព្រះរាជអាជ្ញា ឬក៏សហចៅក្រមស៊ើមអង្កេតខ្ញុំយល់ព្រមបញ្ជូនទៅសភា ក៏ប៉ុន្តែខ្ញុំគ្មានសិទ្ធិនឹងរារាំងបិទមាត់សមាជិកសភាណាម្នាក់មិនឲ្យលើករូបមន្តថ្មី ឬមិនឲ្យពិភាក្សាដូចអ្វីដែលគេបានលើកក្នុងសារលិខិតថាសភាត្រូវតែអនុម័តតាមនូវការព្រមព្រៀងរវាងរដ្ឋាភិបាលជាមួយអង្គការសហប្រជាជាតិ ។ ត្រង់ហ្នឹងហើយដែលខ្ញុំមិនយល់ស្រប ។ អ្វី

ដែលខ្ញុំអាក់អន់ចិត្តគឺកន្លែងហ្នឹង ប៉ុន្តែខ្ញុំសូមបញ្ជាក់ឡើងវិញថា ការអាក់អន់ចិត្តនោះមិនរំខានទៅដល់កិច្ចខិតខំប្រឹងប្រែងជាបន្តរបស់ខ្ញុំទេ ហើយក៏មិនបានបំផ្លាញនូវការខិតខំដែលខ្ញុំធ្វើជាមួយ ចន ឃែរី ដែរ តែខ្ញុំរង់ចាំនូវអ្វីដែល ចន ឃែរី ត្រូវធ្វើជាមួយនឹង កូហ្វីអាណន់ ព្រោះកង្វល់ទៅជាស្ថានកណ្តាលរវាងខ្ញុំជាមួយ កូហ្វីអាណន់ ព្រោះអ្នកធ្វើការនៅជុំវិញ កូហ្វីអាណន់ អាចនឹងមិនយល់នូវការលំបាក ឬក៏ថាអាចនិយាយទៅចុះថាប្រហែលជាយើងនៅឆ្ងាយពីគ្នាពេក ខុសគ្នា១៣ម៉ោង ។ ឥឡូវនេះកំពុងខុសគ្នា១៣ម៉ោង យើងកំពុងថ្ងៃ គេកំពុងយប់ ។ ដូច្នេះអាចនឹងមិនយល់គ្នា ។ ពីនេះសារទៅ ឯនោះសារមក អ៊ីចឹងបានស្នើឲ្យលោក ចន ឃែរី គាត់ធ្វើកិច្ចការងារនេះ ។

**អ្នកកាសែតសួរៈ** សម្តេច...ថ្ងៃ១៥ ខែជូន (មិថុនា-June) ប្រសិនបើអត់មានឧបសគ្គអីម៉ោរារាំងទេ ដំណើរការហ្នឹងអាចឈានដល់ដំណាក់កាលចុងក្រោយទេ?

**សម្តេច ហ៊ុន សែនៈ** ១៥ មិថុនាអី ខ្ញុំអត់យល់ ។

**អ្នកកាសែតសួរៈ** ក៏ប៉ុន្តែលោក ចន ឃែរី គាត់បានមានប្រសាសន៍ថា ថ្ងៃ១៥អាចមានកិច្ចព្រមព្រៀងជាមួយគ្នាបញ្ចប់...

**សម្តេច ហ៊ុន សែនៈ** ខ្ញុំសុំនិយាយថា ខ្ញុំអត់មានរឿងបញ្ហារឿងចុះកិច្ចព្រមព្រៀង មិនចុះកិច្ចព្រមព្រៀងទេ ក៏ប៉ុន្តែខ្ញុំមិនមែនចង់បានដល់១៥មិថុនានោះទេ ខ្ញុំបានប្រាប់ ចន ឃែរី ថាឲ្យតែ កូហ្វីអាណន់ យល់ព្រមជាមួយខ្ញុំកុំបង្ខំឲ្យខ្ញុំចុះហត្ថលេខា ស្អែកក៏បានខាន ស្អែកក៏បានស៊ីសងលើលោកធ្វើលឿនប៉ុនណាទេ ខ្ញុំអត់មាន... ប៉ុន្តែ លោក ចន ឃែរី លោកបាននិយាយ គាត់ថា ១៥មិថុនា ឬ១៥ ឧសភា ក៏ប៉ុន្តែខ្ញុំចង់បានមុនហ្នឹងឆ្ងាយ ស្អែកក៏បាន ខានស្អែកក៏បាន ឲ្យតែអូយេឲ្យខ្ញុំមួយម៉ាត់ កុំបង្ខំឲ្យខ្ញុំចុះហត្ថលេខា ។ ខ្ញុំអាចផ្លាស់ប្តូរលិខិតបាន ប៉ុន្តែការផ្លាស់ប្តូរលិខិតពុំមានន័យជាការគាបសង្កត់ទៅលើសភាទាំងពីរ ក្រុមប្រឹក្សាធម្មនុញ្ញ និងព្រះមហាក្សត្រទេ អ៊ីចឹងទេខ្ញុំនឹងមិននិយាយពីកាលបរិច្ឆេទស្អែកក៏បាន ខានស្អែកក៏បានឲ្យតែកុំបង្ខំឲ្យខ្ញុំធ្វើនូវអ្វីដែលខ្ញុំមិនអាចធ្វើបាន ព្រោះខ្ញុំអត់ត្រូវការយកចិត្តបរទេសទេ ខ្ញុំយកចិត្តប្រជាជនខ្ញុំ ខ្ញុំយកចិត្តអ្នកតំណាងរបស់ប្រជាជន គឺសភា ព្រឹទ្ធសភា ហើយអ្នកដែលធ្វើកិច្ចការខាងច្បាប់ពិនិត្យស្របរដ្ឋធម្មនុញ្ញ ឬមិនស្របរដ្ឋធម្មនុញ្ញ គឺក្រុមប្រឹក្សាធម្មនុញ្ញ និងព្រះមហាក្សត្រជាទីសក្ការៈ ដែលមានព្រះរាជសិទ្ធិឡាយព្រះហស្តលេខាលើសេចក្តីព្រាងច្បាប់នោះ ។

**អ្នកកាសែតសួរៈ** សម្តេចថាកាត់ទោសពី៧០ ដល់៩៩ តើមានន័យយ៉ាងម៉េច?

**សម្តេច ហ៊ុន សែនៈ** ខ្ញុំសូមបញ្ជាក់ជូនថានិន្នាការទាមទារឲ្យកាត់ទោសពីឆ្នាំ៧០ ដល់ឆ្នាំ៩៩ កំពុងក្លាយជាការជាក់ស្តែងមួយ ហើយរឿងនេះខ្ញុំគិតថាវានឹងកើតនៅក្នុងសភា ដាក់ព្រឹបគឺពិភាក្សាចំណងជើងហើយ តើ៧៥-៧៩ ឬ៧០-៩៩? នេះជាបញ្ហាធំណាស់ ។ ខ្ញុំប្រាប់ឯកឧត្តម កូហ្វីអាណន់ នៅទីក្រុងបាងកក ខ្ញុំបានប្រាប់ថាខ្ញុំស្ថិតក្នុងវិឡុនកម្ម ។ មាននិន្នាការច្រើនណាស់ដែលខ្ញុំត្រូវសម្រួលបំពេញចិត្តអ្នកខាងក្រៅ ទើសចិត្តអ្នកខាងក្នុង ។ នៅឡាហាវ៉ាន់ខ្ញុំបានប្រាប់ថា ខ្ញុំមានការលំបាកណាស់ ។ ចរន្តប្រឆាំងនឹងវត្តមាននៃចៅក្រមនិងរដ្ឋអាជ្ញាបរទេសកើនឡើង ។ បន្ថែមទៅដល់ចរន្តនៃការដែលចង់ឲ្យមានការធ្វើគណនីយភាពពីឆ្នាំ៧០ ដល់៩៩ ។ ខ្ញុំក៏ប្រាប់ ចន ឃែរី នៅលើចំណុចនេះ ។ ចន ឃែរីថា ៧៥-៧៩តែខ្ញុំបានប្រាប់ ចន ឃែរី វិញថា ខ្ញុំមិនអាចបិទមាត់សមាជិកសមាជិកាសភា ឬសមាជិកសមាជិកាព្រឹទ្ធសភាបានទេ ។ ដូច្នេះបើសិនជាយើងយកវិធានការមិនបានល្អវានឹងអាចក្លាយមិនគ្រាន់តែច្បាប់នេះអនុម័តមិនបានប៉ុណ្ណោះទេ វាថែមទាំងក្លាយទៅជាវេទិកាកាត់ទោសសាធារណៈមួយតាមកញ្ចក់ទូរទស្សន៍នៅក្នុងសភាតែម្តង ។ សូមកុំភាន់ច្រឡំ ។ ឧក្រិដ្ឋកម្មកើតឡើងច្រើនណាស់លើទឹកដីកម្ពុជាមិនមែនតែ៧៥-៧៩ទេ ក៏ប៉ុន្តែយើងយោគយល់ៗ យើងចង់កម្រិតវង្វង់ឲ្យវានៅតូច ប៉ុន្តែអ្នកដទៃមិនព្រមយល់ដល់ការលំបាករបស់យើង ។ ដូច្នេះបានធ្វើឲ្យនិន្នាការនៃការទាមទារកាត់ទោសពីឆ្នាំ៧០ ដល់ ឆ្នាំ៩៩ កំពុងតែក្លាយទៅជាការពិតមួយដែលខ្ញុំមានការកង្វល់ៗមិនថាខ្ញុំអាចទប់ចរន្តនេះឈ្នះ ឬមិនឈ្នះ ព្រោះខ្ញុំគ្មានសិទ្ធិទៅបិទមាត់សមាជិកសភាណាម្នាក់ទេ ហើយរឿងនេះអស់លោកចាំមើលនៅពេលបើកសម័យប្រជុំសភាភ្លាមនឹងពិភាក្សាភ្លាម តែនៅលើចំណុចនេះឯង ប្រហែលជាមិនអាចអនុម័តចេញផង បើសិនគេទាំងឡាយនៅតែសង្កត់ ហ៊ុន សែន តទៅទៀត អ្នកនោះយល់

ច្រឡំហើយ ។ អ្នកដែលត្រូវសង្កត់គឺសង្កត់បាន ហ៊ុន សែន បានប៉ុនហ្នឹង ប៉ុន្តែមិនអាចសង្កត់សភា១២២នាក់បានទេ មតិ ១២២នាក់ ។ ដូច្នេះអាចនឹងវេទិកាឆ្លងច្បាប់នេះក្លាយទៅជាវេទិកាកាត់ទោសសាធារណៈ យ៉ាងហោចណាស់គេបានធ្វើគណនីយភាពអំពីឧក្រិដ្ឋកម្មរបស់អ្នកណាខ្លះ គេក៏អាចចោទសួរបានដែរថាគេដឹងពេលដែលខ្មែរក្រហមកាន់អំណាច៧៥-៧៩ ខ្មែរក្រហមអង្គុយនៅអង្គការសហប្រជាជាតិក្រោយដឹងថា ខ្មែរក្រហមប្រល័យពូជសាសន៍ ហើយគេជួយខ្មែរក្រហមឲ្យអង្គុយនៅអង្គការសហប្រជាជាតិពី៧៩ ដល់៨២ ហើយគេបន្តគាំទ្រខ្មែរក្រហមឲ្យស្ថិតនៅជាផ្នែកមួយនៃរដ្ឋាភិបាលចំរុះអង្គុយនៅអង្គការសហប្រជាជាតិពី៨២ រហូតដល់ឆ្នាំ៩១ ហើយនៅបន្តគាំទ្រខ្មែរក្រហមជាផ្នែកមួយក្រុមនៃក្រុមប្រឹក្សាជាន់ខ្ពស់ អែស. អ៊ិន.ស៊ី «ឧត្តមក្រុមប្រឹក្សាជាតិ» អង្គុយបន្តរហូតដល់យើងកើតមានរដ្ឋាភិបាលថ្មីមួយ ហើយពេលនោះអវត្តមានខ្មែរក្រហម ។ ក៏ប៉ុន្តែយើងត្រូវរំពឹងថា មកដល់ខែឧសភា ឆ្នាំ១៩៩៨ ហើយការចចារមួយនៅព្យួងយ៉ាងរវាងរាជរដ្ឋាភិបាលជាមួយនឹងខ្មែរក្រហមនៅមាននៅឡើយទេក្រោមព្រះរាជធិបតីភាពរបស់ព្រះមហាក្សត្រ និងសម្តេចព្រះសង្ឃរាជ ។ ដូច្នេះគេត្រូវយល់បញ្ហានេះឲ្យច្បាស់ អញ្ចឹងគេសួរថាហេតុអី? ហើយគេអាចសួរបានដែរថា បើសិនជាខ្មែរក្រហមចូលរួមបោះឆ្នោតឆ្នាំ៩៣ ពិតប្រាកដ ខ្មែរក្រហមព្រមអនុវត្តន៍នូវលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀង តើគេធ្វើអ្វីខ្មែរក្រហម? បើខ្មែរក្រហមមានកៅអីក្នុងសភាខ្មែរក្រហមក្លាយទៅជាបក្សនយោបាយស្របច្បាប់ខ្មែរក្រហមផ្ទេរកងទ័ព និងផ្ទេររដ្ឋបាលចូលទៅក្នុងរដ្ឋបាលចំរុះតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស តើគេធ្វើអីខ្មែរក្រហមពិតប្រាកដ? ដូច្នេះសំណុំបញ្ហាជាកញ្ចប់បញ្ហា មិនមែនជាបញ្ហាលេងសើចទេ ហើយមោតែសង្កត់ តែ ហ៊ុន សែន ធ្វើបាបតែ ហ៊ុន សែន រកតែពេលធ្វើការមិនបានផង ។ ខ្ញុំមានការច្រើនណាស់ លោកឃើញហើយ គ្រាន់តែអត្រាអ្នកកើតជម្ងឺរបេង៦៤ភាគរយ ឲ្យខ្ញុំពិភាក្សាតែពីរឿងកាត់ទោសខ្មែរក្រហម ធ្វើតែខ្មែរក្រហម តែខ្មែរក្រហមថិតថេរបាន តើអ្នកណាអ្នកជួយខ្មែរក្រហម? បញ្ហានេះជាប្រធានបទសុទ្ធតែដែលសភាសួរសភាឆ្លើយៗ ហើយបើសួរមករដ្ឋាភិបាលរដ្ឋាភិបាលឆ្លើយដាក់អង្គការសហប្រជាជាតិ ហើយខ្ញុំអត់មានឆ្លើយដាក់ពីណាទេ ។ ឆ្លងកាត់អស់អគ្គលេខាបីនាក់របស់អង្គការសហប្រជាជាតិ យៀត វុលហែម (Kurt Wald heim) ប៉េរ៉េ ដឺគូអេយ៉ា (Xavier Perez de Cuellar) និងប៊ូត្រុស ប៊ូត្រុសហ្គាលី (Boutros Boutros Ghali) ខ្ញុំនឹងឆ្លើយដាក់ទៅអង្គការសហប្រជាជាតិ បើសួរមករដ្ឋាភិបាលម៉េចបានខ្មែរក្រហមបានចូលកិច្ចព្រមព្រៀងប៉ារីសខ្ញុំឆ្លើយដាក់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិហើយ ហើយអគ្គលេខាធិការអង្គការសហប្រជាជាតិឆ្លើយ បន្តទៅថា ម៉ោពីអឺថាម៉ោពីបោះឆ្នោតនៅអង្គការសហប្រជាជាតិ អ៊ីចឹងទៅមើលប្រទេសណាខ្លះបោះឆ្នោតគាំទ្រខ្មែរក្រហមឲ្យអង្គុយទៅប្រទេសនោះទៀត ហើយប្រទេសណាខ្លះផ្តល់លុយ ផ្តល់អាវុធផ្តល់ទឹកដីផ្តល់ជម្រកស្អីៗសព្វបែបយ៉ាងរឿងច្រើនណាស់ ។ អ៊ីចឹងទេបានជាខ្ញុំពិភាក្សាប៉ុន្មានរយៈពេលកន្លងទៅនេះ ខ្ញុំចង់កម្រិតវាឲ្យវានៅត្រឹមតែ៧៥-៧៩ ក៏ប៉ុន្តែដល់តែពេលគេមិនព្រមគេធ្វើបាប ហ៊ុន សែន ពេក គឺវាទៅជាអាដែងចរន្ត៧០-៩៩រីក ។ នេះបញ្ហាត្រង់ហ្នឹងហើយដែលខ្ញុំមានការសោកស្តាយៗ ហើយខ្ញុំមិនដឹងថាច្បាប់ហ្នឹងអាចទៅដល់ណាទេ ប៉ុន្តែខ្ញុំបញ្ជាក់ឡើងវិញ ខ្ញុំនឹងខិតខំនូវអ្វីដែលបានព្រមព្រៀងជាមួយអ្នកច្បាប់របស់អង្គការសហប្រជាជាតិ អ្នកច្បាប់បារាំង អ្នកច្បាប់ឥណ្ឌា អ្នកច្បាប់រុស្ស៊ី អ្នកច្បាប់អាមេរិក ដើម្បីដាក់ជូនទៅសភា និងការពារគោលជំហររបស់រាជរដ្ឋាភិបាល ប៉ុន្តែគោលជំហររាជរដ្ឋាភិបាលគឺមិនត្រូវយកទៅគាបសង្កត់សភាទេ បើសភាអនុម័តយ៉ាងណាគឺយើងនឹងគោរពតាមសភាគ្មានអ្វីហួសពីនេះទេ ។ នេះជាការបែងចែកអំណាច ។ ខ្ញុំសុំអរគុណ ។

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# បញ្ហាដែនសមត្ថកិច្ចពេលវេលា១៩៧០-១៩៩៩ ត្រូវដោះស្រាយ

ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលបានឮថាមានកិច្ចខិតខំប្រឹងប្រែងពង្រីកដែនសមត្ថកិច្ចរបស់ពង្រាងច្បាប់ដែលបានស្នើឡើងឲ្យបង្កើតអង្គតុលាការព្រហ្មទណ្ឌចម្រុះមួយនាពេលអនាគតដើម្បីជំនុំជម្រះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្រៅរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ។ ខ្ញុំសរសេរលិខិតនេះដោយមានក្តីសង្ឃឹមមួយថារដ្ឋសភាជាតិនឹងពិចារណាការកម្រិតនូវដែនសមត្ថកិច្ចពេលវេលានៃច្បាប់នេះ ដើម្បីកុំឲ្យទាញអង្គជំនុំជម្រះក្តីនាពេលអនាគតខុសពីគោលដៅនាំយកមេដឹកនាំសំខាន់ៗទាំងអស់នៃរបបខ្មែរក្រហមមកកាត់ទោស ។


គណៈប្រតិភូចិនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ជាការច្បាស់ណាស់ថា គ្មាននរណាម្នាក់ប្រកែកថារបបកម្ពុជានៅពេលមុន និងក្រោយរបបខ្មែរក្រហមមិនត្រូវយកមកលាតត្រដាងអំពីក្តីអាម៉ាស់ជាសាធារណៈនៃរបបទាំងនោះឡើយ ។ រដ្ឋាភិបាល លន់ ណុល គឺជារបបពុករលួយមួយដែលមជ្ឈដ្ឋានមួយចំនួននិយាយថាបានប្រកាន់យកគោលជំហររបស់របបខ្លួនធ្វើជាអាយ៉ងមហាអំណាចបរទេសជាកត្តាអត្ថិភាព ដោយពុំគិតគូរអំពីសេចក្តីត្រូវការរបស់ប្រជាជនកម្ពុជា ។ មានមនុស្សមួយចំនួនទាញយកសម្មតិកម្មបង្ហាញថា មូលហេតុចម្បងដែលវៀតណាមឈ្លានពានកម្ពុជាក្នុងឆ្នាំ១៩៧៩ ជាការឆ្ពោះទៅបម្រើផលប្រយោជន៍ខ្លួនឯងជាជាងការផ្តល់ជំនួយមនុស្សធម៌ដល់មនុស្សជាតិ ។ គ្មានអ្វីគួរឲ្យសង្ស័យថារដ្ឋាភិបាលដែលលើកបន្តុបដោយវៀតណាម គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរំលោភសិទ្ធិមនុស្សដែលត្រូវបានការពារជាអន្តរជាតិដូចជាសេរីភាពក្នុងការបញ្ចេញមតិ និងការបង្កើតសមាគមន៍ ។ លើសពីនេះប្រវត្តិសាស្ត្រនាពេលថ្មីៗរបស់កម្ពុជាគឺត្រូវបានកត់សម្គាល់ដោយការជ្រៀតជ្រែកពីសំណាក់មហាអំណាចបរទេសនៅក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ។

គួរឲ្យកត់សម្គាល់ជាងគេបំផុតនោះគឺសហរដ្ឋអាមេរិកទទួលកិត្តិស័ព្ទជាប្រទេសដែលបានទម្លាក់គ្រាប់បែករាប់សិបពាន់គ្រាប់មកលើកម្ពុជាដោយរំលោភលើច្បាប់ក្នុងស្រុករបស់សហរដ្ឋ

អាមេរិកនៅក្នុងអំឡុងសង្គ្រាមវៀតណាម ។ ហើយបន្ទាប់ពីការឈ្លានពានឆ្នាំ១៩៧៩ ដោយប្រទេសវៀតណាម សមាជិកនៃសហគមន៍អន្តរជាតិបានបន្តចាត់ទុករបបខ្មែរក្រហមដែលត្រូវបានបណ្តេញចេញពីអំណាចថាជា «រដ្ឋាភិបាលស្របច្បាប់» របស់កម្ពុជា ។ ដោយសារការប្រឌិតដ៏គួរឲ្យស្ញើចនេះ «រដ្ឋាភិបាលនិរទេស» របស់ខ្មែរក្រហម ត្រូវបានអនុញ្ញាតឲ្យរក្សាកៅអីរបស់ខ្លួននៅក្នុងអង្គការសហប្រជាជាតិ សូម្បីតែភស្តុតាងនៃភាពឃោរឃៅដ៏សាហាវបំផុតនៃរបបនេះមានច្រើនសន្ធឹកសន្ធាប់ក៏ដោយ ។

ថ្វីត្បិតតែភាពពិតនៃប្រវត្តិសាស្ត្រកម្ពុជាដ៏អភ័ព្វគឺបែបនេះក៏ដោយ ក៏យើងមិនអាចប្រកែកបានថា ការរំលោភបំពានសិទ្ធិមនុស្សដែលបានកើតឡើងនៅក្នុងរបបទាំងនេះមានភាពមិនធ្ងន់ធ្ងរ បើប្រៀបធៀបទៅនឹងការរំលោភបំពាននានាដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ នៅក្នុងរបបខ្មែរក្រហមនេះប្រជាជនស្ទើរតែមួយភាគប្រាំនៃប្រទេសកម្ពុជាត្រូវបានប្រហារជីវិត ឬបង្ខំឲ្យធ្វើការបាក់កម្លាំងរហូតដល់ស្លាប់ ។ មន្ត្រីយោធារបបសាធារណរដ្ឋ និងគ្រួសាររបស់របបមន្ត្រីទាំងនោះត្រូវបានយកទៅសម្លាប់ជាខ្សែសង្វាក់យ៉ាងសាហាវព្រៃផ្សៃ ។ ក្រុមសមាជិកសង្គមដទៃទៀតដែលត្រូវបានដាក់ជាគោលដៅសម្លាប់ភ្លាមរួមមានមន្ត្រីទាំងឡាយដែលមាននិន្នាការជាមួយរបប លន់ ណុល បញ្ញាជនដែលបានទទួលការអប់រំពីបស្ចិមប្រទេស និងម្ចាស់ដីតូចធំជាច្រើន ។ ការប្រែក្លាយសង្គមទាំងមូលបែបឆ្កួតរបស់ពួកខ្មែរក្រហម ក៏តម្រូវឲ្យមានការបោសសម្អាតជនជាតិភាគតិចដទៃទៀតទាំងអស់ដូចជាអាណិកជនវៀតណាម ចាម និងជនជាតិភាគតិចដទៃទៀតដែលបានរស់នៅក្នុងទឹកដីកម្ពុជាជាយូរលង់ណាស់មកហើយ ។ របបខ្មែរក្រហមបានធ្វើឲ្យ «អ្នកដទៃ» ខ្សោះ ហើយងាកមករណបតាមពួកខ្លួនយ៉ាងឆាយ ។ ការប៉ុនប៉ងធ្វើរដ្ឋប្រហារដែលត្រូវបានចោទដោយពុំមានសម្អាងនៅក្នុងឆ្នាំ១៩៧៦ ជម្រុញឲ្យមានការធ្វើបន្សុទ្ធកម្មទ្រង់ទ្រាយធំសំដៅលើមេដឹកនាំក្នុងបក្សកម្មាភិបាលមូលដ្ឋាន និងសមាជិកយោធា ។ បណ្ណសារដ្ឋាននៅទួលស្លែងដែលជាប្រព័ន្ធធ្វើទារុណកម្ម និងប្រហារជីវិតកំពូល ចង្អុលបង្ហាញថា



ប្រជាជនប្រមាណ២ម៉ឺននាក់បានបាត់បង់ជីវិតនៅទីនោះ ។ ជនរងគ្រោះភាគច្រើននៅទីនោះគឺជាខ្មែរក្រហមខ្លួនឯង ។

នៅក្នុងរយៈកាលរបបខ្មែរក្រហម ប្រជាជនកម្ពុជាបានទទួលរងនូវការរំលោភបំពានច្បាប់អន្តរជាតិដ៏ធ្ងន់ធ្ងរបំផុតគឺអំពើប្រល័យពូជសាសន៍ ទារុណកម្ម ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ការរំលោភបំពានសិទ្ធិមនុស្សទាំងនេះគឺត្រូវបានចាត់ទុកមានកម្រិតធ្ងន់ធ្ងរដែលក្លាយទៅជាឧក្រិដ្ឋកម្មអន្តរជាតិដែលច្បាប់អន្តរជាតិតម្រូវឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ។ តាមពិត ការរំលោភបំពានទាំងនេះគឺស្ថិតនៅក្រោមគោលការណ៍ដែនសមត្ថកិច្ចសកលដែលចែងថា ប្រទេសណាមួយក៏អាចមានសិទ្ធិនាំយកជនល្មើសរំលោភបំពានបទដ្ឋានទាំងនេះមកកាត់ទោសបានដោយមិនគិតអំពីសញ្ជាតិរបស់ជនរងគ្រោះ ជនដៃដល់ ឬទីកន្លែងប្រព្រឹត្ត ។ នីតិវិធីនានាដែលចាប់ផ្តើមដោយប្រទេសអេស្ប៉ាញប្រឆាំងនឹងសមាជិកនានានៃយោធាអាហ្សង់ទីន និងឈីលី (ដែលក្នុងនោះអតីតឧត្តមសេនីយ៍ ពីណូចេតឡូវនេះជារឿងក្តីដ៏ល្បីល្បាញនិងធំបំផុត) ផ្តល់នូវឧទាហរណ៍

ថ្មីៗស្រឡាងនាពេលបច្ចុប្បន្ន អំពីគោលការណ៍ដែនសមត្ថកិច្ចនេះ ពីព្រោះឧក្រិដ្ឋកម្មទាំងនេះបានរំលោភបំពានមនុស្សជាតិទូទៅដែលសហគមន៍អន្តរជាតិព្យាយាមដើរតួនាទីមួយនៅក្នុងការជំនុំជម្រះក្តីជនល្មើសទាំងនោះនៅតាមបណ្តាប្រទេសមួយចំនួនដូចជាយូហ្គោស្លាវី រ៉្វាន់ដា និងក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។ អង្គជំនុំជម្រះក្តីចម្រុះដែលបានស្នើឡើង និងជាប្រភេទអង្គជំនុំជម្រះពិសេសដែលបង្កើតឡើងតាមកាលៈទេសៈដែលអាចនិយាយបានថាជាអង្គតុលាការអចិន្ត្រៃយ៍មួយដែលមានដែនសមត្ថកិច្ចគ្មានកំណត់ ។ ជាឧទាហរណ៍ដែនសមត្ថកិច្ចពេលវេលានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាត្រូវបានកំណត់ត្រឹមឆ្នាំ១៩៩៣ ជាឆ្នាំដែលអំពើប្រល័យពូជសាសន៍ដ៏សន្ធឹកសន្ធាប់បំផុតត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសនេះ ។ ជាភ័ស្តុតាងច្បាប់ឧក្រិដ្ឋកម្មជាច្រើនបានកើតឡើងមុននិងបន្ទាប់រយៈពេលនេះ ។ ក៏ប៉ុន្តែអង្គការសហប្រជាជាតិបានសម្រេចចិត្តកម្រិតដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះនេះឲ្យមានអំណាចនាំយកមកកាត់ទោសនូវឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតក្រោមច្បាប់អន្តរជាតិដែលឧក្រិដ្ឋកម្មភាគច្រើនត្រូវបានប្រព្រឹត្តឡើងនៅក្នុងឆ្នាំ១៩៩៣ ។ ទម្រាំដល់មានតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍មួយដែលជាគោលដៅរំពឹងទុក (នៅក្រុងរ៉ូម អ៊ីតាលី) ចាប់តាំងពីសង្គ្រាមលោកលើកទី១មកហើយដែលទើបតែឥឡូវនេះបានចេញជាផ្លែផ្កា អង្គជំនុំជម្រះក្តីពិសេសដែលបង្កើតឡើងតាមកាលៈទេសៈនឹងមានដែនសមត្ថកិច្ចដែលត្រូវបានកម្រិតមួយតាមភាពចាំបាច់ និងគម្រោងនៃការបង្កើតឡើង ។ អង្គការសហប្រជាជាតិបានចង្អុលបង្ហាញយ៉ាងខ្លីច្បាស់ថា ខ្លួននឹងជួយជ្រោមជ្រែងនៅក្នុងកិច្ចការតុលាការនេះក្នុងលក្ខខណ្ឌដែលតុលាការនេះផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនមកលើរយៈកាលរបបខ្មែរក្រហមដើម្បីបម្រើមូលហេតុនានាដែលត្រូវបានគូសបញ្ជាក់ខាងលើ ។ ពង្រាងច្បាប់នេះគួរតែត្រូវបានព្រាងឡើងនៅក្នុងរបៀបមួយដើម្បីអនុញ្ញាតឲ្យមានការចូលរួមពីសហគមន៍អន្តរជាតិនៅក្នុងកិច្ចការតុលាការនេះពីព្រោះថាកម្ពុជាចាំតែទទួលបាននូវផលប្រយោជន៍ដ៏សន្ធឹកសន្ធាប់ពីការបង្កើតអង្គជំនុំជម្រះក្តីចម្រុះមួយដែលចូលរួមដោយបុគ្គលិកក្នុងស្រុកនិងបុគ្គលិកអន្តរជាតិ ។ ប្រព័ន្ធច្បាប់របស់កម្ពុជាស្ថិតនៅក្នុងតំណាក់កាលអភិវឌ្ឍន៍មួយនៅឡើយ ។ ដោយមានការចូលរួមពីអង្គការសហប្រជាជាតិនៅក្នុងជំនុំជម្រះក្តីនេះកម្ពុជានឹងទទួលបាននូវជំនួយដ៏សំខាន់ជាច្រើននៅក្នុងវិស័យបច្ចេកវិទ្យាច្បាប់ រចនាសម្ព័ន្ធ និងសម្ភារ ។ អង្គជំនុំជម្រះក្តីចម្រុះពិសេសតែមួយគត់នេះនឹងផ្តល់ដល់ចៅក្រម និងមេធាវីកម្ពុជានូវឱកាសបានធ្វើការជាដៃគូជាមួយនឹងមេធាវី និងចៅក្រមដ៏ល្បីល្បាញបំផុតមួយចំនួននៅក្នុងពិភពលោក ។ ដោយយោងទៅតាមសកម្មភាពនៃអង្គជំនុំជម្រះក្តីពិសេសដែលបង្កើតឡើងតាមកាលៈទេសៈទាំងពីរដែលបានបង្កើតសម្រាប់ប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដាសមាជិក និងសហគមន៍អន្តរជាតិបានអភិវឌ្ឍនូវជំនាញដ៏សំខាន់នៅក្នុងការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ អង្គជំនុំជម្រះក្តីកម្ពុជាគួរតែទាញយកផលប្រយោជន៍ពីបទពិសោធន៍នៃអង្គជំនុំជម្រះក្តីទាំងពីរនេះជាជាងត្រូវចាប់ផ្តើមពីបាតដៃទទេ ។ ដោយមូលហេតុទាំងនេះហើយដែលពង្រាងច្បាប់នេះគួរព្រាងឡើងនៅក្នុងរបៀបមួយដែលមិនរារាំងដល់ការចូលរួមពីសំណាក់អង្គការសហប្រជាជាតិ ។

ជាសង្ខេប ខ្ញុំសូមលើកទឹកចិត្តឲ្យរដ្ឋាភិបាលកម្ពុជាធ្វើការព្រាងច្បាប់មួយដែលផ្តល់អំណាចដល់អង្គជំនុំជម្រះក្តីនាពេលខាងមុខដើម្បីកាត់ទោសតែបុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ពីបទបានប្រព្រឹត្តការរំលោភបំពានធ្ងន់ធ្ងរបំផុតលើច្បាប់អន្តរជាតិនៅក្នុងរបបខ្មែរក្រហម ។ តាមរបៀបនេះ អង្គជំនុំជម្រះក្តីនឹងផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនមកលើការដាក់ឲ្យមានការទទួលខុសត្រូវមួយចំពោះប្រវត្តិសាស្ត្រដ៏គួរឲ្យភ័យរន្ធត់របស់កម្ពុជានិងក្នុងពិភពលោកមួយនេះ ។ ជាបន្ថែមអង្គជំនុំជម្រះក្តីនេះក៏ដូចជាប្រទេសកម្ពុជានឹងទទួលបាននូវផលប្រយោជន៍ពីការចូលរួមជាអន្តរជាតិ ។ ជនរងគ្រោះដោយអំពើឃោរឃៅដែលប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមសក្តិសមនឹងទទួលការជំនុំជម្រះមួយដែលមានលក្ខណៈមាំទាំនិងប្រសិទ្ធិភាព ។

**អេលីហ្សាប៊ែត វ៉ាន់ស្លាក់**

**មេធាវីមជ្ឈមណ្ឌលសម្រាប់យុត្តិធម៌ និងការទទួលខុសត្រូវ**

**សហរដ្ឋអាមេរិក**

# ម្ភៃប្រាំឆ្នាំក្រោយស្រមោលនៃការពិត

## ការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងបរិបទអន្តរជាតិ

**(តពីលេខមុន)** បញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងនេះ÷ កន្ទុះប្រព័ន្ធយុត្តិធម៌ដ៏មាំទាំ ជនរំលោភបំពានមានសិទ្ធិអំណាចនិងឥទ្ធិពលធំធេងនៅក្នុងសង្គម និងបញ្ហានៃការធានាអភ័យឯកសិទ្ធិពីការកាត់ទោសមានសក្តានុពលអាចរារាំងការប៉ុនប៉ងនាំយកជនល្មើសដែលបានប្រព្រឹត្តខុក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមកកាត់ទោស ។ បញ្ហានេះបានបង្កើតឲ្យមានជម្រើសពីរយ៉ាងគឺ អង្គជំនុំជម្រះក្តីជាលក្ខណៈអន្តរជាតិ និងគណៈកម្មការស្វែងរកការពិត ។ ដោយសារថា ប្រព័ន្ធយុត្តិធម៌និងរដ្ឋាភិបាលនៃបណ្តាប្រទេសជាច្រើនសបញ្ជាក់ឲ្យឃើញថា ពុំមានធនធានចាំបាច់ដើម្បីកាត់ទោសខុក្រិដ្ឋជនរំលោភបំពានសិទ្ធិមនុស្សនៅក្នុងដែនដីរបស់ខ្លួន សហគមន៍អន្តរជាតិបានចាប់ផ្តើមស្វែងរកយុត្តិធម៌ជាលក្ខណៈអន្តរជាតិ ហេតុផលគឺថាមានខុក្រិដ្ឋកម្មមួយចំនួនដែលមានលក្ខណៈធ្ងន់ធ្ងរ ពេកដែលធ្វើឲ្យជនប្រព្រឹត្តខុក្រិដ្ឋកម្មទាំងនោះពុំអាចត្រូវបានការពារដោយអធិបតេយ្យភាព ឬដែនសមត្ថកិច្ចនៃប្រទេសនោះ ។

ការចាប់ខ្លួន និងការប៉ុនប៉ងធ្វើបត្យាប័នឧត្តមសេនីយ៍ពីណូចេ នាពេលថ្មីៗនេះ ពីបទចោទប្រកាន់ថាឧត្តមសេនីយ៍រូបនេះមានតួនាទីនៅក្នុងការប្រព្រឹត្តអំពើទារុណកម្មនិងការបាត់ខ្លួនរាប់ពាន់ករណីនៅក្នុងប្រទេសឈីលី បានធ្វើឲ្យមានការចាប់អារម្មណ៍ដ៏ខ្លាំងក្លាចំពោះកិច្ចខិតខំប្រឹងប្រែងបង្កើតឲ្យមានតុលាការសិទ្ធិមនុស្សពិភពលោកមួយ ។ ដើម្បីសម្រេចបាននូវគោលដៅនេះ តុលាការអន្តរជាតិពីរត្រូវបានបង្កើតឡើងដើម្បីនាំយកខុក្រិដ្ឋជនសង្គ្រាមពីប្រទេសរ៉ាន់ដា និងអតីតយូហ្គោស្លាវី មកកាត់ទោស ទោះបីជាការនាំយកខុក្រិដ្ឋជនមកកាត់ទោសជាអន្តរជាតិអាចធ្វើឲ្យជនទាំងនោះទទួលទោសចំពោះខុក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តក៏ដោយ លទ្ធផលជាអវិជ្ជមានគឺស្ថិតនៅត្រង់ថា ដំណើរការកាត់ទោសនៅក្រៅប្រទេសធ្វើឲ្យជនរងគ្រោះឃ្លាតឆ្ងាយពុំបានដឹងឮ និងឃើញដោយផ្ទាល់ភ្នែកនូវដំណើរការស្វែងរកយុត្តិធម៌នេះ ហេតុដូច្នេះធ្វើឲ្យលទ្ធផលដែលសង្គមជាតិរបស់ជនរងគ្រោះទទួលបានមានតិចជាអតិបរមា ។ ជម្រើសមួយទៀតដែលប្រទេសមួយចំនួនបានជ្រើសរើសមកទល់ពេលនេះ គឺការបង្កើតគណៈកម្មការស្វែងរកការពិតជាផ្លូវការមួយ ។ គណៈកម្មការស្វែងរកការពិតទាំងនេះជានិច្ចកាលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល ហើយជួនពេលខ្លះដោយមានការគាំទ្រជាអន្តរជាតិដើម្បីស៊ើបអង្កេត និងធ្វើរបាយការណ៍ពីការរំលោភបំពានសិទ្ធិមនុស្សក្នុងអតីតកាល និងកេរដំណែលដែលបន្សល់ទុកដោយការរំលោភបំពានទាំងនោះ ។ គណៈកម្មការស្វែងរកការពិតទាំងនោះមានជាច្រើនសណ្ឋានដោយមានកម្រិតអំណាចខុសៗគ្នា ហើយផ្តល់សម្លេងដល់ជនរងគ្រោះឲ្យបកស្រាយអំពីការឈឺចាប់របស់ខ្លួន ដែលជាផ្នែកមួយនៃដំណើរការស្វែងរកការពិត ។

នៅអាហ្វ្រិកខាងត្បូង គណៈកម្មការស្វែងរកការពិតនិងបង្រួបបង្រួមជាតិមានសិទ្ធិអំណាចប្រហាក់ប្រហែលនឹងតុលាការមួយដែរ ដោយមានសិទ្ធិផ្តល់និងបដិសេធការដាក់ពាក្យសុំលើកលែងទោសពីបណ្តាជនរំលោភបំពានសិទ្ធិមនុស្សនៅគ្រប់ករណីទាំងអស់នៃជម្លោះនៅក្នុងប្រទេសនេះ ។ ដើម្បីឲ្យជនល្មើសទទួលបាននូវការលើកលែងទោស ជនល្មើសត្រូវបានតម្រូវឲ្យបកអាក្រាតអំពីតួនាទីរបស់ខ្លួនជាសាធារណៈក្នុងការរំលោភបំពានសិទ្ធិមនុស្ស និងត្រូវផ្តល់ព័ត៌មានទាំងអស់ ដែលជនល្មើសនោះបានដឹងដល់គណៈកម្មការនេះ ។ ដំណើរការនេះត្រូវបានចាក់ផ្សាយតាមទូរទស្សន៍ ហើយនាំឲ្យប្រជាជនជាច្រើនបានយល់ដឹងពីជោគវាសនារបស់មិត្តភក្តិ និងសមាជិកគ្រួសាររបស់ខ្លួន ។ ជួនពេលខ្លះគណៈកម្មការស្វែងរកការពិតនេះបានបញ្ជាឲ្យជនល្មើសវិលត្រឡប់ទៅសហគមន៍ណាមួយដែលជនល្មើសទាំងនោះបានប្រព្រឹត្តខុក្រិដ្ឋកម្មដើម្បីសុំខមាទោស និងស្វែងរកទម្រង់នៃការផ្សះផ្សាណាមួយរវាងជនល្មើស និងជនរងគ្រោះ ។ ករណីដ៏ល្បីល្បាញបំផុតគឺ ករណីលោកប្រាយអិន មីចសែល ដែលគណៈកម្មការបានស្នើសុំឲ្យវិលត្រឡប់ទៅកាន់សហគមន៍ ឈ្មោះ ត្រាស៊ីក ដើម្បីសុំខមាទោសនៅក្នុង

អង្គប្រជុំដ៏ធំមួយ នៅកណ្តាលទីក្រុងអំពីបទដែលគាត់បានដឹកនាំការសម្លាប់រង្គាលលើមនុស្ស១១នាក់ ។ ការសុំខមាទោសបាននាំឲ្យមានទំនាក់ទំនងជាបន្តរវាង មីចសែល និងសហគមន៍នេះ ។ ក្រោយពីសុំខមាទោសរួច មីចសែល ត្រូវបានអញ្ជើញឲ្យវិលត្រឡប់ទៅចូលរួមក្នុងការប្រារព្ធពិធីសប្បាយនានានៅក្នុងសហគមន៍ ។ ទោះបីពុំមានលក្ខណៈទូទៅនៅទីនោះក៏ដោយ ក៏រឿងក្តីនេះល្បីរន្ទឺនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូងជាផ្នែកមួយនៃការស្វែងរកការផ្សះផ្សាជាតិនៅក្នុងប្រទេសនេះ ។ ការធ្វើបែបនេះបានបើកចំហនូវកន្លែងមួយនៅក្នុងសង្គម និងនៅក្នុងសហគមន៍សម្រាប់ឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងជនល្មើសនិងជនរងគ្រោះដើម្បីបង្កើតបរិយាកាសផ្សះផ្សាគ្នាជាបន្ត ។ គំរូនេះត្រូវបានបណ្តាប្រទេសដទៃទៀតមានបំណងយកទៅប្រើប្រាស់ដើម្បីធ្វើការផ្សះផ្សានៅក្នុងសហគមន៍នៃប្រទេសរបស់ខ្លួន ។

ក៏ប៉ុន្តែ គណៈកម្មការស្វែងរកការពិតនៅអាហ្វ្រិកខាងត្បូងមានឈ្មោះល្បីល្បាញចំពោះតួនាទីរបស់ខ្លួនជាវេទិកាផ្តល់ឲ្យជនរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្សនូវឱកាសបញ្ចេញសម្លេងរបស់ខ្លួន ។ ជនរងគ្រោះនីមួយៗត្រូវបានផ្តល់ឲ្យនូវសិទ្ធិផ្តល់កសិណ ឬប្រាប់សាច់រឿងរបស់ខ្លួន ហើយជនរងគ្រោះជាច្រើនត្រូវបានជ្រើសរើសឲ្យឡើងបកស្រាយរឿងរ៉ាវរបស់ខ្លួនជាសាធារណៈ ។ ការបកស្រាយរឿងរ៉ាវបែបនេះត្រូវបានរៀបចំឡើងដោយគណៈកម្មការនេះ ហើយត្រូវបានចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍រាប់សិបសប្តាហ៍ ហើយបានជ្រួតជ្រាបគ្រប់ទិសតំបន់នៅអាហ្វ្រិកខាងត្បូងទាំងមូល ។ ប្រជាជនតិចតួចបំផុតដែលពុំបានដឹង និងទទួលឥទ្ធិពលពីយន្តការនេះហើយគ្រប់មជ្ឈដ្ឋានពុំអាចនឹងបដិសេធអំពីសារជាតិដ៏សាហាវព្រៃផ្សៃនៃរបបអាប៉ាថេតជាបន្តទៀត ។ ប្រទេសអាហ្វ្រិកខាងត្បូងបានផ្តល់នូវមាគ៌ាដ៏ល្អសម្រាប់គណៈកម្មការស្វែងរកការពិតផ្សេងៗទៀត ក៏ប៉ុន្តែគណៈកម្មការភាគច្រើនពុំមានធនធាន ឬអាណត្តិដើម្បីធ្វើកិច្ចការឲ្យបានចប់ជាស្ថាពរបែបនេះឡើយ ។ ជាឧទាហរណ៍ នៅប្រទេសហ្គាតេម៉ាឡា អាជ្ញាធររបស់គណៈកម្មការស្វែងរកការពិតក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សមានកម្រិតបំផុត ហើយអំពើល្មើសទាំងអស់ស្ទើរតែពុំមានបានបកស្រាយបំភ្លឺអ្វីទាំងអស់មកទល់ពេលនេះដំណើរការនៃការស៊ើបអង្កេតដែលបានអនុវត្តក្នុងលក្ខណៈសម្ងាត់ដ៏តឹងរ៉ឹង ។ ជាលទ្ធផលប្រទេសនេះពុំបានដើរទន្ទឹមនឹងគណៈកម្មការស្វែងរកការពិតនៅក្នុងបេសកកម្មរបស់ខ្លួនដើម្បីស្រាយបំភ្លឺនូវអ្វីដែលបានកើតឡើងឲ្យបានពិតប្រាកដនោះទេ ។

ហេតុដូច្នេះ ប្រទេសកម្ពុជាកំពុងតែស្ថិតនៅត្រង់ចំណុចរបត់ដែលចារិកដោយចលករជាអន្តរជាតិមួយឆ្ពោះទៅរកការដោះស្រាយបញ្ហាប្រវត្តិសាស្ត្រ និងការចងចាំជាផ្នែកមួយនៃអន្តរកាលឆ្ពោះទៅលទ្ធិប្រជាធិបតេយ្យ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តដោយរបបខ្មែរក្រហមគឺធំធេងណាស់ ។ កម្ពុជាកំពុងប្រឈមមុខនឹងការសម្រេចចិត្តដ៏សំខាន់បំផុតចំពោះឧក្រិដ្ឋកម្មទាំងនោះ ។ ចាប់តាំងពីសប្តាហ៍ដែល អៀង សារី ខៀវ សំផន និង នួន ជា បានបង្ហាញខ្លួនចេញពីចលនាខ្មែរក្រហមដែលត្រូវបានបែកបាក់ជាទម្ងន់ក្នុងឆ្នាំ១៩៩៨ ប្រទេសកម្ពុជាបានមមាញឹកនៅក្នុងការពិភាក្សាអំពីបញ្ហាខ្មែរក្រហមដែលបានរីករាលដាលពាសពេញពិភពលោក នៅក្នុងពេលនៃការពិភាក្សានោះ សម្តេច ហ៊ុន សែន ត្រូវបានកាសែតញូវយ៉កថែមដកស្រង់ប្រសាសន៍ថា «យើងគួរតែជីករណ្តៅកប់អតីតកាល ហើយសម្លឹងឆ្ពោះទៅសតវត្សរ៍ទី២១ ដោយបំភ្លេចចោលនូវអតីតកាលខ្មៅងងឹត» ។ សម្តេចបានបន្ថែមទៀតថា «ប្រសិនបើដំបៅមិនឈឺកុំយកឈើចាក់ឲ្យចេញឈាម» ។ ក៏ប៉ុន្តែប្រតិកម្មចេញពីសហគមន៍កម្ពុជា និងសហគមន៍អន្តរជាតិបានជំរុញឲ្យសម្តេច ហ៊ុន សែន បន្ទន់ឥរិយាបថងាកមករកការព្រមព្រៀងនាំយកមកកាត់ទោសនូវមេដឹកនាំខ្មែរក្រហមក្នុងកិច្ចខិតខំប្រឹងប្រែងរួមមួយជាមួយនឹងអង្គការសហប្រជាជាតិ ។ ការចរចាជាច្រើនបានបន្តរហូតមកដល់ខែមីនា ឆ្នាំ២០០០នេះ នៅក្នុងពេលដែលភាគីទាំងសងខាងបានធ្វើការរួមគ្នាដើម្បីបង្កើតអង្គជំនុំជម្រះក្តីមួយការពិភាក្សាក៏ចេះតែបន្តអំពីថាតើការជំនុំជម្រះក្តីទាំងនោះគួរតែរៀបចំឡើងយ៉ាងដូចម្តេច ហើយមេដឹកនាំខ្មែរក្រហមណាខ្លះដែលគួរចោទប្រកាន់ ។ ជាបន្ថែមការចរចាទាំងនោះក៏បានពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួនទៀត ដូចជាតួនាទីរបស់ប្រជាជនកម្ពុជានៅក្នុងដំណើរការកាត់ទោសនេះ ។



២៥ឆ្នាំក្រោយរបបប្រល័យពូជសាសន៍

ការមិនទុកចិត្តចំពោះប្រព័ន្ធយុត្តិធម៌នៅកម្ពុជាក៏ដូចជាភាពអល់អែករបស់សម្តេច ហ៊ុន សែន ក្នុងការប្តេជ្ញាចិត្តឈានទៅរកការសម្រេចឲ្យមានការកាត់ទោសនានា គឺជាចលករដែលបានរុញសហគមន៍អន្តរជាតិឲ្យចូលពាក់ព័ន្ធក្នុងរឿងនេះ ។ អ្នកកាសែត សេត ម៉ាយដេន នៃកាសែតញូវយ៉កថែម បានសរសេរអត្ថបទមួយនៅក្នុងឆ្នាំ១៩៩៨ ដែលបានចុះផ្សាយនៅក្នុងកាសែតញូវយ៉កថែមថា «កេរដំណែលមួយក្នុងចំណោមកេរដំណែលដែលរបបខ្មែរក្រហមបានបន្សល់ទុកក្រៅពីភាពក្រីក្រ អំពើហិង្សា ការនិរាសព្រាត់ប្រាស និងភាពឆ្កួតលីលា គឺជាអ្វីដែលលោក ថូម៉ាស់ ហាម៉ាប៊ឺក តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាហៅថា «វប្បធម៌នៃភាពរួចទោស» ។

នៅក្នុងខណៈដែលប្រទេសកម្ពុជាខិតខំនូវបុណ្យខួបទី២៥ នៃការផ្តួលរំលំរបបខ្មែរក្រហមចេញពីក្រុងភ្នំពេញបានមកដល់ភាពច្បាស់លាស់ដោយគ្មានមន្ទិលសង្ស័យតទៅទៀត គឺថាប្រទេសកម្ពុជា និងប្រជាជនកម្ពុជាមានកាតព្វកិច្ចជីករកការពិតនៅក្នុងស្រមោលប្រវត្តិសាស្រ្តនេះ ដែលបានយាយីដល់ប្រទេសជាតិទាំងមូលនាពេលបច្ចុប្បន្ន ពិភពលោកទាំងមូលកំពុងតែបានបោលភ្នែកសម្លឹងឆ្ពោះមកកម្ពុជាដោយទន្ទឹងរង់ចាំនូវការសម្រេចចិត្ត និងការចាត់វិធានការរបស់កម្ពុជា ថាតើកម្ពុជានឹងធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហម ឬក៏សមាជិកជាន់ខ្ពស់នៃរបបខ្មែរក្រហមដែរឬទេ ។ នៅក្នុងខណៈដែលប្រទេសកម្ពុជាប្រឈមមុខនឹងជម្រើសទាំងអស់នេះ ប្រទេសកម្ពុជាក៏មានបន្ទុកមួយដែលត្រូវឆ្លើយតបទៅនឹងការទទួលខុសត្រូវចំពោះមនុស្សជាតិទូទាំងពិភពលោក ។ ទោះបីជាចលករដើម្បីបង្កើតឡើងនូវអង្គជំនុំជម្រះក្តីលក្ខណៈអន្តរជាតិបែបនេះពុំស្ថិតនៅក្នុងកណ្តាប់ដៃនៃប្រទេសកម្ពុជាក៏ដោយ ព្រឹត្តិការណ៍នៃការកាត់ទោសរបបខ្មែរក្រហមនៅក្នុងប៉ុន្មានខែក្រោយនេះនឹងប្រាកដជាមានឥទ្ធិពលមកលើការអភិវឌ្ឍនៅក្នុងប្រទេសនេះ ។ មិនតែប៉ុណ្ណោះប្រទេសកម្ពុជាកំពុងតែប្រឈមមុខទៅនឹងអតីតកាលរបស់ខ្លួនតាមរបៀបផ្សេងទៀត ទោះបីជាមកដល់ពេលនេះពុំមានគណៈកម្មការស្វែងរកការពិតជាផ្លូវការដែលគ្រប់គ្រងដោយរដ្ឋាភិបាលក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាលទូទាំងប្រទេស និងជាអន្តរជាតិបានតស៊ូស៊ុតស្វាញក្នុងការគាស់រំលើងនូវការពិតជាលម្អិតអំពីអំពើឃោរឃៅព្រៃផ្សៃរបស់របបខ្មែរក្រហម មានវិមានរំឭកដល់ជនរងគ្រោះ និងកសិណសាក្សីជាច្រើនត្រូវបានកត់ត្រា និងនិយាយប្រាប់ ។ លោក សេត ម៉ាយដេន បានទាញហេតុផលថាប្រវត្តិសាស្រ្តនៃរបបខ្មែរក្រហម គឺជាផ្នែកមួយនៃជីវិតនៅក្នុងប្រទេសកម្ពុជា ។ លោក សេត ម៉ាយដេន បានដកស្រង់សម្តីជនរងគ្រោះក្រោមរបបខ្មែរក្រហមម្នាក់មកសរសេរថា «ប្រជាជនកម្ពុជានិយាយថានៅពេលរដូវផ្លាស់ប្តូរទឹកទន្លេសាបដែលហូរកាត់ទីក្រុងភ្នំពេញក៏ហូរផ្លាស់ប្តូរទិសទៅតាមរដូវដែរ ។ ចំពោះប្រជាជនកម្ពុជាទន្លេគឺជានិមិត្តសញ្ញានៃប្រទេសរបស់ខ្លួន ។ ទឹកមិនដែលនៅនឹងហើយ អតីតកាលរមែងមិនដែលស្ថិតនៅក្នុងអតីកាលរហូតទេ វាអាចត្រឡប់មកវិញម្តងហើយម្តងទៀតដោយនាំយកមកនូវកម្មេចកម្មុំដែលប្រមែប្រមូលមកពីគ្រប់ទិសទី ។

**ម៉ៃឃើល ស៊ីប្ល័រ**

# មាស សារិន បានដឹងអំពីជោគវាសនារបស់បងប្អូនជីដូនមួយ តាមរយៈទស្សនាវដ្តី "ស្វែងរកការពិត"

**(តពីលេខមុន)**

ស (សួរ)ៈ ពេលមកដល់ភូមិតាកែវ កំពង់ចាម តើពួកខ្មែរក្រហមដឹងថា អ៊ំ និង ទីវ មុី ជាបងប្អូនរបស់ ទីវ អុល ធ្វើការនៅភ្នំពេញទេ?

ឆ (ឆ្លើយ)ៈ ដឹងថាសាច់ញាតិដែរ ប៉ុន្តែគេ «ពួកខ្មែរក្រហម» របៀបមិនសូវយកចិត្តទុកដាក់ព្រោះថាសូម្បីតែពោះម៉ែ ទីវ មុី ប៉ុន្មាន សាច់ថ្លៃក៏ដោយ សាច់បង្កើតក៏ដោយយកអស់ ។ ទីវ មុី ទាំងបងស្រី បងប្រុស បងថ្លៃ ព្រមទាំងឈ្នួលមួយនៅជាមួយក៏យកទៅសម្លាប់ដែរ ពេលប្រជុំម្តងៗគេថា «**ដកស្មៅ ដកឲ្យអស់ទាំងឫស**» ។ បើកូនអ្នកថ្មីមួយណា វ៉ៃអាបងវ៉ៃអាប្អូនដែលអាយុ ៨ឆ្នាំទៀត វ៉ៃហើយបោះចោលក្នុងគុម្ពឫស្សីអត់នរណាហ៊ានយកទៅកប់ទេ ។ ម្តាយឈរយំទឹកភ្នែកលួចលាក់ៗមិនហ៊ានឲ្យគេដឹង ។



សៈ អ៊ីចឹងក្រៅពីសំបុត្រមួយដែល ទីវ អុល សរសេរឲ្យក្នុងឆ្នាំ៧៥ហ្នឹង មានសំបុត្រអ៊ីផ្សេងទៀតដែលគាត់សរសេរមកអ៊ំទេ?

ឆៈ អត់ទេ! សរសេរតែម្តងគត់ ។ សំបុត្រនោះសរសេរថាឲ្យខ្ញុំលត់ដំ គាត់មិនមានពេលមកជួបខ្ញុំទេគាត់នៅភ្នំពេញ ។ ពេលជម្លៀសចេញពីភ្នំពេញទៅនោះខ្ញុំដូចចង់ឆ្កួតណា៎ ណាខ្ញុំរង្វេងប្តីទៀត ខ្ញុំទៅតែកូននិងម្តាយខ្ញុំហ្នឹងប្តីខ្ញុំថាទៅមើលផ្ទះទទួលគេឲ្យទៅខាងណោះហើយខ្ញុំទៅខាងណេះ អ៊ីចឹងទៅណា៎បែកគ្នាអ៊ីចឹងដល់រួចទៅខ្ញុំដាំៗឲ្យតែជួបផ្តាំទាំងអស់ដើម្បីរកប្តី ។

សៈ តើក្រោយពេលចាប់ ទីវ មុី ទៅប្រពន្ធនិងកូនអត់ចាប់ទៅទេ?

ឆៈ យកតែ ទីវ មុី ទៅមុន ប្រហែលជាចុង ៧៧ ឬ ៧៨ ហ្នឹងបញ្ជូនប្រពន្ធទៅទៀត ។ មិនចាប់ទេ ហៅស្រួលណាស់គេចាក់ដាក់មេក្រូនរណាក៏សប្បាយដែរអត់ដឹងផាប់ទេ ដូចមមៀចអ៊ីចឹងណា៎ ។ ចាក់សុទ្ធតែចម្រៀងបដិវត្តន៍ ចាក់មេក្រូឡូៗអ៊ីចឹងៗទៅប្រមូលយើងយកទៅដាក់សាលារៀនម្តុំ ហើយយាមជុំវិញ ។ បាយឲ្យស៊ីឆ្អែតៗ ប៉ុន្តែប្អូនខ្ញុំដឹងខ្លួនហើយ អាមុី ក៏ដឹងខ្លួន ដឹងខ្លួនព្រោះឃើញគេសម្លាប់បណ្តើរៗហើយ ។

សៈ ពេលដែលអ៊ំបានទស្សនាវដ្តី «ស្វែងរកការពិត» អ៊ំអានទៅតើសាច់រឿងពិត ឬមិនពិត?

ឆៈ ពេលដែលខ្ញុំអានទៅ ខ្ញុំយកឲ្យបងប្អូនមើលគ្រប់គ្នា ហើយអាប្អូនខ្ញុំមួយទៀតនៅជាមួយម៉ែ ខ្ញុំផ្ទះជាប់ៗគ្នា ហ្នឹងយកទៅមើល ហើយគិតចុះគិតឡើងអន្ទុយយំទាំងអស់គ្នា ។ ខ្ញុំឆ្ងល់អ្នកណាគេជាអ្នកដឹកនាំប្រទេស? វាសមតែសាសន៍គេយល់ទេ? បើខ្មែរដឹកនាំប្រទេស ហេតុអីក៏សម្លាប់? យកដីឲ្យអ្នកណានៅ? ខ្ញុំឆ្ងល់អ៊ីចឹងទេ ខ្ញុំអន្ទុយឆ្ងល់ម៉េចបានជាធ្វើអ៊ីចឹង? បានថាអ្នកនយោបាយនោះណា៎ ចុះអាគ្នាអត់នយោបាយ ម៉េចក៏សម្លាប់គ្នាដែរ? គេយកអាខ្លៅមកឲ្យត្រួតយើងខ្លះអត់ចេះខ្មែរផង អត់ចេះសរសេរទៀតប៉ុន្តែបដិវត្តន៍គេនិយាយ

ឡើងសុទ្ធតែ «**គឺជាដើម្បី**» ហើយយកទៅសម្លាប់អ៊ីចឹង ខ្ញុំឆ្ងល់ថា ដែនដីយើងមិនត្រូវការអ្នកចេះដឹងហ្ន៎? ហេតុអីបានគេយកទៅសម្លាប់អ៊ីចឹង?

សៈ អ៊ំចង់ឲ្យពួកខ្មែរក្រហមឆ្លើយ?

ឆៈ ខ្ញុំសួរថាអ្នកណាគេហ្ន៎? ជាអ្នកដឹកនាំប្រទេសជំនាន់ហ្នឹងបានជាយកមនុស្សទៅសម្លាប់ចោលទុក ដីឲ្យអ្នកណានៅ? បើរាប់ខ្មែរវិញខ្មែរទាំងអស់គឺបងប្អូនគ្នាទាំងអស់ គេថាឈាមខ្មែរនោះណា៎ មិនគួរសម្លាប់គ្នាទេ សូម្បីតែសម្លាប់តាមផ្លូវប្លន់យកម៉ូតូក៏ខ្ញុំអាណិតគេដែរ ។ ប៉ុន្មានថ្ងៃមុន ខ្ញុំទៅខេត្តកំពង់ចាមស្វែងរកវត្តភ្នំប្រុស ភ្នំស្រី កំពង់ចាមហ្នឹងណា៎ គេថាគេឃើញរណ្តៅខ្មោចអី ខ្ញុំស្វែងរក ខ្ញុំដឹងថា.. គេប្រាប់ខ្ញុំថា ប្អូនខ្ញុំហ្នឹងហើយនិង ម្តាយធំទៅស្លាប់នៅហ្នឹង ។ ខ្ញុំសួរគេថាចុះគេយកមនុស្សមកសម្លាប់នៅត្រង់ណាកាលជំនាន់ប៉ុលពត? គេថានេះអ៊ំត្រង់ស្រះពីរជួរៗព័ទ្ធជុំវិញអ៊ីចឹងមក បួនជ្រុងអ៊ីចឹង ប៉ុន្តែសុទ្ធតែរណ្តៅពេញទាំងអស់សុទ្ធតែរណ្តៅមួយៗ៥០ម៉ែត្រឯណោះ អូនឯងគិតមើលជម្រៅ១០ម៉ែត្រក៏មាន ៥ម៉ែត្រក៏មាន អ៊ីចឹងទៅ វែករនៅហ្នឹងទាំងអស់ ។

ហើយអ្នកស្រុកប្រាប់ខ្ញុំថាក្មេងណា៎ឮ មាត់នៅលេងក្រោមដើមឈើហ្នឹងឲ្យរញៀវ អាខ្លះយំ អាខ្លះសើច អ៊ីចឹងទៅណា៎ វាអត់ដឹងអីកូន ក្មេងតូចៗអ៊ីចឹងអារញៀវៗអ៊ីចឹង គ្រាន់តែថ្ងៃរសៀលបន្តិចបាត់អស់រលីងអត់ឮសំលេង ។ ថាអណ្តូងមួយណា៎ជ្រៅអើយជ្រៅដាក់ទាល់តែកំពុងអត់កប់ទេ ។

សៈ កន្លែងហ្នឹងឈ្មោះអី? នៅខាង ណាខាងភ្នំ...?

ឆៈ ភ្នំប្រុសអ៊ីចឹង ភ្នំស្រីអ៊ីចឹង បើកឡានចូលទៅឡានខ្ញុំទៅទើបនឹងមកអាទិត្យមុនហ្នឹង បើកឡានចូលទៅលើភ្នំប្រុសអាក្បែរវាហ្នឹងទៀតជាប់ផ្លូវឡើង ឃើញផ្លូវលំមួយហ្នឹងឡើងទៅភ្នំស្រី ត្រង់កន្លែងសម្លាប់ហ្នឹងមានចេតិយមានគេតាំងរូបក្បាលអ្នកងាប់ហ្នឹងណា៎តាំងបានតែអាលើៗទេ គេប្រាប់ខ្ញុំគេថាគេរើសតែអាណាលេចផុសអណ្តែតដែលឆ្កែវាអូសហ្នឹងណា៎ គេរើសយកទៅដាក់ទៅត្រង់អានៅក្នុងកប់រណ្តៅហ្នឹងយកត្រាក់ទ័រ ទៅមើលចង់និយាយថាទៅរកភ័ស្តុតាងឯណាយកអាត្រាក់ទ័រទៅគាស់ហើយហៅអន្តរជាតិទៅមើលទៅគរដូចភ្នំ ។ ពួកអ្នកស្រុកប្រាប់ខ្ញុំថាពេលវាហើមពោះដោររឡើងដង្កូវ ។



សៈ អ៊ីស្លាប់បងប្អូនអស់ប៉ុន្មាននាក់ដែរ?

ឆៈ អាឆ្ងាយកុំនិយាយណា៎ បងប្អូនបង្កើត របស់ខ្ញុំអស់៣-៤ហើយ ។

សៈ តាមអ៊ីនៅចាំបានតើនៅកន្លែងហ្នឹង អ៊ីមានធ្លាប់ស្គាល់ឈ្មោះមេដឹកនាំខ្មែរក្រហមទេ? មេខ្មែរក្រហមធំៗទេ?

ឆៈ មេធំៗខ្ញុំដឹងតែមេ...អើយ...មិត្តណែមហ្នឹងគឺមេគណៈស្រុក

សៈ ចុះលើហ្នឹងទៀត?

ឆៈ លើហ្នឹងទៀតខ្ញុំអត់ដែលដឹង

សៈ កាលហ្នឹងអត់ដែលមានពួឈ្មោះ ប៉ុល ពត អត់ដែលមានពួឈ្មោះអៀង សារី អត់ដែលពួឈ្មោះនួន ជា កែ ពក អីទេ?

ឆៈ គ្រាន់តែពួ ។ ខ្ញុំមិនដែលឃើញមុខគេទេ ។ អាប្រធានសង្កាត់ អាប្រធានភូមិ អាប្រធានអីគេហ្នឹងគឺខ្លាចមិនហ៊ានមើលមុខ អ្នកណាមួយយើងមិនដឹង យើងគិតតែពីខំរែកដីអត់ហ៊ានមើលមុខគេទេ ។ ថ្ងៃមួយខ្ញុំទៅសួនជិតមន្ទីរឃុំឃាំងរបស់វាណា៎ គ្រូបង្រៀនខ្លះចាប់យកទៅទាំងស្រីទាំងប្រុស យកទៅទុកនៅហ្នឹងបណ្តើរអ៊ីចឹងទៅឃើញក្តាមចាប់ដាក់មាត់ក្លាម ឃើញកង្កែបចាប់ដាក់មាត់ដូចអាបអ៊ីចឹង ខ្ញុំប្រាប់អូនឯងគឺអត់មានឲ្យស៊ីគ្រប់គ្រាន់ទេ ហើយឲ្យគ្នាធ្វើស្រែដល់គ្នាធ្លាក់ខ្លួនឈឺរត់គោងស្មាអ្នកជាណា៎ ។ ខ្ញុំមើលឃើញទឹងភ្នែកពេលហ្នឹងភ្លៀងណា៎ ដល់ម៉ោងគេត្រូវវាយជួងចេញទៅផ្ទះ ហើយគេវាយជួងម៉ឺងអ៊ីចឹងទៅពួកវាហ្នឹងកាំបិតខ្វែវវាដងវែងដូអ៊ីចឹង វា

វាយក្បាលអ្នកឈឺហ្នឹងពួសួរតែភូសៗដូចវាយដូងទុំអ៊ីចឹង ហើយអត់មានយំអត់មានទឹកភ្នែកទេអូន ញញឹមទៀតណា៎ វាយភូសឡើងហូរឈាមហើយ អ្នកស្រុកប្រាប់ខ្ញុំថាហ៊ានយំងាប់ឥឡូវវាវាយភូសហើយវាសួរថាឈឺមិនឈឺអ៊ីចឹងទៀតណា៎ បើថាឈឺក៏ថែម បើថាមិនឈឺក៏ថែមមិនដឹងធ្វើម៉េចទេ ។ ពេលខ្ញុំសួន ខ្ញុំឃើញគេ «ពួកសន្តិសុខ» សែងខ្មោចហ្នឹងយកមក ហើយដោយដាក់ខ្មោចលើសង្កសីមួយសន្ទឹកអត់មានខោអាវអីទេ មានតែខោខ្លីមួយ ស្គមសល់តែស្បែកដណ្តប់ឆ្អឹង វាអត់ឲ្យស៊ី វាយកកៅស៊ូកងដាក់សឹកសង្កសីមុខក្រោយ ហើយខ្មោចមួយសែងតែគ្នាពីរនាក់ ។ កាប់កប់តែមួយចបទេនៅលើទួលមួយគេហៅថា ទួលក្រសាំង ខ្មោចងាប់ដូចម្រាមដៃ ត្រង់ណាក៏មានខ្មោចដែរ ហើយពេលភ្លៀងមកសុទ្ធតែដង្កូវចុះប៉ុនៗចុងចង្កឹះ ទឹកឡើងខៀវពេលត្រូវពន្លឺថ្ងៃចាំងផ្លេកៗ ព្រោះខ្លាញ់អណ្តែត ពេលខ្ញុំសួនខ្ញុំបេះតែជញ្ជ្រាំដើងខ្លាចដង្កូវហ្នឹង នៅពេលសួនខ្ញុំបេះតែងើបមើលអ៊ីចឹងខ្ញុំរាប់ម្ញៃៗ៦-៧នាក់ ងាប់រាល់ថ្ងៃ...។

សៈ សូមកាត់ប្រសាសន៍ត្រឡប់ទៅ ទីវ ម៉ី ពេលដែលចាប់ទៅនៅម៉ោងប៉ុន្មាន?

ឆៈ ចាប់នៅម៉ោង ប្រហែលជាពេលបាយរួចថ្ងៃត្រង់នៅរដូវក្តៅព្រោះយើងហាលស្លឹក ។ ពេលបាយរួចក្លាមនាំគ្នាលើកស្លឹកដាក់រទេះមិនបានកន្លះរទេះផងហ្នឹង ។

សៈ ក្នុងការដែលគេចាប់ ទីវ ម៉ី យកទៅតើអ៊ីមានដឹងថាមកពីមូលហេតុអ្វីទេ?

ឆៈ ធម្មតាឲ្យតែគេយកទៅរៀនសូត្រគឺងាប់មិនដែលមកវិញទេមិនដឹងទេតាមដែលខ្ញុំស្មានប្រហែលជាឃុំនៅក្នុងហ្នឹង ស្រាប់តែលេចពួអូនឯងនិយាយហ្នឹង ខ្ញុំថាអុញអានេះមកងាប់ឯណោះតើ ចាស់ អ៊ីចឹងបានសេចក្តីថា ទីវ អុល ងាប់មុនហ្នឹងយូរដែរហើយ ។

សៈ ចំពោះអ៊ីពាក្យថាយុត្តិធម៌មានន័យថាម៉េច?

ឆៈ មិនដឹង ខ្ញុំមិនយល់ ។ មិនដឹងហេតុម៉េចបានជាគេធ្វើយ៉ាងហ្នឹងទេ ។

សៈ អ៊ី មានដែលប្រាប់លម្អិតបែបហ្នឹងអំពីរបបខ្មែរក្រហមដែលអ៊ីឆ្លងកាត់មក ដល់កូនដែលមិនបានឆ្លងកាត់ឲ្យដឹងទេ?

ឆៈ ប្រាប់ទាំងអស់ហ្នឹង

សៈ តើបើតាមគំនិតរបស់អ៊ីរឿងរ៉ាវទាំងហ្នឹងគួរតែក្មេងៗជំនាន់ក្រោយបានដឹងពួគួរតែត្រូវបំភ្លេចចោល?

ឆៈ អត់ភ្លេចបានទេអូនអើយ តទៅទៀតក៏មិនភ្លេចបានដែរ និយាយជំនាន់នេះមានស៊ីប៉ុណ្ណេះគ្រាន់ហើយ ហើយឈឺប៉ុណ្ណេះនៅមានថ្នាំគ្រប់គ្រាន់ ។ ខ្ញុំកាលណោះមានជម្ងឺ អារាកអាចម៌ក៏ថ្នាំហ្នឹង អាគ្រុនក្តៅក៏ថ្នាំហ្នឹង ថ្នាំតែមួយព្យាបាលជម្ងឺគ្រប់មុខសុទ្ធតែថ្នាំអាចម៌ទន្សាយទាំងអស់ ។

សៈ ក្នុងនាមអ៊ីជាជនរងគ្រោះម្នាក់ដែរតើការដែលបង្កើតឲ្យមានតុលាការសម្រាប់កាត់ទោសខ្មែរក្រហម អ៊ីយល់ឃើញថាយ៉ាងណាដែរ?

ឆៈ និយាយថាមិនចង់យ៉ាងម៉េច ហើយចង់មើលដូចព្រាប អ៊ិន ដែលគេយកទៅប្រហារជីវិតតាមរោងកុនទាំងអស់ដែលគេដាក់បញ្ចាំងឲ្យមើលកាលជំនាន់ហ្នឹងត្រូវតែមើលអ៊ីចឹងហ្នង ។

សៈ ក្នុងការកាត់ទោសខ្មែរក្រហម ដើម្បីឲ្យមានភាពយុត្តិធម៌ចំពោះជនរងគ្រោះតើអ៊ីចង់ឲ្យតុលាការខ្មែរជាអ្នកកាត់ទោសឬចង់ឲ្យតុលាការជាលក្ខណៈអន្តរជាតិជាអ្នកកាត់ទោស?

ឆៈ បើចិត្តរបស់ខ្ញុំចង់ឲ្យតុលាការអន្តរជាតិវិញព្រោះគេជាជាតិដ៏ទៃគេកាត់ទោសទៅក្រែងវាយុត្តិធម៌ជាងដូចតុលាការខ្មែរសព្វថ្ងៃចាប់បានចោររួចលែងចោរទៅវិញ ក្រែងលោអ៊ីចឹង អានេះចិត្តខ្ញុំទេណា៎ ។

សៈ ស្រុកខ្មែររហូតដល់ពេលឥឡូវហ្នឹង គ្រប់គ្រួសារនៅមានពុំនិយាយពីការបាត់បងប្អូននៅឡើយ រហូតដល់អ្នកខ្លះទៀតគេកំពុងតាមរកបងប្អូនដែលបានបាត់ខ្លួនក្រោមជំនាន់ប៉ុលពតនៅឡើយ តើអារម្មណ៍របស់អ៊ីផ្ទាល់យ៉ាងម៉េចដែរចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងចំពោះគ្រួសារអ៊ីក្នុងរបបនោះ?

ឆៈ ខ្ញុំឈឺចាប់ និងខឹងនៅពេលដែលមើលឃើញទាំងអស់គ្នាដូចជាប្អូនខ្ញុំ ក្មួយខ្ញុំអីហ្នឹងដែលវានាំទៅមិនដឹងជាសម្លាប់របៀបណា ។ ប្អូនខ្ញុំបានទៅឈរយំនៅលើរណ្តៅខ្មោចឈឺចាប់រាល់តែថ្ងៃអ៊ីចឹងដល់ពេលបុណ្យភ្ជុំម្តងៗក៏រឹតតែឈឺចាប់ទៀតខ្ទិសអស់បង្សុកូលអស់ ប៉ុន្តែមិនដឹងថាយើងទៅធ្វើយ៉ាងម៉េចគេកើតស្រេចលើច្បាប់ចុះ បើអន្តរជាតិជួយយើងអ្នកណាខុសអ្នកណាត្រូវស្រេចលើគេចុះដល់ត្រឹមនេះ អ៊ំស្រី មាស សារិន (និយាយដោយ អួលដើមក) ។

សៈ ខ្ញុំអស់សំណួរតែប៉ុណ្ណឹង សូមអរគុណអ៊ំ! ។

បទសម្ភាសន៍នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០០០

ដោយ **ផាត កុសល** និង **ថ្លុង សុភារិទ្ធ**



សហករណ៍វាយសម្រុកលើកទំនប់

# កោះខ្សាច់ទន្លេ កោះស្រ្តីមេម៉ាយ



**(តពីលេខមុន)** *កោះខ្សាច់ទន្លេមានបណ្តោយប្រវែង៦គីឡូម៉ែត្រ និងទទឹងប្រវែង៣គីឡូម៉ែត្រ ហើយមានរោងបាយរួម៦ ។ រោងបាយបីស្ថិតនៅជាជួរនៅផ្នែកខាងកើតកោះ ហើយបីទៀតស្ថិតនៅជាជួរនៅផ្នែកខាងលិច ។ ផ្ទះត្រូវបានសង់ឡើងជុំវិញរោងបាយទាំងអស់នោះ ។ «ប្រជាជនមូលដ្ឋាន» ដែលមានដើមកំណើតនៅលើកោះនេះ ព្រមទាំងស្ត្រីមេម៉ាយដែលអង្គការបានរៀបការឲ្យម្តងទៀតនោះ រស់នៅភាគខាងកើតពោលគឺនៅរោងបាយទី១ ទី២ និងទី៣ ចំណែកឯស្ត្រីមេម៉ាយដែលគ្មានប្តីរស់នៅភាគខាងលិច ។ បុប្ផា និយាយថា «ពួកខ្មែរក្រហមចង់បែងចែករវាងប្រជាជនចាស់និងប្រជាជនថ្មី ។ ស្ត្រីជាប្រជាជនថ្មីដែលត្រូវបានពួកខ្មែរក្រហមចាប់យកប្តីទៅបាត់នោះត្រូវបានដាក់ឲ្យរស់នៅមួយកន្លែង ។ ពួកខ្មែរក្រហមមិនឲ្យយើងរស់នៅលាយឡំជាមួយប្រជាជនមូលដ្ឋានឡើយ ។ ពួកខ្មែរក្រហមធ្វើរបៀបនេះគឺដើម្បីគ្រប់គ្រងការពារពួកខ្ញុំទាំងអស់គ្នា ។ បើសិនជាយើងប្រព្រឹត្តអ្វីមួយខុសពួកវានឹងយកយើងទៅសម្លាប់ចោលភ្លាម» ។ ខ្មែរក្រហមគឺជាក្បាលម៉ាស៊ីនដឹកនាំដែលមានលក្ខណៈដូចគ្នា និងជាប្រពន្ធ័ ។ ការបែងចែកមនុស្សទៅតាមប្រភេទគឺអាចធ្វើឲ្យពួកខ្មែរក្រហមមានលទ្ធភាពចាត់ការចំពោះខ្មាំងសត្រូវរបស់បដិវត្តន៍ហើយព្រមទាំងអាចជៀសវាងនូវភាពល្អក់កករដល់បដិវត្តន៍របស់ខ្លួនទៀតផង ។ ទោះបីជាស្ត្រីមេម៉ាយមិនបានប្រព្រឹត្តអ្វីខុសក៏ដោយក៏ស្ត្រីទាំងនោះនៅតែមានកំហុសដោយសារមានការពាក់ពន្ធ័ដែរ ។ ដាវីគឺជាប្រជាជនមូលដ្ឋានដែលមានសិទ្ធិពេញលេញ ប៉ុន្តែគាត់ត្រូវបានបញ្ជូនមកកាន់កោះខ្សាច់ទន្លេពីព្រោះតែគាត់មានការពាក់ព័ន្ធ ។ «ខ្ញុំគឺជាប្រជាជនមូលដ្ឋាន ចុះហេតុអ្វីបានជាជីវិតរបស់ខ្ញុំលំបាកម្ល៉េះ?» គាត់បានសួរថា «តើមូលហេតុអ្វីទៅ? ពីព្រោះនាងខ្ញុំមានទោសដោយសារការពាក់ព័ន្ធជាមួយប្តីដែលពួកវាយកទៅបានជាចាត់ខ្ញុំជាប្រជាជន១៧មេសា» ។*

*នៅលើកោះនេះ ពួកខ្មែរក្រហមបានបង្កើតជាសង្គម*

ថ្មីមួយដែលជាពិភពនៃស្ត្រីក្លាហាន ។ នៅក្នុងពិភពមួយនេះគ្មានគំនិតថាឯកជននិងកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ ហើយគំនិតចំពោះគ្រួសារនិងចំពោះសហគមន៍ក៏គ្មានដែរ ។ ពេលគឺរាល់សកម្មភាពរបស់មនុស្សម្នាក់ៗត្រូវបានធ្វើឡើងដោយការភ័យខ្លាចអង្គការយកទៅសម្លាប់ចោល ។

ចាប់ពីដើមដំបូងម្ល៉េះ ពួកខ្មែរក្រហមបានព្យាយាមកម្ទេចនូវរាល់តំណាងនៃភាពប្លែកពីគ្នា និងឯកវាជ្ជភាព ព្រមទាំងរាល់សញ្ញាណទាំងឡាយណាដែលអាចធ្វើឲ្យអារម្មណ៍ស្ត្រីមិនមូលចំពោះការងាររបស់អង្គការ និងដែលនាំឲ្យមានលក្ខណៈមិនប្រក្រតីនៃភក្តីភាពចំពោះអង្គការ ។ តំណាងទាំងអស់នោះរួមមានទំនាក់ទំនងកម្មសិទ្ធិ ទំនាក់ទំនងជាមួយគ្រួសារ និងទំនាក់ទំនងផ្នែកគំនិតនិងសេរីភាព ។ ដូចដែល ដាវី បានបញ្ជាក់យ៉ាងសមស្របដូច្នោះដែរថា «ពួកខ្មែរក្រហមមិនឲ្យយើងមានអ្វីឡើយ សូម្បីតែពាក្យមួយម៉ាត់ក៏គ្មានដែរ» ។ ពេលដែល ធីតា មកដល់កោះនេះដំបូង ពួកខ្មែរក្រហមបានជម្រុះចោលនូវអ្វីៗទាំងអស់ដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់គាត់ ។ «ចាប់ពីពេលនោះមកពួកខ្មែរក្រហមបានប្រមូលយកចានក្បាននិងឆ្នាំងទាំងអស់ពីយើង ។ ហើយសូម្បីតែខោអាវក៏ត្រូវបានយកអស់ដែរ ។ ពួកខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងយករបស់អ្វីតាមខ្លួនឡើយ ។ ពួកវាអនុញ្ញាតឲ្យយើងយកតែមួយចង្កេះតែប៉ុណ្ណោះ ពោលគឺមានតែខោមួយនិងអាវមួយដែលយើងស្លៀកជាប់ខ្លួនតែប៉ុណ្ណោះ ។ យើងគ្មានអ្វីទាំងអស់» ។

លើសពីនេះទៅទៀត ស្ត្រីគ្មានសិទ្ធិក្នុងការបញ្ចេញនូវភាពចម្លែកពីអ្នកដទៃតាមរយៈអាការៈខាងក្រៅរបស់ខ្លួនឡើយ ។ សម្លៀកបំពាក់ទាំងអស់ត្រូវបានគ្រវាត់ចោលស្ត្រីទាំងអស់ត្រូវបង្ខំឲ្យស្លៀកពាក់ខ្មៅទាំងអស់ ហើយកាត់សក់ខ្លីត្រឹមកដែលជាម៉ូតសក់របស់ជនជាតិកូរ៉េ ។ ប្រសិនបើគ្មានសម្លៀកបំពាក់ខ្មៅទេ ស្ត្រីទាំងនោះនឹងយកសម្លៀកបំពាក់របស់ខ្លួនមកជ្រលក់ក្នុងភក់ ឬជ្រលក់មាក់ក្លឿ ដើម្បីឲ្យវាមានពណ៌ចាស់ ។ ជាការសំខាន់ណាស់ដែលសម្លៀកបំពាក់ទាំងនោះមិននាំឲ្យមានការចាប់អារម្មណ៍ ហើយមើលទៅមិនល្អជាងសម្លៀកបំពាក់របស់ប្រជាជនមូលដ្ឋានដែលមានសម្លៀកបំពាក់ស្អាតបាតពណ៌ខ្មៅ ស្បែកជើងកង់ឡាន ហើយនិងក្រមាបង់ក ។ រាល់ការប៉ុនប៉ងទាំងឡាយណាក្នុងការធ្វើឲ្យខុសប្លែកពីប្រជាជនរស់នៅលើកោះនេះនឹងត្រូវទទួលទោសមិនខាន ។ «ម្នាក់ៗត្រូវតែស្លៀកពាក់ខ្មៅ» នេះជាសម្តីរបស់ ចន្ធូ «គ្មានអ្នកណាម្នាក់ស្លៀកសម្លៀកបំពាក់មានពណ៌ឡើយ បើមានពណ៌នឹងត្រូវមានបញ្ហា ឬក៏យកទៅអប់រំ ។ បើពួកវាហាមយើងពីរ-បីដងហើយយើងមិនព្រមស្តាប់ នៅតែស្លៀកពាក់ដដែលនោះពួកវានឹងយកយើងទៅសម្លាប់ចោលភ្លាម ។ យើងធ្វើមិនដឹងមិនបានទេ ។ យើងត្រូវតែជ្រលក់ភក់រហូតវាប្រែពណ៌ខ្មៅហើយកខ្វក់» ។

ស្ត្រីទាំងនោះមិនត្រឹមតែត្រូវបានដកហូតសិទ្ធិនៃការយល់ឃើញរបស់ខ្លួនឡើយ តែថែមទាំងត្រូវបានឆក់ប្លន់យកនូវគំនិតជាគ្រួសារដែលជាលក្ខណៈប្រពៃណីរបស់ខ្លួនថែមទៀត ។ នៅពេលដែលធ្វើដំណើរមកកាន់ភូមិកំណើតនៅកោះខ្សាច់ទន្លេ ស្ត្រីទាំងនោះត្រូវបានអនុញ្ញាតឲ្យយកកូនមកតាមខ្លួន ។ រយៈពេលនៃការងារមានកំណត់ហើយវែងទៀតផង រហូតដល់ធ្វើឲ្យស្ត្រីទាំងនោះកម្រនឹងបានជួបមុខកូនរបស់ខ្លួនណាស់ ។ ពេលដែល ដាវី មកដល់កោះនេះ កូនស្រីរបស់គាត់មានអាយុទើបតែបាន៥ខែប៉ុណ្ណោះ ហើយនៅត្រូវការបំបៅដោះនៅឡើយ ។ នៅវេលាម៉ោង៤ព្រឹកនៃថ្ងៃបន្ទាប់ ដាវី បានជិះទូកឆ្លងទន្លេចេញទៅធ្វើការដោយទុកកូនស្រីជាមួយយាយៗនៅឯកងកុមារ ។ នាងធ្វើការនៅព្រែកវាំងដកស្ទូងស្រូវនៅទល់មុខភ្នំធនមន្ត ។ ក្រោយពីហូបបាយថ្ងៃត្រង់ជាមួយអ្នករួមការងាររួច ដាវី ក៏ជិះទូកត្រឡប់មកមកបំបៅដោះកូនដែលទើបតែមានអាយុ៥ខែរបស់គាត់ ។ ដាវី បានពោលថា «មួយថ្ងៃៗ ខ្ញុំមិនដែលបានឈប់សម្រាកទេ» ។ លុះពេលព្រលប់ទើបគាត់ត្រឡប់មកពីធ្វើការវិញ ។ ដាវី ហូបបាយល្ងាចរួចទើបមកយកកូនត្រឡប់មកផ្ទះ ។ «នៅពេលយប់ក្រោយពីត្រឡប់មកពីធ្វើការងារវិញ យាយៗក៏ប្រគល់កូនឲ្យយើងទៅផ្ទះរៀងៗខ្លួន ។ ខ្មែរក្រហមឲ្យយើងរស់នៅក្នុងផ្ទះមួយដែលមានពី៤ទៅ៥គ្រួសារ ។ មានប្រភេទផ្ទះតូចនិងផ្ទះធំ ។ ផ្ទះធំដាក់បាន១០គ្រួសារ ។ ពួកវាគ្រាន់តែក្រាលកន្ទេលហើយ ឲ្យយើងដេកជាមួយកូនរៀងៗខ្លួន» ។

ចន្ធូ ក៏មកដល់កោះនេះដែរបន្ទាប់ពីគាត់ទើបតែឆ្លងទន្លេ



ហើយភ្លាម ។ ពេលនោះកូនរបស់គាត់ទើបតែមានអាយុ១ខែប៉ុណ្ណោះ ។ ចន្ទូ បានធ្វើជាមេដោះអស់រយៈពេលប្រហែល៧ទៅ៨ខែ ព្រោះគាត់មិនអាចចេញទៅធ្វើការនៅតាមស្រែចម្ការបាន ។ នៅក្នុងរយៈពេលនោះ ចន្ទូ បានមើលនិងបំបៅដោះក្មេងនៅក្នុងក្រុមរបស់ខ្លួន ។ នៅតាមក្រុមដទៃៗជាច្រើនទៀតក៏មានស្ត្រីច្រើនដែរ ។ ចន្ទូ បានពន្យល់ថា «ស្ត្រីណាដែលទើបតែឆ្លងទន្លេហើយគឺត្រូវតែធ្វើជាមេដោះជាកំហិត» ។ ចន្ទូ មិនសូវមានទឹកដោះទេ ប៉ុន្តែគាត់នៅតែមើលក្មេងដដែល ។ គាត់មើលក្មេងចាប់ពីម៉ោង៦ព្រឹកដល់ម៉ោង៦ល្ងាច ។ នាពេលព្រលឹមឡើងម្តាយៗទុកកូនចោលហើយចេញទៅធ្វើការបាត់ៗ ។ មានពេលខ្លះដូចជា ដាវីអ៊ីចឹងដែរ ម្តាយរបស់ក្មេងទាំងនោះបានឆ្លៀតពេលមកមើលកូនមួយភ្លែត ។ «មានម្តាយខ្លះពេលឃើញមុខកូនក៏ស្ទុះទៅឱបកូនហើយស្រែកយំហ៊ូតែម្តង ។ ម្តាយទាំងនោះមានការអាណិតកូនណាស់ ព្រោះត្រូវចេញទៅធ្វើការបាត់ៗគ្មានពេលនៅក្បែរកូនបានយូរឡើយ ។ មានខ្លះទៀតមកដល់ភ្លាមឱបរឹតកូនហើយយំព្រោះខ្លួនគ្មានអ៊ីហូប» ។ នៅពេលសួរថាតើគាត់មានអារម្មណ៍យ៉ាងណាដែរនៅពេលដែលពួកខ្មែរក្រហមឲ្យមើលកូនគេដូច្នេះ? ចន្ទូ បានឆ្លើយថាគាត់មិនដែលនឹកគិតអ្វីទេ ។ គាត់ចេះតែធ្វើៗទៅ ។ «អង្គការបានចាត់តាំងការងារឲ្យខ្ញុំមើលក្មេង ហើយបើខ្ញុំមិនមើលទេ ពួកវានឹងសម្លាប់ខ្ញុំចោលភ្លាម ។ បើខ្ញុំតវ៉ាក៏ត្រូវស្លាប់ដែរ ។ ហើយបើខ្ញុំមិនមើលក្មេងឲ្យបានស្រួលបួលក៏មិនកើតដែរ» ។ ក្នុងរបប ប៉ុល ពត កិច្ចការផ្ទាល់ខ្លួន និងកិច្ចការឯកជនត្រូវបានកាត់បន្ថយឲ្យមកការងារសមូហភាពនិងការងារមិនផ្ទាល់ខ្លួនវិញ ។ ក្នុងប្រពៃណីគ្រួសារខ្មែរម្តាយតែងតែមើលកូនរបស់ខ្លួនជាពិសេសពេលដែលទើបតែឆ្លងទន្លេរួចថ្មីៗ ។ ក្នុងអំឡុងពេលនៃការធ្វើសមូហភាវូបនីយកម្ម និងការមិនឲ្យមានឯកជននូបនីយកម្ម ម្តាយលែងអាចបានមើលថែកូនទៀតហើយ គឺត្រូវតែពឹងអ្នកដទៃឲ្យមើលជំនួសវិញ ។ មានម្តាយមួយចំនួនដូច ចន្ទូ ដែរគឺត្រូវបង្ខំឲ្យធ្វើជា «ម្តាយសមូហភាព» មើលថែកូនអ្នកដទៃ ។ កិច្ចការផ្ទាល់ខ្លួនក្នុងនាមជាម្តាយត្រូវបានប្រែក្លាយទៅជាផលិតផលសាធារណៈរបស់អង្គការ ។

សុភាព ដែលឆ្លងទន្លេភ្លាមក្រោយពីមកដល់កោះខ្សាច់ទន្លេនោះ បានធ្វើជាមេដោះមួយរយៈខ្លីតែប៉ុណ្ណោះ ។ កូនរបស់គាត់បានស្លាប់ក្រោយពេលកើតបានមួយខែហើយក្រោយពីកូនស្លាប់ភ្លាមគាត់ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងកងពិសេសដោយបញ្ជូនឲ្យធ្វើការនៅព្រៃករាំង និងប្រាសាទ ។ ស្ត្រីភាគច្រើនត្រូវបានបញ្ជូនទៅធ្វើការនៅព្រៃករាំងដែលជាភូមិស្ថិតនៅត្រើយម្ខាងទន្លេនៅភាគខាងលិចកោះខ្សាច់ទន្លេ ។ ស្ត្រីទាំងនោះភ្ញាក់ពីព្រលឹមដើម្បីជិះទូកឆ្លងទន្លេ ។ នៅទីនោះស្ត្រីទាំងអស់ធ្វើការដកស្ទូង កាប់ព្រៃ ដកស្មៅ ដាំពោត និងប្រូតកាត់ប្រមូលផលស្រូវ ។ មិនតែប៉ុណ្ណោះថែមទាំងធ្វើការភ្ជួររាស់ដែលជាកិច្ចការបុរសទៀតផង ។ ក្រោយពេលធ្វើការអស់ពេលជាច្រើនម៉ោង ហើយត្រឡប់មកផ្ទះវិញនាពេលព្រលប់ ។ ស្ត្រីទាំងនោះមកយកបាយពីរោងបាយសមូហភាពដើម្បីហូបមុនពេលត្រឡប់ទៅដេកតាមកន្លែងរៀងៗខ្លួន ។

ទោះបីជាពួកខ្មែរក្រហមខិតខំព្យាយាមបំផ្លាញសញ្ញាណនៃប្រពៃណីគ្រួសារក៏ដោយ ក៏ពួកវានៅតែចង់ឲ្យស្ត្រីមេម៉ាយនៅលើកោះនេះរៀបការម្តងទៀតដែរ ។ ស្ត្រីមូលដ្ឋានដែល

រៀបការរួចជាច្រើននៅលើកោះនេះចាត់ទុកស្ត្រីមេម៉ាយដែលនៅម្នាក់ឯងថាជាការគំរាមកំហែងដល់អាពាហ៍ពិពាហ៍របស់ខ្លួនហើយចង់ឲ្យស្ត្រីមេម៉ាយទាំងនោះរៀបការឲ្យហើយឆាប់ៗ ដើម្បីបញ្ចប់បញ្ហារបស់ខ្លួន ។ តាមសម្តីរបស់ ដាវី បាននិយាយថា «ពេលខ្លះពួកខ្មែរក្រហមបានយកទាហាន ឬជនពិការ ឲ្យមករៀបការជាមួយស្ត្រីមេម៉ាយ» ។ អាពាហ៍ពិពាហ៍ប្រព្រឹត្តទៅនៅក្នុងវិហារស្ថិតនៅចុងកោះហើយក្នុងពេលនោះមួយគូៗ បានតម្រង់គ្នាជាជួរៗ ។ ស្ត្រីអង្គុយម្ខាងបុរសអង្គុយម្ខាង ។ ស្ត្រីនៅលើកោះនេះកម្រត្រូវបានគំរាមកំហែង ឬក៏ត្រូវធ្វើទារុណកម្មបង្ខំឲ្យរៀបការណាស់ ។ ប្រធានកងច្រើនតែមកសាកសួរចិត្តស្ត្រីផ្ទាល់ថានាងចង់ឬមិនចង់រៀបការ ។ ប៉ុន្តែ បុប្ផា និយាយថា «មិនបង្ខំក៏ដូចជាបង្ខំដែរ ។ យើងខ្លាចគេសម្លាប់ ។ នៅពេលនោះបើយើងធ្វើអ្វីមួយឲ្យពួកវាទាស់ចិត្ត យើងខ្លាចស្លាប់ ។ ដូច្នេះអ្នកដែលមានកូនក៏ចេះតែទ្រាំទៅ ព្រោះប្តីរបស់ខ្លួនត្រូវបានយកទៅបាត់ហើយ ។ ប្រសិនបើស្ត្រីណាហ៊ានប្រឆាំងនោះនឹងស្លាប់ចោលកូន ។ ម្ល៉ោះហើយចេះតែទ្រាំៗទៅ» ។ ទោះបីជា សុភាព អាចប្រកែកចំពោះការផ្សំផ្គុំនេះក៏ដោយ ក៏នាងនៅតែឆ្ងល់ថា ហេតុអ្វីបានជាពួកខ្មែរក្រហមបង្ខំឲ្យមានការរៀបអាពាហ៍ពិពាហ៍នេះព្រោះក្រោយពីថ្ងៃផ្សំផ្គុំហើយប្តីប្រពន្ធត្រូវបែកចេញពីគ្នា ។ «ហេតុអ្វីបានជាខ្ញុំត្រូវយកបុរសម្នាក់ទៀត ។ ខ្ញុំមានកូនរួចទៅហើយ ហើយកូនទាំងនោះមិនទាន់ធំទៀត ។ ពួកខ្មែរក្រហមបង្ខំខ្ញុំឲ្យធ្វើការទាល់តែស្លាប់ ។ កូនរបស់ខ្ញុំមិនទាន់ធំដឹងក្តីផង ក៏ពង្រាត់ពីខ្ញុំទៀត ។ កូនខ្ញុំមិនបានរស់នៅជាមួយខ្ញុំទេ ។ ហេតុអ្វីខ្ញុំត្រូវបង្កើតកូន? ខ្ញុំខំបង្កើតកូនមកពួកវាមកយកទៅអស់ដើម្បីឲ្យបម្រើវាថែមទាំងបង្អត់អាហារទៀត» ។ ពេលដែលសួរថាតើជីវិតរបស់អ្នកមានប្តីប្រពន្ធនិងអ្នកដែលមិនទាន់រៀបការម្តងទៀតខុសគ្នាយ៉ាងណានោះ ដាវី បានឆ្លើយថា «ជីវិតអ្នកមានប្តីប្រពន្ធហាក់ដូចជាពុំមានភាពស្រួលជាងជីវិតអ្នកមិនរៀបការម្តងទៀតឡើយ ។ ពេលខ្លះក្រោយពេលរៀបការហើយបើប្តីឬ ប្រពន្ធធ្វើអ្វីមួយខុស ពួកខ្មែរក្រហមនឹងយកទៅទាំងពីរ» ។ វានៅជាការអាថ៌កំបាំងនៅឡើយថា ហេតុអ្វីបានជាខ្មែរក្រហមបង្ខំឲ្យប្តីប្រពន្ធរៀបការហើយបំបែកចោលទៅវិញ ។



ម៉ម កល្យានី ថតនៅខេត្តស្ទឹងត្រែង

ស្ត្រីទាំងឡាយបានហៅកោះខ្សាច់ទន្លេថាជាគុកដែលហ៊ុំព័ទ្ធជុំវិញដោយទឹកនិងការភ័យខ្លាច ។ ថ្វីត្បិតតែស្ត្រីនៅលើកោះនេះមិនត្រូវបានធ្វើបាបខាងផ្លូវកាយមែនតែត្រូវទទួលទារុណកម្មដោយការព្រាត់ប្តី ។ ដូចដែល បុប្ផា បាននិយាយថា «ពួកខ្មែរក្រហមមិនបានធ្វើបាបដាក់គុកច្រវាក់ទេ តែបានឆក់យកប្តីរបស់ខ្ញុំទៅ វាដូចជាការចាប់ខ្ញុំដាក់គុកអ៊ីចឹងដែរ» ។ ដោយការបាត់បង់ប្តី ស្ត្រីក៏មានការព្រួយបារម្ភចំពោះការបាត់បង់ជីវិតរបស់ខ្លួនព្រមទាំងលទ្ធភាពនៃការព្រាត់ប្រាស់កូនជាទីស្រលាញ់ ។ បុប្ផា បានពន្យល់ថា «បើសិនជាខ្ញុំមិនប្រឹងធ្វើការទេ ខ្ញុំមានការព្រួយបារម្ភថាពួកខ្មែរក្រហមនឹងចាប់ខ្ញុំយកទៅ ដោយទុកឲ្យកូនខ្ញុំនៅកំព្រា ។ ដូច្នេះខ្ញុំត្រូវតែប្រឹងធ្វើការ» ។ ស្ត្រីមិនត្រឹមតែត្រូវ

បង្ខំឲ្យធ្វើការដាំទម្ងន់ទេ តែថែមទាំងត្រូវហាមមិនឲ្យនិយាយស្តីទៀតផង ។ ស្ត្រីក្លាយទៅជាមនុស្សគ ត្រូវពួកខ្មែរក្រហមដកសិទ្ធិសេរីភាពក្នុងការបញ្ចេញយោបល់ ហើយសូម្បីតែការទាក់ទងគ្នាធម្មតាក៏គ្មានដែរ ។ កងឈ្លបក្មេងៗបានលួចស្តាប់នៅក្រោមផ្ទះនីមួយៗក្រែងមានការនិយាយអាក្រក់អំពីអង្គការ ។ ដូច្នេះមិននិយាយល្អជាង ។ ដូចដែល ចន្ធូ បានរំឭកថា «នៅក្នុងជំនាន់ប៉ុល ពត រៀងរាល់យប់មនុស្សម្នាក់ៗដឹងតែពីចូលដេកក្នុងមុងតែប៉ុណ្ណោះ ។ គ្មានអ្នកណាហ៊ាននិយាយកំប្លែង ឬក៏សើចឡើយព្រោះយើងភ័យខ្លាចក្រែងនិយាយជ្រុលជ្រួស» ។ ការភ័យខ្លាចរីករាលដាលខ្លាំងរហូតដល់ធ្វើឲ្យ ធីតា គិតថាជារាត្រីកាត់សេចក្តី ។ «ក្នុងមួយថ្ងៃ បើខ្ញុំបានដេកមួយយប់ខ្ញុំអាចនិយាយថាខ្ញុំរស់ហើយ ។ប្រសិនបើខ្ញុំដេកមួយយប់ហើយព្រឹកឡើងបានឃើញពន្លឺព្រះអាទិត្យ នោះខ្ញុំនិយាយបានថាខ្ញុំនៅរស់ ។ មួយយប់ស្លាប់មួយយប់រស់ ។ ពេលយប់មកដល់ខ្ញុំគិតថាខ្ញុំស្លាប់ ។ នៅពេលដែលរង់ចាំមើលពួកខ្មែរក្រហមមកយកមនុស្សទៅ ខ្ញុំមិនដឹងថាពេលណាដល់វេនពួកខ្មែរក្រហមមកយកខ្ញុំទេ» ។

ថ្វីដ្បិតតែគ្មានការសម្លាប់មនុស្សក៏ពិតមែន តែមានស្ត្រីជាច្រើនបានបាត់ខ្លួនពីកោះនេះ ។ ខ្មែរក្រហមបានរៀបចំប្រព័ន្ធស៊ើបការណ៍ដ៏សាំញ៉ាំប្រទាក់ក្រឡាគ្នា ។ ក្រៅពីកងឈ្លបដ៏ច្រើនសន្ធឹកសន្ធាប់នៅរាយពាសពេញកោះ ក៏នៅមានមេកងផ្សេងទៀតដែលទទួលមើលការខុសត្រូវសមាជិក១០នាក់ក្នុងក្រុមរបស់ខ្លួន ។ មេកងទាំងអស់សុទ្ធតែស្គាល់កូនក្រុមរបស់ខ្លួនច្បាស់ណាស់ ។ ពេលមានបញ្ហាអ្វីមួយកើតឡើង កូនក្រុមត្រូវរាយការណ៍ឲ្យមេកងរបស់ខ្លួន ហើយមេកងនឹងរាយការណ៍ទៅថ្នាក់លើទៀត ។ ដល់ពេលនោះកូនក្រុមណាដែលមានបញ្ហានឹងត្រូវចាប់យកទៅ ។ ចន្ធូ បានលើកយករឿងរបស់ស្ត្រីម្នាក់ដែលត្រូវបានពួកខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ។ ពេលដែលស្ត្រីម្នាក់នោះកំពុងតែប្រឡេះពោតជាមួយអ្នកធ្វើការជាមួយគ្នាស្រាប់តែមានមនុស្សមកហៅគាត់ហើយប្រាប់គាត់ថាគេចង់ឲ្យនាងត្រឡប់ទៅស្រុកវិញ ។ គ្រាន់តែឮពាក្យនេះភ្លាមផ្លែពោតក៏របូតជ្រុះចេញពីដៃហើយនាងក៏រាគនោមដាក់ខោពេញ ។ ពីរ-បីថ្ងៃក្រោយមក ចន្ធូ បានឃើញសាកសពរបស់ស្រីម្នាក់នោះអណ្តែតតាមទឹក ។ ស្ត្រីរូបនេះប្រហែលជាត្រូវបាននាំយកទៅកោះគរដែលជាគុកនិងកន្លែងសម្លាប់ធំជាងគេនៅស្រុកស្អាង ។ តាមសម្តីរបស់ស្ត្រីទាំង៥រូបខាងលើ កោះខ្សាច់ទន្លេគឺជាកោះសម្រាប់ការកសាងខ្លួន ហើយកោះគរជាកន្លែងសម្លាប់មនុស្ស ។ ធីតា និយាយថា «ពួកខ្មែរក្រហមមិនសម្លាប់មនុស្សនៅលើកោះខ្សាច់ទន្លេទេ ប៉ុន្តែនាំយកទៅសម្លាប់នៅកោះគរ ។ ពួកខ្មែរក្រហមបានដាក់ជនរងគ្រោះតាមទូករួចអុំទៅកាន់កោះគរ នៅលើកោះគរពោរពេញទៅដោយសាកសព» ។ នារដូវទឹកឡើង ស្ត្រីទាំងនេះបានឃើញខ្មោចអណ្តែតតាមទឹកពីកោះគរមកវិញ ។

ជាការពិតណាស់ មានមនុស្សជាច្រើនត្រូវបានយកទៅសម្លាប់ ប៉ុន្តែក៏នៅមានស្ត្រីនិងកុមារភាគច្រើនត្រូវទទួលរង ឬស្លាប់ដោយជំងឺនិងការបង្អត់អាហារ ។ អាហារចម្បងរបស់ប្រជាជនខ្មែរគឺអង្ករ ។ តែនៅជំនាន់នោះក្រៅពីអង្ករ ស្ត្រីបានហូបអាហារផ្សេងៗទៀតដូចជា សម្លដើមឈូក សម្លម្ជូរត្រកួន ដំឡូងឈើ និងពោតមួយចឹបៗ ។ ស្ត្រីភាគច្រើនត្រូវតែខំរកអាហារបន្ទាប់បន្សំដើម្បីទទួលទាន ។ ចន្ធូ បានរំឭករឿងមួយកាលពីគាត់ទើបតែមកដល់កោះនេះពីរ-បីខែដំបូង «ពេលយើងមកដល់កោះនេះភ្លាមពួកខ្មែរក្រហមបានបង្អត់បាយយើង ។ យើងគ្មានបាយហូបអស់រយៈពេលជាច្រើនខែ ។ យើងគ្មានបាយហូបមានតែស្លឹកឈើដូចជាស្លឹកដំឡូង ឬស្លឹកឈើផ្សេងៗទៀត ។ និយាយទៅស្លឹកអីក៏បានដែរឲ្យតែហូបទៅអត់ពុល» ។ សុខភាពរបស់ស្ត្រីនៅលើកោះនេះធ្លាក់ដុនដាបយ៉ាងខ្លាំង បណ្តាលមកពីកង្វះអាហារនិងជីវជាតិគ្រប់គ្រាន់ ។ ស្ត្រីលែងធ្លាក់រដូវ ហើយម្តាយមានទឹកដោះតិចតួចប៉ុណ្ណោះសម្រាប់ឲ្យកូនបៅ ។ ស្ត្រីជាច្រើនទៅជាមានជំងឺហើម ដោយខ្វះជាតិអំបិលនៅក្នុងខ្លួន ។ តាមសម្តីរបស់ធីតា ឲ្យដឹងថា «ខ្ញុំមានរាងស្គមស្គាំងសល់តែស្បែកនិងឆ្អឹង ។ អ្នកណាក៏ដូច្នេះដែរ ។ នៅលើកោះខ្សាច់ទន្លេមនុស្សភាគច្រើនមានជំងឺហើម ។ ក្រោយពីហើមគឺស្លាប់តែម្តង ហើមនិងស្លាប់ព្រោះមនុស្សទាំងអស់គ្មានអ្វីហូបគ្រាប់គ្រាន់» ។ មនុស្សនៅលើកោះនេះតែងតែទទួលរងនូវជំងឺនេះក្នុងរដូវវស្សាពេលគឺពេលដែលមួយភាគធំនៃកោះនេះត្រូវទឹកលិចជោគជាំ ។ ចន្ធូ ដែលជាមេដោះម្នាក់នៅលើកោះនេះសង្កេតឃើញថាមានកុមារជាច្រើន

នាក់ត្រូវស្លាប់ក្នុងអំឡុងពេលនេះ ។ «មានមនុស្សជាច្រើនត្រូវស្លាប់ជាពិសេសក្មេងៗតូច ពីព្រោះវាគ្មានអ៊ីហូប ។ កូនក្មេងតូចៗស្លាប់គ្មានសល់ម្នាក់ ។ ខ្លះជាំខ្លួនរីតតែខ្លាំង ខ្លះមានស្នាមផ្សេងៗទៀតនៅលើខ្លួន ។ ខ្ញុំមិនដឹងថាវាជាអ្វីឡើយ ប៉ុន្តែក្មេងទាំងនោះដេកតែលើស្លឹកចេកប៉ុណ្ណោះ ។ ក្មេងខ្លះមានដំបៅរីកធំឡើងៗដេកនៅលើស្លឹកចេកហើយក៏ស្លាប់ទៅ ។ ក្មេងជាច្រើននាក់ត្រូវស្លាប់ពេលដែលម្តាយត្រឡប់មកពីធ្វើការវិញនៅសល់តែដៃទទេព្រោះមុនពេលចេញទៅធ្វើការស្ត្រីទាំងអស់នៅមានកូនតែពេលត្រឡប់មកវិញត្រូវបាត់បង់កូនអស់» ។

ដោយមានការសម្លាប់ច្រើន ការគំរាមកំហែងពីជំងឺរាតត្បាត ហើយនិងការបង្អត់អាហារនោះ ប្រជាជននៅលើកោះនេះទាំងមូលមានការប្រែប្រួលជាលំដាប់ ។ មានស្ត្រីជាច្រើនប៉ាន់ស្មានថា នៅលើកោះខ្សាច់ទន្លេមានស្ត្រីចំនួនប្រហែលរាប់ពាន់នាក់ ។ ប៉ុន្តែ ធីតា និង ចន្ទូ អះអាងថា ស្ត្រីទាំងអស់មានចំនួនរាប់ម៉ឺននាក់ ។ វាជាការលំបាកណាស់ក្នុងការប៉ាន់ស្មានចំនួនស្ត្រីនិងកុមារដែលនៅរស់រានក្រោយថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ។ ធីតា អះអាងថា «ជិតដល់ឆ្នាំ១៩៧៩ដែលជាឆ្នាំរំដោះ ពួកខ្មែរក្រហមសម្លាប់មនុស្សច្រើនណាស់ ។ ពេលដែលយើងមកដល់កោះខ្សាច់ទន្លេឃើញតែមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ» ។ នៅពេលទន្ទឹមគ្នានេះដែរ ធីតា បានទទួលស្គាល់ភាពចលាចលនៅលើកោះនេះដោយបាននិយាយថា «មានការច្របូកច្របល់ខ្លាំងមែនទែន ។ ពួកខ្មែរក្រហមបញ្ជូនមនុស្សទៅនេះបន្តិច ទៅនោះបន្តិច តើធ្វើម្តេចនឹងដឹងបាន? យើងមិនដឹងទេ ។ ពួកវានិយាយថា «ឥឡូវយើងត្រូវការមនុស្សទៅធ្វើការនៅទីនោះ» ។ រួចហើយវាក៏យកឡានមកដឹកពីរ-បីឡានយកទៅ ។ ពេលដែលយើងកំពុងតែត្រូវដឹកតាមឡានទៅកោះខ្សាច់ទន្លេ ពេលនោះមានមនុស្សច្រើនមែនទែន ។ តែទីបំផុតនៅឆ្នាំ១៩៧៩ មិនដឹងជាទៅណាអស់ឃើញសល់តែពីរបីនាក់ប៉ុណ្ណោះ ។ យើងមិនបានដឹងថាពួកវាយកមនុស្សទាំងនោះទៅដាក់ទីណាឡើយព្រោះយើងត្រូវវាបំបែកឲ្យនៅផ្សេងៗពីគ្នា» ។ នៅពេលដែលវៀតណាមចូលទឹកដីកម្ពុជាកាន់តែកៀកទៅៗនោះពួកខ្មែរក្រហមក៏ភ័យស្លន់ស្លោហើយជម្លៀសស្ត្រីជាច្រើនចេញពីកោះនេះទៅទិសខាងលិច ។

ឆ្លងតាមទិដ្ឋភាពនៃកោះស្ត្រីមេម៉ាយមួយនេះប្រទេសកម្ពុជាក្លាយជាប្រទេសនៃស្ត្រីមេម៉ាយ ។ បច្ចុប្បន្ននេះយោងតាមតួលេខរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិឃើញថា ២១ភាគរយនៃស្ត្រីខ្មែរគឺជាស្ត្រីមេម៉ាយ ។ រឿងរ៉ាវរបស់ស្ត្រីទាំងប្រាំរូបនៅក្នុងខេត្តកណ្តាលគឺជាសក្ខីភាពបញ្ជាក់ពីការឈឺចាប់ដែលកើតមាននៅក្នុងអំឡុងពេលកាន់កាប់ដោយពួកខ្មែរក្រហម ប៉ុន្តែវាគ្រាន់តែជាការបង្ហាញពីជ្រុងតូចមួយនៃការឈឺចាប់របស់ស្ត្រីកម្ពុជាប្រាំរូបតែប៉ុណ្ណោះ ។ ចុះស្ត្រីមេម៉ាយដទៃៗទៀតនោះមានការឈឺចាប់យ៉ាងណាទៅហើយមាននរណាជួយចងចាំអំពីការឈឺចាប់របស់គាត់ទេ? នៅចុងបញ្ចប់នៃកិច្ចសម្ភាសន៍ បុប្ផា បានទទូចថា «ខ្ញុំចង់ឲ្យជួយរកយុត្តិធម៌ឲ្យស្ត្រីមេម៉ាយផង ។ ប៉ុល ពត គឺជាឈ្មោះរបស់អ្នកដែលបានសម្លាប់ប្តីរបស់ស្ត្រីមេម៉ាយ» ។

**ម៉ម កល្យាណី**



# លិខិតពីអភិបាលខេត្តពោធិសាត់

*សូមគោរពផ្ញើជូនឯកឧត្តម* **ឆាំង យុ**

*នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

ឯកឧត្តមជាទីគោរព ខ្ញុំបាទបានទទួលនូវទស្សនាវដ្ដី (ស្វែងរកការពិតទី២) របស់មជ្ឈមណ្ឌលឯកសារកម្ពុជាហើយ នៅវេលាម៉ោង១០ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ នៅការិយាល័យរបស់យើងខ្ញុំផ្ទាល់ ខ្ញុំបានអានសាចុះសាឡើង នូវខ្លឹមសារក្នុងទស្សនាវដ្ដីរបស់ឯកឧត្តម ធ្វើឲ្យមានការរន្ធត់ផង ធ្វើឲ្យពញ្ញាក់ស្មារតីផង ដូចជារឿងដែលទើបនឹងកើតថ្មីផង ។

ខ្ញុំសូមសរសើរដោយស្មោះអស់ពីដួងចិត្ត ដោយមនសិកាឧត្តមគតិឈរខាងផលប្រយោជន៍ជាតិ និងប្រជាជនជាធំចងក្រងបាននូវទំព័រប្រវត្តិសាស្ត្រទុកសម្រាប់កុលបុត្រកុលធីតាជំនាន់ក្រោយដើម្បីពិចារណា ។ ក្នុងនាមខ្ញុំជាខ្មែរអង្គរមួយរូប សូមគោរព និងគាំទ្រ ដើរតាមមាគ៌ាប្រជាជនជាធំ ផលប្រយោជន៍ជាតិជាធំ ដោះស្រាយសន្តិភាពជាធំផ្សះផ្សាបង្រួបបង្រួមជាតិជាដែនគ្រឹះដើម្បីស្ថិរភាពនយោបាយអភិវឌ្ឍន៍ប្រទេសកម្ពុជាសម្បូរសប្បាយដូចបណ្ដាប្រទេសជិតខាងនិងនៅលើពិភពលោក ។ សូមគោរពជូនពរឯកឧត្តម និងសហការីក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងមូលឲ្យជួបប្រទះនឹងសេចក្ដីសុខគ្រប់ប្រការប្រាជ្ញាឈ្លាសវៃនិងប្រកបភារកិច្ចបានសម្រេចមួយរយភាគរយ ។ **អ៊ុំង សាមី** អភិបាលខេត្តពោធិសាត់ ។

***គោរពជូនឯកឧត្តម អ៊ុំង សាមី***

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលិខិតគាំទ្ររបស់ឯកឧត្តមដល់ការងាររបស់ខ្ញុំ និងបុគ្គលិកទាំងអស់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទន្ទឹមនឹងនេះដែរ ខ្ញុំបាទសូមសម្ដែងនូវការដឹងគុណជាអនេកដល់ប្រជាជនខេត្តពោធិសាត់ទាំងមូលដែលតែងតែយកចិត្តទុកដាក់ជួយជ្រោមជ្រែងនឹងផ្ដល់ពត៌មានដល់ក្រុមស្រាវជ្រាវរបស់ខ្ញុំបាទ ។

មកទល់នឹងសព្វថ្ងៃនេះក្រុមស្រាវជ្រាវរបស់ខ្ញុំបាទ បានស្រាវជ្រាវទីតាំងប្រល័យពូជសាសន៍បានចំនួន១៩កន្លែងរួចមកហើយនៅក្នុងខេត្តពោធិសាត់ ។ ឧក្រិដ្ឋកម្មដែលបានកើតឡើងត្រូវតែបានកត់ត្រាទុកជាប្រវត្តិសាស្ត្រដើម្បីជាមេរៀនដល់កូនខ្មែរជំនាន់ក្រោយក៏ដូចជាការការពារមិនឲ្យអំពើនេះកើតឡើងមកវិញជាថ្មីម្ដងទៀត ។ ខេត្តពោធិសាត់ជាខេត្តដែលបង្កប់នូវសោភ័ណភាពដ៏វិសេសបំផុត ។ សូមឲ្យសោភ័ណភាពនេះជួយដល់ការអភិវឌ្ឍខេត្តពោធិសាត់ឲ្យបានរីកចំរើនយ៉ាងឆាប់រហ័ស ។ ដោយក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

**ឆាំង យុ**

## អំពីរូបថតឯកសារ

រូបថតទាំងឡាយដែលបោះពុម្ពផ្សាយនៅលើទស្សនាវដ្ដីនេះមានប្រវត្តិ ប៉ុន្តែខ្លះទៀតពុំមានប្រវត្តិឯកសារយោងឲ្យបានច្បាស់លាស់ ជាពិសេសរូបថតរបស់ជនរងគ្រោះ ។ ហេតុដូច្នេះហើយបានជារូបថតមួយចំនួនពុំបានធ្វើសេចក្ដីបញ្ជាក់នៅក្នុងន័យសូមឲ្យអ្នកអានមេត្តាជួយផ្ដល់ពត៌មានបន្ថែមដូចជាឈ្មោះ អាយុ ភូមិកំណើត ឬទីតាំងនៃរូបថតដើម្បីសម្រួលដល់ការរៀបចំទិន្នន័យស្ដីអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យនេះឲ្យមានភាពកាន់តែសុក្រិតឡើង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសូមសម្ដែងនូវការដឹងគុណទុកជាមុនចំពោះពត៌មានផ្សេងៗដែលទាក់ទងនឹងរូបថតហើយដែលអាចផ្ដល់មកកាន់ការិយាល័យរបស់យើងខ្ញុំ ។ សូមអរគុណ!







**កំណាព្យ**

ជុំ ធឿន ១៥-៥-១៩៨៦

# ថ្ងៃ ២០ ឧសភា

ថ្ងៃ ២០ ឧសភា ជាប្រវត្តិ
ឆេះឆំជានិច្ចខ្មែរសូមប្តឹង
មហាវិនាសកម្មប្រល័យពូជ
ក្រោមរបបក្បត់ខ្មៅងងឹត
ខ្មែរជាងបីលានគ្មានទោសអ្វី
ឆ្អឹងគរដូចភ្នំស្ទឹងលោហិត
ដូចនេះខ្មែរអើយត្រូវចងចាំ
ចាំជាប់ជានិច្ចកុំសំចៃ
ឆេះឆំជានិច្ចនឹងបនក្បត់
កម្ចាត់ឲ្យអស់ពួកវាហ្នឹង
កុំចាញ់ឃោសនាកលឧបាយ
ធាតុពិតបនក្បត់យើងភ្លក្សហើយ
ដូចនេះថ្ងៃ២០សាក្សីល្អ
ជាក់៣លានស្លាប់យ៉ាងប្រត្យក្ស
ច្បាំងនឹង ប៉ុល ពត ចោរអប្រិយ
សម្លាប់ជាតិឯងចោទថាខ្មាំង
អំពើពួកវាសែនអាស្រូវ
កំហឹងឆេះឆំទើបសម្រេច
សូមឲ្យថ្ងៃ២០មានន័យល្អ
គ្រប់គ្នាចាំច្បាស់មិនមានឃ្លាត

ខ្មែរបានកំណត់ចងកំហឹង
ពិភពលោកដឹងពីរឿងពិត ។
ខ្មែរទាំងធំតូចដាច់ជីវិត
សែនមហាឧក្រិដ្ឋយ៉ាងខ្លោចផ្សា ។
ប៉ុល ពត អប្រិយវាប្រហារ
ប៉ុល ពត ប្ញស្សាសែនព្រៃផ្សៃ ។
រឿងរ៉ាវ៣ឆ្នាំ៨-២០ថ្ងៃ
ចាំហើយកែច្នៃចងកំហឹង ។
មិនត្រូវឱនអត់ត្រូវបេះប្រឹង
ព្រោះបានព្ញដឹងស្គាល់ជាក់ហើយ ។
វាមកលែបខាយឲ្យយើងស្បើយ
បងប្អូនខ្មែរអើយចាំឲ្យជាក់ ។
នាំគ្នាស្មោះសរំពុកអ្នក
ឯអ្នករស់នៅត្រូវតែច្បាំង ។
ចង់លើកទឹកដីឲ្យប៉េកាំង
យកលេសមកបាំងវាយកម្ទេច ។
យើងអ្នករស់នៅមិនត្រូវភ្លេច
គ្រប់ភារកិច្ចបម្រើជាតិ ។
ខ្មែរទាំងនគរផ្គង់មាយាទ
កំហឹងឆេះទៀតកុំភ្លេចឡើយ ។

**កត់ត្រាចងក្រងដោយឯកសារ**

**កញ្ញា សេី សាយ្យាណា**



**ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា**
**ទស្សនាវដ្តីចំនួន១០០០ក្បាលជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល**

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 5, May 2000
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; and the Canada Funds, Canadian Embassy, Phnom Penh, Cambodia